**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**
**និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**


## សារណាបញ្ចប់ការសិក្សា

# ការបង្កើនប្រាក់ចំណូលបុគ្គល
# តាមរយៈការអប់រំ

ស្រាវជ្រាវពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៧ ដល់ថ្ងៃទី៣១ ខែ ឧសភា ឆ្នាំ ២០១៧


តាក់តែងឡើងដោយ
និស្សិតឈ្មោះ **គឹម សេរី**

សាស្ត្រាចារ្យណែនាំ
បណ្ឌិត **ខ៊ាន់ ស៊ុនដេត**


ថ្នាក់បរិញ្ញាបត្រ វិទ្យាសាស្ត្រសេដ្ឋកិច្ច
ជំនាញ សេដ្ឋកិច្ចអភិវឌ្ឍន៍ ជំនាន់ទី៣០

ឆ្នាំចូលសិក្សា ២០១៣
ឆ្នាំសរសេរសារណា ២០១៧

# សេចក្តីថ្លែងអំណរគុណ

ក្នុងនាមខ្ញុំបាទជានិស្សិតផ្នែកវិទ្យាសាស្ត្រសេដ្ឋកិច្ចឆ្នាំទី៤ ជំនាន់ទី ៣០ ជំនាញផ្នែកសេដ្ឋកិច្ចអភិវឌ្ឍន៍ ក្រុម$E_4DA_1$ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច មានសេចក្តី សោមនស្សរីករាយជាខ្លាំង និងមានកិត្តយសសូមសំដែងការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះ៖

អ្នកមានគុណទាំងពីរ ដែលបានខិតខំចិញ្ចឹមបីបាច់ថែរក្សា ទំនុកបំរុងលើការរស់នៅ ការសិក្សា ព្រមទាំងផ្តល់នូវកម្លាំងកាយនិងកម្លាំងចិត្ត ប្រៀនប្រដៅខ្ញុំបាទឱ្យក្លាយជាពលរដ្ឋល្អក្នុងសង្គម។ ជាមួយគ្នាផងដែរ សូមសំដែងការអរគុណចំពោះបងប្អូន ប្រុស ស្រី មិត្តភក្តិ ដែលតែងតែជួយផ្តល់ការប្រឹក្សាយោបល់ និងលើកទឹកចិត្តរហូតដល់ខ្ញុំបាទសម្រេចនូវកិច្ចការងារលើ សារណានេះ។

ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង គណៈគ្រប់គ្រងការិយាល័យស្រាវជ្រាវ ការិយាល័យសិក្សា ព្រមទាំង លោកគ្រូ អ្នកគ្រូ ដែលបានបង្ហាត់បង្រៀន ផ្តល់នូវចំណេះដឹង និងឱវាទល្អៗ ជួយឱ្យការងារស្រាវជ្រាវសារណារបស់ខ្ញុំបញ្ចប់ដោយជោគជ័យ។

លោកសាស្ត្រាចារ្យបណ្ឌិត **ង៉ាន់ ស៊ុនដេត** ដែលបានចំណាយពេលដ៏មានតម្លៃក្នុងការដឹកនាំ សារណារបស់ខ្ញុំបាទ និងបានយកចិត្តទុកដាក់ក្នុងការណែនាំ បង្ហាត់បង្ហាញ និងប្រឹក្សាយោបល់នានារហូតដល់សម្រេចបាននូវការងារស្រាវជ្រាវមួយនេះឡើង។ ឯកសារស្រាវជ្រាវនេះសង្ឃឹមថា នឹងអាចជួយប្រយោជន៍ដល់និស្សិតជំនាន់ក្រោយ និងមិត្តអ្នកអានដែលមាន បំណងក្នុងការស្រាវជ្រាវលើខ្លឹមសារប្រធានបទនេះទៅមុខបន្តទៀត។

ជាចុងក្រោយ ខ្ញុំសូមជូនពរឱ្យព្រះជាម្ចាស់ ជួយថែរក្សាលោកអ្នកទាំងអស់គ្នាឱ្យជួបប្រទះតែសេចក្តីសុខ និងប្រកបដោយព្រះគុណកុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ផ្អែកលើទ្រឹស្តី ទស្សនៈទាន រួមនឹងបទពិសោធន៍នានាលើកិច្ចការស្រាវជ្រាវកន្លងមក លើមុខវិជ្ជា សេដ្ឋកិច្ចអភិវឌ្ឍន៍ បានបំផុសគំនិតខ្ញុំបាទ ឱ្យមានការស្រាវជ្រាវទាក់ទងជាមួយនឹងប្រាក់ចំណូលរបស់បុគ្គល និងការអប់រំ។ ហេតុដូច្នេះហើយ ខ្ញុំបាទបានសម្រេចចិត្តជ្រើសរើសប្រធានបទ " **ការបង្កើនប្រាក់ចំណូលបុគ្គលតាមរយៈការអប់រំ** " ដើម្បីធ្វើជាប្រធានបទនៃសារណាសម្រាប់ឡើងធ្វើបទបង្ហាញនៅពេលបញ្ចប់ថ្នាក់សិក្សាបរិញ្ញាបត្រ។

ខ្លឹមសារនៃសារណា មានគោលបំណងឆ្លុះបញ្ចាំងឱ្យឃើញពីការលើកកម្ពស់ប្រាក់ចំណូលបុគ្គល តាមរយៈការទទួលបានការអប់រំកម្រិតខ្ពស់ ដើម្បីអោយលើកម្ពស់ជីវភាពរស់នៅអោយបាន ល្អប្រសើររបស់ប្រជាជនកម្ពុជា។ ពីមួយឆ្នាំទៅមួយឆ្នាំ ប្រាក់ចំណូលរបស់ប្រជាជនកម្ពុជាបានកើន ឡើងគួរអោយគត់សម្គាល់ ប៉ុន្តែ ភាគច្រើននៃប្រជាជនដែលទទួលបានប្រាក់ចំណូលខ្ពស់ គឺសុទ្ធតែ ជាប្រជាជនដែលទទួលបានការអប់រំបានល្អប្រសើរដូច ជាមន្ត្រីរាជ្ជការ បុគ្គលិកក្រុមហ៊ុនឯកជន និង សមាជិកអង្គការសង្គមស៊ីវិលជាដើម។ ដោយសារតែ កម្លាតរវាងប្រាក់ចំណូលរវាងអ្នកទទួល បានកម្រិតនៃការអប់រំខ្ពស់ និងអ្នករៀនបានតិចតួចនេះហើយ ទើបគោលនយោបាយរាជ្ជរដ្ឋាភិបាល អណត្តិទី៥ បានបង្ហាញពីសុទិដ្ឋិនិយម ក្នុងការងាកមកយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការកែទម្រង់ វិស័យអប់រំដោយផ្តោតលើការពង្រឹងគុណភាព និងបង្កើតគោលនយោបាយជម្រុញអោយមានការ អប់រំក្នុងប្រព័ន្ធ ស្តីពីការបណ្តុះបណ្តាលវិជ្ជាជីវៈនិងបច្ចេកទេស។ ការជម្រុញគោលនយោបាយអប់រំ ផ្តោតលើបរិមាណ គឺពិតជាធ្វើអោយមានការបង្កើនប្រាក់ចំណូលរបស់បុគ្គលម្នាក់ៗ ប៉ុន្តែវាមានប្រសិទ្ធ ភាពរយៈពេលខ្លីប៉ណ្ណោះ។ ដើម្បីធានាអោយមានការបង្កើនប្រាក់ចំណូលបុគ្គលរយៈពេលវែង លុះត្រាតែពង្រឹងគុណភាពនៃការអប់រំ ដើម្បីបង្កើតធនធានមនុស្សដែលមានសមត្ថភាព ជំនាញ និងទេពកុសល្យ ក្នុងការអភិវឌ្ឍន៍ប្រកបដោយចីរភាព។

ជាចុងក្រោយ ខ្ញុំបាទសូមអភ័យទោសនូវរាល់កំហុសឆ្គងដែលកើតមានឡើងដោយអចេតនា ទាំងផ្នែកអក្ខរាវិរុទ្ធ ទាំងការប្រើប្រាស់ពាក្យបច្ចេកទេសនានា ហើយក្រុមយើងខ្ញុំរង់ចាំទទួលការរិះគន់ទាំងឡាយក្នុងន័យស្ថាបនា ដើម្បីជាបទពិសោធន៍ក្នុងការកែលម្អគុណភាពការងារស្រាវជ្រាវនាពេលក្រោយៗទៀត។

# មាតិកា

**ទំព័រ**


បញ្ជីតារាង ........ iv


## សេចក្តីផ្តើម


១. លំនាំបញ្ហា ........ ១

២. សំណួរស្រាវជ្រាវ ........ ២

៣. គោលបំណងនៃការស្រាវជ្រាវ ........ ២

៤. សារៈសំខាន់នៃការស្រាវជ្រាវ ........ ៣

៥. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........ ៣

៦. វិធីសាស្ត្រស្រាវជ្រាវ ........ ៣

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៣


## ជំពូកទី១ ទស្សនៈនៃការបង្កើនចំណូលបុគ្គល


១.១ និយមន័យនៃពាក្យគន្លឹះ ........ ៥

១.១.១ និយមន័យនៃពាក្យប្រាក់ចំណូលបុគ្គល ........ ៥

១.១.២ និយមន័យនៃពាក្យការអប់រំ ........ ៥

១.២ អត្ថប្រយោជន៍នៃការអប់រំសម្រាប់លើកកម្ពស់ប្រាក់ចំណូល ........ ៥

១.៣ លទ្ធផលនៃការវិនិយោគពីការអប់រំ ........ ៦

១.៤ ប្រាក់ចំណូលបុគ្គល ........ ៧

១.៥ ទីផ្សារពលកម្ម ........ ៩

១.៥.១ តម្រូវការពលកម្ម ........ ៩

១.៥.២ ការផ្គត់ផ្គង់ពលកម្ម ........ ១០

១.៥.៣ តុល្យភាពនៅក្នុងផ្សារពលកម្ម ........ ១០

១.៦ ករណីសិក្សាកម្រិតអប់រំរបស់ប្រទេសមួយចំនួន (ប្រទេសថៃ វៀតណាម និងសិង្ហបុរី) ........ ១០

១.៦.១ ករណីសិក្សាប្រព័ន្ធអប់រំប្រទេសសិង្ហបុរី ........ ១០

១.៦.១.១ កត្តាដែលប្រទេសសិង្ហបុរីប្រឈម ........ ១១

១.៦.១.២ កត្តាដែលសិង្ហបុរីយកចិត្តទុកដាក់ ........ ១១

១.៦.១.៣ លក្ខណចំពោះគ្រូបង្រៀននៅប្រទេសសិង្ហបុរី ........ ១១

១.៦.១.៤ គោលនយោបាយ ........ ១២
១.៦.១.៥ ចំពោះថ្នាក់នាយក ........ ១៣
១.៦.១.៦ កម្មវិធីសិក្សា ........ ១៤
១.៦.១.៧សមិទ្ធផលដែលប្រទេសសិង្ហបុរីទទួលបានពីការរួមចំណែកនៃវិស័យអប់រំ ........ ១៥
១.៦.២ ករណីសិក្សាប្រព័ន្ធអប់រំរបស់ប្រទេសថៃ ........ ១៦
១.៦.២.១ ព័ត៌មានអប់រំសង្ខេបរបស់ប្រទេសថៃ ........ ១៦
១.៦.២.២ សាកលវិទ្យាល័យល្បីៗនៅប្រទេសថៃ ........ ១៧
១.៦.២.៣ ការអប់រំវិជ្ជាជីវៈបច្ចេកទេស ........ ១៧
១.៦.៣ ករណីសិក្សាប្រព័ន្ធអប់រំរបស់ប្រទេសវៀតណាម ........ ១៨
១.៦.៣.១ ផ្នែកចំណេះដឹងទូទៅ និងឧត្តមសិក្សា ........ ១៨
១.៦.៣.២ ផ្នែកអប់រំវិជ្ជាជីវៈ ........ ១៩

## ជំពូកទី២ ករណីសិក្សាស្ដីពីការអប់រំនៅកម្ពុជា

២.១ ប្រវត្តិការអប់រំ ........ ២០
២.១.១ មុនសម័យអាណានិគមបារាំង ( កំឡុងឆ្នាំ ១៨០០ ) ........ ២០
២.១.២ សម័យអាណានិគមបារាំង ( ១៨៦៣ ដល់ ១៩៥៣ ) ........ ២០
២.១.៣ ប្រព័ន្ធអប់រំសម័យសង្គមរាស្ត្រនិយម (១៩៥៣ ដល់ ១៩៧០ ) ........ ២១
២.១.៤ ស្ថានភាពអប់រំសម័យសាធារណៈរដ្ឋខ្មែរ (១៩៧០ ដល់ ១៩៧៥ ) ........ ២២
២.១.៥ ការអប់រំសម័យកម្ពុជាប្រជាធិបតេយ្យ (១៩៧៥ ដល់ ១៩៧៩ ) ........ ២២
២.១.៦ ប្រព័ន្ធអប់រំសម័យសាធារណៈរដ្ឋប្រជានិមិតកម្ពុជា (១៩៧៩ ដល់ ១៩៨៩ ) ........ ២៣
២.២ ស្ថានភាពទូទៅនៃការអប់រំនាពេលបច្ចុប្បន្ន ........ ២៤
២.២.១ អនុវិស័យមត្តេយ្យសិក្សា ........ ២៤
២.២.២ អនុវិស័យបឋមសិក្សា ........ ២៥
២.២.៣ អនុវិស័យអប់រំមធ្យមសិក្សាចំណេះទូទៅ និងការបណ្ដុះបណ្ដាលបច្ចេកទេស ........ ២៦
២.២.៤ អនុវិស័យឧត្តមសិក្សា ........ ២៨
២.៣ គោលនយោបាយអប់រំទូទៅឆ្នាំ ២០១៤-២០១៨ ........ ២៩
២.៤ កំណែទម្រង់វិស័យអប់រំនាពេលថ្មីៗនេះ ........ ៣១

២.៤.១ វិធានការណ៍ចំពោះថ្នាក់មធ្យមសិក្សា ................................................ ៣១
២.៤.២ វិធានការណ៍ចំពោះថ្នាក់ឧត្តមសិក្សា ................................................ ៣៤
២.៤.៣ ការផ្តោតលើគុណភាពគ្រូបង្រៀនជាបញ្ហាចម្បង ........................................ ៣៥

## ជំពូកទី៣ ការវិភាគទិន្នន័យ

៣.១ ការរៀបចំទិន្នន័យ ................................................................ ៣៦
៣.២ បកស្រាយទិន្នន័យ ................................................................ ៣៦
៣.២.១ បរិយាយទិន្នន័យព័ត៌មានអង្កេត ................................................ ៣៦
៣.២.២ លទ្ធផលនៃការវិភាគការបង្កើនប្រាក់ចំណូលបុគ្គលតាមរយៈការអប់រំ ............. ៣៧
៣.២.២.១ ការវិភាគប្រាក់ចំណូលបុគ្គល តាមសាកលវិទ្យាល័យ ........................ ៣៧
៣.២.២.២ ការវិភាគប្រាក់ចំណូលបុគ្គល តាមកម្រិតនៃការអប់រំ ........................ ៣៨
៣.២.២.៣ ការវិភាគប្រាក់ចំណូលបុគ្គល តាមចំនួនឆ្នាំនៃការអប់រំ ........................ ៣៩
៣.២.២.៤ ការវិភាគប្រាក់ចំណូលបុគ្គល តាមការមានការងារធ្វើ ........................ ៤០
៣.២.២.៥ ការវិភាគប្រាក់ចំណូលបុគ្គល តាមអំឡុងពេលទទួលបានការងារ ក្រោយបញ្ចប់ ការសិក្សា ................................................ ៤១
៣.២.២.៦ ការវិភាគប្រាក់ចំណូលបុគ្គល តាមវិស័យការងារ ................................ ៤៣
៣.២.២.៧ ការវិភាគប្រាក់ចំណូលបុគ្គល តាមជំនាញ ........................................ ៤៤
៣.២.២.៨ ការវិភាគប្រាក់ចំណូលបុគ្គល តាមផ្នែកការងារ .................................... ៤៤
៣.២.២.៩ ការវិភាគប្រាក់ចំណូលបុគ្គល តាមបទពិសោធក្នុងការងារ ........................ ៤៥
៣.២.២.១០ ការវិភាគប្រាក់ចំណូលបុគ្គល និងកត្តាដែលធ្វើអោយប្រែប្រួល ......... ៤៧
៣.៣ លទ្ធផលនៃការស្រាវជ្រាវ ................................................................ ៤៨

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍

១. សេចក្តីសន្និដ្ឋាន ................................................................ ៥០
២. អនុសាសន៍ ................................................................ ៥០
ឯកសារយោង
ឧបសម្ព័ន្ធ

# បញ្ជីតារាង

**ទំព័រ**

តារាងទី១៖ ចំនួនសិស្សក្នុងថ្នាក់រៀន និងម៉ោងសក្សាតាមមុខវិជ្ជានៃស្តង់ដារបស់ប្រទេស សិង្ហបុរីនិងស្តង់ដារបស់ OECD ......១៤
តារាងទី២៖ បង្ហាញពីកម្រិតថ្នាក់សិក្សា និងប្រភេទអាយុសិក្សាតាមថ្នាក់នីមួយៗតាមប្រព័ន្ធ អប់រំបស់ប្រទេសថៃ ......១៦
តារាងទី៣៖ កម្រិតសញ្ញាបត្រអប់រំវិជ្ជាជីវៈបច្ចេកទេសនៅប្រទេសថៃត្រូវបានបែងចែកជាបី ប្រភេទ ......១៧
តារាទី៤៖ រយៈពេលសិក្សាតាមកម្រិតថ្នាក់សិក្សានៅប្រទេសវៀតណាម ......១៨
តារាងទី៥៖ ផ្នែកអប់រំវិជ្ជាជីវៈបច្ចេកទេសនៅប្រទេសវៀតណាមត្រូវបានគេបែងចែកជា បួនកម្រិត ......១៩
តារាងទី៦៖ សូចនាករស្នូលនៃគោលនយោបាយដែលបានដាក់ចេញ ......៣០
តារាងទី៧៖ បុគ្គលនៅតាមជំនាញផ្សេងៗដែលបានចូលរួមឆ្លើយកម្រងសំណួរ ......៣៦
តារាងទី៨៖ ការវិភាគប្រាក់ចំណូលបុគ្គល តាមសាកលវិទ្យាល័យ ......៣៧
តារាងទី៩៖ ការវិភាគប្រាក់ចំណូលបុគ្គល តាមកម្រិតនៃការអប់រំ ......៣៨
តារាងទី១០៖ ការវិភាគប្រាក់ចំណូលបុគ្គល តាមចំនួនឆ្នាំនៃការអប់រំ ......៣៩
តារាងទី១១៖ ការវិភាគប្រាក់ចំណូលបុគ្គល តាមការមានការងារធ្វើ ......៤០
តារាងទី១២៖ ការវិភាគប្រាក់ចំណូលបុគ្គល តាមអំឡុងពេលទទួលបានការងារក្រោយ បញ្ចប់ការសិក្សា ......៤១
តារាងទី១៣៖ ការវិភាគប្រាក់ចំណូលបុគ្គល តាមវិស័យការងារ ......៤៣
តារាងទី១៤៖ ការវិភាគប្រាក់ចំណូលបុគ្គល តាមជំនាញ ......៤៤
តារាងទី១៥៖ ការវិភាគប្រាក់ចំណូលបុគ្គល តាមផ្នែកការងារ ......៤៤
តារាងទី១៦៖ ការវិភាគប្រាក់ចំណូលបុគ្គល តាមបទពិសោធក្នុងការងារ ......៤៥
តារាងទី១៧៖ វិភាគប្រាក់ចំណូលបុគ្គល និងកត្តាដែលធ្វើអោយប្រែប្រួល ......៤៧
តារាងទី១៨៖ ការធ្វើតេស្តលទ្ធផលស្រាវជ្រាវ......៤៨

# សេចក្តីផ្តើម

# សេចក្តីផ្តើម

ការលើកម្ពស់វិស័យអប់រំគឺជាកត្តាដ៏សំខាន់បំផុត ក្នុងការអភិវឌ្ឍប្រទេសអោយមានភាពរីកចម្រើនលើគ្រប់វិស័យដូចជា កសិកម្ម ឧស្សាហកម្ម និងសេវាកម្ម ដែលត្រូវបានគេចាត់ទុកជាសសរស្តម្ភនៃសេដ្ឋកិច្ចជាតិ។ គ្រប់សកម្មភាពលើស្នួយសេដ្ឋកិច្ច គឺទាមទារនូវធនធានមនុស្សដើម្បីប្រើប្រាស់ធនធានកម្រសម្រាប់ចូលរួមដំណើរការ ផលិត បែងចែក និងប្រើប្រាស់។ ធនធានកម្រមានដូចជា ដី ពលកម្ម មូលធន និងសហគ្រិនភាពជាដើម (ហាស់ វង់ដារា ២០១៧) ។

ជាការពិតណាស់ ប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើននៅលើសកលលោក ចាប់ផ្តើមយកចិត្តទុកដាក់លើគុណភាពនៃការអប់រំប្រជាជនរបស់ខ្លួនអោយមាន សមត្ថភាព ជំនាញ និង មានផលិតភាពក្នុងកត្តាផលិតកម្មនានា ដើម្បីឈានទៅដល់ការអភិវឌ្ឍប្រទេសប្រកបដោយចីរភាព និងភាពសម្បូរសប្បាយរីកចម្រើន។ ប៉ុន្តែប្រទេសតតិយលោកភាគច្រើនមិនសូវសម្បូរធនធាន មនុស្សដើម្បីចូលរួមក្នុងការប្រើប្រាស់រាល់ធនធានធម្មជាតិដែលមាន អោយអស់សក្តានុពលនោះទេ មិនថារដ្ឋាភិបាល ឬក៏ប្រជាពលរដ្ឋក្តី។ ភាពទន់ខ្សោយខាងផ្នែកគ្រប់គ្រង ប្រើប្រាស់ និងបែងចែកនូវធនធានដែលមានបានបណ្តាលអោយគ្មានប្រសិទ្ធភាពសេដ្ឋកិច្ច។ កត្តាទាំងនេះ បានធ្វើអោយប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើនបាត់បង់ផលប្រយោជន៍ និងឱកាសនៃការរកចំណូល ជូនជាតិយ៉ាងច្រើនសន្ធឹកសន្ធាប់។

ប្រទេសលោកទីបីភាគច្រើន បានធ្វើសកម្មភាពសេដ្ឋកិច្ចដោយពឹងផ្អែកលើការនាំចេញវត្ថុធាតុដើម ដើម្បីដោះស្រាយលើបញ្ហាចំពោះមុខផ្នែកហិរញ្ញវត្ថុ ជាហេតុនាំអោយខាតបង់សេដ្ឋកិច្ចមួយផ្នែកធំ។ ចំណែកឯ ប្រាក់ចំណូលរបស់ប្រជាជនម្នាក់ៗ ក៏នៅមានកម្រិតនៅឡើយដោយសារតែ វិសាលភាពនៃការអប់រំនៅក្នុងប្រទេស។

ទិដ្ឋភាពនេះបានបង្ហាញអោយឃើញថា ដើម្បីបង្កើនប្រាក់ចំណូលបុគ្គលម្នាក់ៗ អោយបានប្រសើរ ជាពិសេសរួចផុតពីបន្ទាត់នៃភាពក្រីក្រ និងបញ្ហាសុខភាព ផលិតភាពការងារទាប លុះត្រាតែ បុគ្គលម្នាក់ៗ ទទួលបានការអប់រំបានល្អប្រសើរ។ ដូច្នេះ **ការបង្កើនប្រាក់ចំណូលបុគ្គល គឺអាស្រ័យទៅនឹងការអប់រំ។**

## ១. លំនាំបញ្ហា

ក្រោយពីប្រទេសកម្ពុជា បានបញ្ចប់សង្គ្រាមស៊ីវិលជាស្ថាពរនៅឆ្នាំ ១៩៩៨ រាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែងយកចិត្តទុកដាក់យ៉ាងខ្លាំង ក្នុងការស្តារ និងអភិវឌ្ឍប្រទេសជាតិឡើងវិញ។ រាជរដ្ឋា

ភិបាលកម្ពុជា បានដាក់ចេញនូវគោលនយោបាយ និងសកម្មភាពអភិវឌ្ឍន៍ចម្បងនានាដែលបានផ្តោតសំខាន់លើការលើកកម្ពស់ជីវភាពប្រជាជនតាមរយៈការអប់រំ។ នារយៈពេលកន្លងមក រាជរដ្ឋាភិបាលកម្ពុជាបានកំពុងរៀបចំកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តនានា រួមមាន សាលារៀន ផ្លូវថ្នល់ ស្ពាន អគ្គិសនី ទឹកស្អាត មន្ទីរពេទ្យ និងហេដ្ឋារចនាសម្ព័ន្ធនានាផ្សេងទៀត ក្នុងគោលដៅដើម្បីជំរុញ ជីវភាព និងលើកម្ពស់ប្រាក់ចំណូលប្រជាពលរដ្ឋអោយបានល្អប្រសើរ។ ដោយសារតែសិស្ស-និស្សិត បានចូលរៀន និងចូលបំពេញការងារ ជាហេតុធ្វើអោយប្រាក់ចំណូលរបស់ពួកគេមានការ កើនឡើង។

ជាច្រើនឆ្នាំកន្លងមក ប្រជាជនរស់នៅដោយភាពខ្វះខាតលើគ្រប់វិស័យដូចជា ការទទួលបានការអប់រំ ការទទួលបានសេវាថែរទាំសុខភាពឥតគិតថ្លៃ និងភាពខុសគ្នានៃការទទួលបានប្រាក់ចំណូល ។ ប៉ុន្តែនារយៈពេលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ រាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់យ៉ាងខ្លាំងដោយដាក់ចេញនូវយុទ្ធសាស្ត្រត្រីកោណ និងចតុកោណដើម្បីកែរលម្អជីវភាពប្រជាជនឡើងវិញដោយបានពង្រឹងគុណភាពអប់រំ និងបង្កើនបរិមាណនៃការអប់រំ ក្នុងគោលបំណង ដើម្បីអោយប្រជាពលរដ្ឋមានការងារធ្វើ និងទទួលបានប្រាក់ចំណូលប្រសើរ។

ប្រាក់ចំណូលរបស់ប្រជាជនម្នាក់ៗ ពិតជាមានសារៈសំខាន់សម្រាប់ធ្វើអោយរីកចំរើន ឬថយក្រោយនៃសេដ្ឋកិច្ចរបស់បុគ្គល និងប្រទេសជាតិ។ ប្រសិនបើប្រជាជនកម្ពុជាម្នាក់ៗទទួលបានប្រាក់ ចំណូលល្អប្រសើរ នោះប្រទេសជាតិក៏មានការរីកចម្រើនដូចគ្នាដែរ។ យ៉ាងណាមិញ ប្រាក់ចំណូល របស់ប្រជាជនម្នាក់ៗ អាចទទួលបានល្អប្រសើរវាអាស្រ័យលើកត្តាដូចជា ចំណេះដឹងបទពិសោធន៍ ជំនាញ និងកម្រិតនៃការអប់រំជាដើម។

ប្រព័ន្ធអប់រំនៅប្រទេសកម្ពុជានាពេលបច្ចុប្បន្ន កំពុងតែជួបនូវការខ្វះខាតជាច្រើពីព្រោះរាជរដ្ឋាភិបាលកម្ពុជាជំរុញតែបរិមាណនិស្សិត ប៉ុន្តែមិនបានយកចិត្តទុកដាក់លើប្រសិទ្ធភាពនៃការអប់រំ ជាហេតុនាំអោយការផ្គត់ផ្គង់កំលាំងពលកម្មដល់ទីផ្សារពលកម្មមានការខ្វះខាតគុណភាពហើយប្រាក់ចំណូលដែលទទួលបានក៏មានកម្រិតផងដែរ។

## ២. សំណួរស្រាវជ្រាវ

ក្នុងខ្លឹមសារនៃការស្រាវជ្រាវ យើងសូមលើកឡើងនូវចំណោទបញ្ហាមួយគឺៈ

- តើការអប់រំមានឥទ្ធិពលលើចំណូលដូចម្តេចខ្លះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ចំពោះខ្លឹមសារនៃសារណាទាំងមូល មានគោលបំណងបង្ហាញអំពីៈ

- ការបង្កើនប្រាក់ចំណូលបុគ្គលតាមរយៈការអប់រំ
- សិក្សាអំពីប្រាក់ចំណូលបុគ្គលតាមជំនាញ ដើម្បីលើកម្ពស់សេដ្ឋកិច្ចជាតិ
- ការពង្រឹងគុណភាពអប់រំ ក្នុងគោលបំណងឱ្យកម្លាំងពលកម្មមានជំនាញ និង សមត្ថភាពក្នុងការបង្កើតផលិតភាពការងារ។

## ៤. សារៈសំខាន់នៃការស្រាវជ្រាវ

សារៈសំខាន់នៃប្រធានបទ គឺបង្ហាញដល់អ្នកអានពីៈ

- គុណភាពនៃការអប់រំក្នុងគោលបំណង ដើម្បីបង្កើនប្រាក់ចំណូលបុគ្គលអោយបានល្អប្រសើរ
- ផ្តល់ជូននូវបទពិសោធលើករណីសិក្សា អំពីប្រព័ន្ធអប់រំរបស់ប្រទេសរីកចំរើននៅអាស៊ីមួយចំនួន
- ផ្តល់ជូនជាលទ្ធផលនៃការស្រាវជ្រាវថ្មីៗ ទុកសម្រាប់អ្នកស្រាវជ្រាវបន្តបន្ទាប់ទៀត
- ចែករំលែក បទពិសោធ និងចំណេះដឹង រវាងគ្នានឹងគ្នា។

## ៥. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

- សិក្សាលើស្ថានភាពការបង្កើនប្រាក់ចំណូលបុគ្គលក្នុងវិស័យ ទីផ្សារ គណនេយ្យ និង គ្រូបង្រៀន តាមរយៈចំនួនឆ្នាំនៃការទទួលបានការអប់រំ នៅក្នុងឆ្នាំ ២០១៧ នៅទីក្រុងភ្នំពេញ។

## ៦. វិធីសាស្ត្រស្រាវជ្រាវ

ចំពោះវិធីសាស្ត្រស្រាវជ្រាវ យើងបានជ្រើសរើសយកវិធីសាស្ត្របរិមាណវិស័យ (Qualitative Method) ដើម្បីធ្វើការវិភាគលើ ទិដ្ឋភាពជាក់ស្តែងជុំវិញស្ថានភាពនៃការបង្កើនប្រាក់ចំណូលនៅទីក្រុងភ្នំពេញ លើកក្តានៃការអប់រំ និងចំនុចពាក់ព័ន្ធមួយចំនួនទៀត។

ការស្រាវជ្រាវនេះត្រូវការ **ទិន្នន័យបឋម** ( Primary Data) មកធ្វើ ជាមូលដ្ឋានក្នុងការវិភាគ។ រាល់ទិន្នន័យទាំងអស់ដែលយកមកវិភាគចេញមកពីកម្រងសំណួរចំនួន ១១សំណួរ ហើយសម្ភាសន៍លើអ្នកពាក់ព័ន្ធ ចំនួន ១៥០នាក់ នៅទីក្រុងភ្នំពេញ ចាប់ពី ខែ មិនា ឆ្នាំ ២០១៧ ដល់ ខែ មេសា ឆ្នាំ ២០១៧។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះចែកចេញជាបីជំពូកដូចជាៈ

ជំពូកទី១ៈ ទស្សនៈនៃការបង្កើនចំណូលបុគ្គល លើកយកចំនុចសំខាន់ៗមកបកស្រាយ ដូចជាៈ និយមន័យការអប់រំ ប្រាក់ចំណូលបុគ្គល អត្ថប្រយោជន៍ការអប់រំសម្រាប់លើកកម្ពស់ប្រាក់ចំណូល និងកត្តាពាក់ព័ន្ធដ៏ទៃផ្សេងទៀត។

ជំពូកទី២ៈ ករណីសិក្សាស្តីពីការអប់រំនៅកម្ពុជា លើយកចំណុចសំខាន់ៗដូចជាៈ ប្រវត្តិនៃការអប់រំនៅកម្ពុជា គោលនយោបាយអប់រំសម្រាប់ឆ្នាំ ២០១៤-២០១៨ និងកំណែទម្រង់វិស័យអប់រំនាពេលថ្មីៗនេះ។

ជំពូកទី៣ៈ ការវិភាគទិន្នន័យ បកស្រាយលទ្ធផលស្រាវជ្រាវតាមតារាង តាម Mean និងវិភាគគំរូប្រាក់ចំណូលបុគ្គល។

# ជំពូកទី ១
# ទស្សនៈនៃការបង្កើន
# ចំណូលបុគ្គល

# ជំពូកទី១

# ទស្សនៈនៃការបង្កើនចំណូលបុគ្គល

## ១.១ និយមន័យនៃពាក្យគន្លឹះ

ដើម្បីជាការងាយស្រួល និងមូលដ្ឋានក្នុងដំណើរការសិក្សាឱ្យកាន់តែមានប្រសិទ្ធភាពល្អ និងអាចវែកញែកបានត្រឹមត្រូវនោះ យើងគួស្វែងយល់នៃនិយមន័យនៃពាក្យគន្លឹះមួយចំនួនសិនដែលមានដូចជា ប្រាក់ចំណូលបុគ្គល និងការអប់រំ។

### ១.១.១ និយមន័យនៃពាក្យប្រាក់ចំណូលបុគ្គល ( Income )

**ប្រាក់ចំណូលបុគ្គល** គឺជាប្រាក់ឈ្នួលដែលត្រូវបានគណនាជាម៉ោង ជាថ្ងៃ ជាសប្តាហ៍ ជាខែ ឬជាការបំពេញការងារជាគោល។ ហើយនៅពេលដែលការងារណាដែលផ្តល់ប្រាក់ចំណូល ដែលមានលក្ខណៈជាខែ គេហៅថាប្រាក់ខែ[1]។

### ១.១.២ និយមន័យនៃពាក្យការអប់រំ ( Education )

**ការអប់រំ** គឺជាដំណើរការនៃការរៀនសូត្រ ការបង្រៀនដែលជាធម្មតាមាននៅតាម សាលារៀន វិទ្យាល័យ សាកលវិទ្យាល័យជាដើម[2] ។ ការអប់រំ បើនិយាយនៅក្នុងន័យទូទៅ គឺជាសំណុំទម្រង់នៃ ការរៀនសូត្រ ចំណេះដឹង អាកប្បកិរិយា ជំនាញ ដែលទទួលបានតាមរយៈ ការផ្ទេរពីក្រុមមនុស្ស ជំនាន់មួយទៅជំនាន់ក្រោយៗទៀត តាមរយៈសកម្មភាពបង្រៀន ការហ្វឹកហាត់ និងការស្រាវជ្រាវ នានាជាដើម។ ការអប់រំ ជាទូទៅ ធ្វើឡើងនៅក្រោមការណែនាំរបស់អ្នកដទៃ ប៉ុន្តែក៏អាចធ្វើឡើង តាមរយៈ ការធ្វើស្វ័យសិក្សាផងដែរ[3]។

## ១.២ អត្ថប្រយោជន៍នៃការអប់រំសម្រាប់លើកកម្ពស់ប្រាក់ចំណូល

ការរៀបចំប្រព័ន្ធអប់រំ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈបច្ចេកទេសនានា មានតួនាទីសំខាន់ណាស់ ក្នុងការចូលរួមលើកកម្ពស់ឯកទេសកម្មនៃកម្លាំងពលកម្ម។ កាលណាមនុស្សទទួលបានការអប់រំ និងការបណ្តុះបណ្តាលត្រឹមត្រូវ ពួកគេនឹងមានសមត្ថភាពខ្ពស់ជាងមុនក្នុងការធ្វើការងារអ្វីមួយ។ អត្ថប្រយោជន៍នៃការអប់រំសម្រាប់លើកកម្ពស់ប្រាក់ចំណូលមានបី៖ **ទីមួយ** ការអប់រំ អាចបង្កើនចំណេះដឹងបន្ថែមលើសមត្ថភាពយល់ដឹង បង្កើននូវផលិតភាព (Productivity)

[1] ដកស្រង់ចេញពីគេហទំព័រ៖http://www.businessdictionary .com/definition/wage.html

[2] មាននៅក្នុងវចនានុក្រម៖ Longman Dictionary of Contemporary English "Education"

[3] ដកស្រង់ចេញពីគេហទំព័រ៖ https://en.wikipedia.org/wiki/Education

ដើម្បីជំរុញកំណើន អៅភុត (Output) អោយដល់ចំណុចលំនឹង ហើយបុគ្គលិក ឬក៏កម្មករនឹងទទួលបាន ប្រាក់ចំណូលប្រសើរឡើងជាងមុន។ **ទីពីរ** ការអប់រំ អាចបង្កើនសមត្ថភាពក្នុងការច្នៃប្រឌិត (Creativity) ទាក់ទងនឹងការផលិតទំនិញ និងសេវាកម្ម។ **ទីបី** ការអប់រំ អាចធ្វើឱ្យមនុស្សមានភាពងាយស្រួលក្នុងការទទួលយកចំណេះដឹងពីប្រភពខាងក្រៅ និងចែករំលែកគ្នាទៅវិញទៅមក មានដូចជា ព័ត៌មាន បច្ចេកទេស និងបច្ចេកវិទ្យាថ្មីៗ យកមកអនុវត្ត ដើម្បីឈានទៅសម្រេចគោលដៅរបស់ខ្លួន[4] ។

## ១.៣ លទ្ធផលនៃការវិនិយោគពីការអប់រំ

នៅក្នុងបណ្តាលប្រទេសតតិយលោក បានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការវិនិយោគ លើវិស័យអប់រំជាទឹកប្រាក់យ៉ាងច្រើនសន្ធឹកសន្ធាប់។ ជាលទ្ធផល មានក្មេងៗជំនាន់ក្រោយ ភាគច្រើនបានចូលរៀន ក៏ប៉ុន្តែការសិក្សានោះ បន្តបានត្រឹមកម្រិតបឋមសិក្សាតែប៉ុណ្ណោះ។ តាមរយៈការសង្កេតនានាបានបង្ហាញថា ការឈប់រៀននេះគឺបណ្តាលមកពី កុមារឈានចូលដល់វ័យយុវជន (១៣ឆ្នាំឡើងទៅ) មានកម្លាំងពលកម្មគ្រប់គ្រាន់ អាចជួយរកចំណូលទ្រទ្រង់សេដ្ឋកិច្ចគ្រួសារ ដូចជា ជួយប្រកបរបរកសិកម្ម ឬរកការងារណាដែលពួកគេអាចធ្វើបាន។

ទោះបីរៀនបានទាបយ៉ាងណាក៏ដោយ គេសង្កេតឃើញថា មនុស្សដែលទទួលបានការសិក្សាអប់រំប្រកបដោយគុណភាពត្រឹមត្រូវ គឺអាចធ្វើការបានល្អ មានផលិតភាពខ្ពស់ជាងអ្នកដែលមិនធ្លាប់បានចូលរៀនសោះ។ ឧទាហរណ៍នៅក្នុងវិស័យកសិកម្ម កសិករដែលរៀនបានចប់បឋមសិក្សា អាច អាន សរសេរ និងគិតលេខ។ វាបានឆ្លើយតបនឹងលក្ខខណ្ឌ ការងាររបស់ពួកគេ និងថែម ទាំងស្វែងយល់ពីបច្ចេកទេសកសិកម្មបន្ថែមទាក់ទងនឹង ការប្រើប្រាស់ដី គ្រាប់ពូជ ជី ឬថ្នាំ សំលាប់សត្វល្អិតផ្សេងៗជាដើម។

នារយៈពេលចុងក្រោយនេះ តាមរយៈការវិវត្តន៍នៃការគិតរបស់ប្រជាជនភាគច្រើនមកលើ ការអប់រំ បានធ្វើឱ្យពួកគាត់សម្រេចចិត្តធ្វើការវិនិយោគលើការសិក្សារបស់កូនៗ ឱ្យរៀនបានថ្នាក់កាន់តែខ្ពស់តាមលទ្ធភាពដែលអាចធ្វើបាន ក្នុងក្តីសង្ឃឹមថាកូនៗ របស់ពួកគាត់ នឹងរួចចាកផុតពីភាពក្រីក្រ និងភាពល្ងង់ខ្លៅ។ ការអភិវឌ្ឍ និងកំណែទម្រង់លើវិស័យអប់រំមួយជំហានម្តងៗ បានផ្តល់ឱ្យប្រជាជនជាពិសេសយុវជន ទទួលបានឱកាសការងារល្អៗជាច្រើន។

[4]Eric Hanushek៖ គឺជាអ្នកជំនាញខាងសេដ្ឋកិច្ចជនជាតិអាមេរិកដែលគាំទ្រការពង្រឹងគុណភាពអប់រំ ដើម្បីជំរុញកំណើនសេដ្ឋកិច្ច៖ ព័ត៌មានបន្ថែមសូមចូលទៅកាន់គេហទំព័រ៖ https://en.wikipedia.org/wiki/Eric_Hanushek

ជាច្រើនឆ្នាំមកហើយ ចំណេះដឹងដែលទទួលបានតាមរយៈការចូលរៀន ត្រូវបានគេសម្គាល់ឃើញថាជាវិថីនៃក្តីសង្ឃឹមតែមួយគត់ ដើម្បីរួចចាកផុតពីភាពក្រីក្ររបស់ប្រជាជនទូទៅ ក៏ប៉ុន្តែដើម្បីធានានិរន្តភាពនេះបាន គឺគេមិនត្រូវបំភ្លេចជាដាច់ខាត អំពីការពង្រឹងគុណភាពអប់រំ (Todaro, Michael P; Smith, Stephen C; 2010) ។

## ១.៤ ប្រាក់ចំណូលបុគ្គល ( Personal Income )

មានទស្សនៈផ្សេងៗជាច្រើន ដែលជាប់ពាក់ព័ន្ធទៅនឹងប្រាក់ចំណូលដែលបានមកពីការងារ។ ទស្សនៈទាំងនោះមានដូចជា អត្រាប្រាក់ឈ្នួល ការរកចំណូល និងថ្លៃពលកម្ម។ ទស្សនៈទាំងអស់នេះមានលទ្ធផលនៃការប្រើប្រាស់ និងគោលដៅផ្សេងៗគ្នាដូចជា ប្រាក់ឈ្នួលត្រូវបានគេចាត់ទុកថាជាថ្លៃពលកម្មដែលបានមកពីការងារ ឬជាចំនួនប្រាក់បើកបានពីការងារ ឬជាថ្លៃឈ្នួលពលកម្ម។ ភាពជាប់ទាក់ទងទាំងនេះ ត្រូវបានធ្វើជាមូលដ្ឋានក្នុងទស្សនៈជាក់លាក់នៅគ្រប់ជាតិសាសន៍ទាំងអស់។ ទោះបីជាយ៉ាងណាក៏ដោយ ទស្សនៈទាំងអស់នេះគឺជាប់ទាក់ទងគ្នា និងត្រូវបានគេចាត់ទុកថានៅជាមួយគ្នា។

ជាទូទៅ ទស្សនៈនៃការបើកប្រាក់សំរាប់ការងារគឺជាប់ពាក់ព័ន្ធជាមួយចំនួនសាច់ប្រាក់ស្មើៗគ្នា (ប្រសិនអ្នកបើកប្រាក់មានចិត្តល្អ) ដែលវាត្រូវបានទទួលដោយបុគ្គល កំឡុងពេលដែលពួកគេចូល រួមសកម្មភាពសេដ្ឋកិច្ច។ កំឡុងពេលនៃការទទួលបានប្រាក់ចំណូលនោះ គឺមិនចាំបាច់ដូចជាពេល ធ្វើការងារនោះទេ។

ទស្សនៈនៃអត្រាប្រាក់ឈ្នួល គឺទាក់ទងទៅនឹងថ្លៃមូលដ្ឋាននៃឯកតាពលកម្ម ( Unit of Labor) មុនពេលបូកថែមប្រាក់បន្ថែមម៉ោងធ្វើការងារ ឬប្រាក់ឧបត្ថមក្រុមគ្រួសារ មុនពេលដកចេញនូវការផ្តល់ទៅគម្រោងសុវត្ថិភាពសង្គម និងការបង់ពន្ធ។ អត្រាប្រាក់ឈ្នួល អាចបង្ហាញពីឯកតាពេលដូចជា មួយម៉ោង មួយសប្តាហ៍ និងមួយខែ ជាប្រាក់ដែលត្រូវបង់សម្រាប់ការងារដែលបានធ្វើ។ នេះជាទស្សនៈនៃការបើកប្រាក់ឈ្នួលតូចបំផុតទៅកម្មករក្នុងការបង់ថ្លៃការងារតែមួយគត់។

ទស្សនៈនៃប្រាក់ចំណូល គឺជាប់ទាក់ទងនឹងការបើកប្រាក់ ដែលនិយោជក់ផ្តល់ទៅដល់និយោជិករបស់ពួកគេដោយផ្ទាល់លើមូលដ្ឋានជាក់លាក់ និងរយៈពេលពិតប្រាកដ។ វារួមបញ្ចូលទាំងការបើកប្រាក់សំរាប់ម៉ោងធ្វើការងារ ឬក៏ការងារដែលបានធ្វើរួចរាល់ហើយ ព្រមទាំងម៉ោងមិនធ្វើការងារដូចជា វិស្សមកាល ថ្ងៃឈប់សំរាក និងពេលមានជម្ងឺ។ ជាងនេះទៅទៀត វារួមបញ្ចូលទាំងការបើកប្រាក់ផ្សេងទៀតផងដែរ ដែលផ្តល់ដោយនិយោជក់តាមហេតុផលផ្សេងៗដូចជា៖ ការ

បន្ថែមម៉ោង ម៉ោងមិនចូលសង្គម ( Unsocial hours) ឬកាលវិភាគ ការងារពិបាក ប្រាក់បន្ថែមទៀងទាត់ និងប្រាប់បន្ទាប់បន្សំដូចជាការឧបត្ថមក្រុមគ្រួសារ។ ម៉្យាងវិញទៀត វាមិនរាប់បញ្ចូលគ្រប់ទាំងប្រាក់ បន្ថែមដែលមិនទៀងទាត់ ទោះបីជាផ្តល់ដោយនិយោជក់ក៏ដោយ។ ការរកចំណូលដូចជាអត្រាម៉ោង (Time Rate) ត្រូវចុះបញ្ជីសុវត្ថិភាពសង្គមសរុប ឬដកយកពន្ធ។

ទស្សនៈចំណូលជាប់ទាក់ទងនឹងការបើកប្រាក់ការងារ ដែលជារង្វាស់ទូលំទូលាយបំផុតនៃកម្រិតរង្វាន់នៃតំលៃការងាររបស់កម្មករ។ វារួមបញ្ចូលទាំងការបន្ថែមលើប្រាក់ចំណូល គ្រប់ទាំងការ បន្ថែមប្រាក់មិនទៀងទាត់ និងការបើកប្រាក់ ហើយនឹងអត្ថប្រយោជន៍សុវត្ថិភាពសង្គមដែលបានទទួលពីនិយោជក់ដោយផ្ទាល់ ឬពីគម្រោងសុវត្ថិភាពសង្គម ប្រសិនបើវាជាប់ទាក់ទងជាមួយការងារ។ ទាំងនេះរួមបញ្ចូលទាំងការ ឧបត្ថមក្រុមគ្រួសារ ការអប់រំ ជម្ងឺ និងប្រាក់ធានារ៉ាប់រងស្ត្រីនៅ ពេលមានកូន (maternity benefits) ។ វាក៏រួមបញ្ចូលទាំងអត្ថប្រយោជន៍ ដែលទទួលដោយបុគ្គលធ្វើការមិនមានរយៈពេលយូរក្នុងសង្គមដូចជា អត្ថប្រយោជន៍និកម្មភាព សោធននិវត្តន៍វ័យចាស់ និងអត្ថប្រយោជន៍ពេលពិការ។ អត្ថប្រយោជន៍សង្គមទាំងអស់នេះ នឹងក្លាយផ្នែកមួយនៃចំណូលដែល បានមកពីការបើកប្រាក់ការងារតែមួយគត់ ដែលកម្មករទទួលបានពីលទ្ធផលនៃការចូលរួមការងារ របស់ពួកគេ។ នៅក្នុងប្រទេសដែលមានប្រព័ន្ធសុវត្ថិភាពសង្គមទូទៅ ប្រាក់ឧបត្ថមក្រុមគ្រួសារ និងប្រាក់ឧបត្ថមដ៏ទៃផ្សេងទៀតមានឯករាជ្យក្នុងសកម្មភាពការងារ ការឧបត្ថមទាំងអស់នេះមិនមែនជា ផ្នែកមួយនៃចំណូលដែលបានពីការបើកប្រាក់ការងារនោះទេ។ ដើម្បីជៀសផុតពីការរាប់បញ្ចូល ពីរដងនូវអត្ថប្រយោជន៍ទាំងនេះ គេបានកត់ត្រានៅចំណូលសុទ្ធ (Net of Contributions) ដែលបង្កើតដោយកម្មករសម្រាប់គម្រោងសុវត្ថិភាពសង្គម។

ទស្សនៈថ្លៃពលកម្ម ជាប់ពាក់ព័ន្ធជាមួយតម្លៃពិតប្រាកដរបស់និយោជក់ដែលជួលកម្មករ។ វាមានសមាសភាគជាប្រាក់ចំណូល និងមិនមែនជាប្រាក់ចំណូល។ សមាសភាគប្រាក់ចំណូលវាស្រដៀងគ្នានឹងទស្សនៈនៃប្រាក់ចំណូលដែរ តែខុសគ្នានឹងប្រភេទនៃការបើកប្រាក់ វាជាប្រភេទដែលត្រូវបានគេចាត់ទុកជាវិធីសម្រាប់វាយតម្លៃ។ សមាសភាគដែលមិនមែនជាប្រាក់ចំណូល កើតមានឡើងលើការចំណាយដែលមានទំហំធំ ជាប់ទាក់ទងជាមួយវត្ថុ ដែលរួមជាមួយការបើកប្រាក់ទៅតាមប្រភេទកម្មករ ប៉ុន្តែវាត្រូវបានវាយតម្លៃពីគំនិតរបស់និយោជក់ថា ជាចំណាយដែលកើតមានឡើង។ ឧទាហរណ៍នៃប្រភេទវត្ថុទាំងនេះមានដូចជា ផ្ទះ អាហារដ្ឋាន មណ្ឌលថែរក្សាសុខភាព និងការចំណាយដែលស្រដៀងនឹងនេះ។ សមាសភាគទាំងនេះរួមបញ្ចូលទាំង វិភាគទាន

សុវត្ថិភាពសង្គម ការចំណាយ វគ្គបណ្តុះបណ្តាលវិស្សមកាល ពន្ធលើការងារ និងប្រាក់ខែដែលមិនមែនជាផ្នែកនៃការរកចំណូល។

ទស្សនៈនៃប្រាក់ចំណូលទាក់ទងជាមួយ ការងារដោយខ្លួនឯង ( Self Employment) ជាទស្សនៈ តែមួយគត់ដែលអាស្រ័យទៅនឹងការងារខ្លួនឯង។ វាគឺស្មើនឹងថ្លៃទំនិញ និងសេវាកម្មដែល ផលិតដោយផ្ទាល់ខ្លួន ការចំណាយប្រតិបត្តិការសរុប ( ដូចជា ការបើកប្រាក់ខែ ការប្រើប្រាស់វត្ថុធាតុដើម ការចុះថ្លៃម៉ាស៊ីន ឧបករណ៍ និងការបង់ពន្ធ) បូករួមនឹងប្រាក់ខែដែលទទួលបាន និងអត្ថប្រយោជន៍ សុវត្ថិភាពសង្គម (ការផ្តល់សរុប)។ ប្រាក់ចំណូលដែលទាក់ទងនឹងការងារខ្លួនឯង រួមបញ្ចូលទាំង អត្ថប្រយោជន៍ដែលទទួលបានពីការងាររបស់បុគ្គល ដែលធ្វើការមិនមានរយៈពេលយូរ ដូចជា អត្ថប្រយោជន៍និកម្មភាព សោធននិវត្តន៍វ័យចាស់ អត្ថប្រយោជន៍ពេលពិការ។ ប្រាក់ចំណូលដែលបានពីការងារ ដូចគ្រប់ទាំងអត្ថប្រយោជន៍ទាំងអស់នេះ នឹងជាផ្នែកមួយនៃចំណូលដែលបានមកពី ការងារផ្ទាល់ខ្លួន គ្រាន់តែជាកម្មករដែលទទួលបានផលពីការចូលរួមសកម្មភាពការងារប៉ុណ្ណោះ[5] ។

## ១.៥ ទីផ្សារពលកម្ម

**ទីផ្សារពលកម្ម** សំដៅទៅលើការផ្គត់ផ្គង់ និងតម្រូវការពលកម្ម ដែលកម្មករនិយោជិតជាអ្នក ផ្គត់ផ្គង់ពលកម្ម និងនិយោជក់ជាអ្នកមានតម្រូវការពលកម្ម [6] ។ ទីផ្សារពលកម្មចែកចេញជាពីរប្រភេទ គឺ តម្រូវការពលកម្ម និងការផ្គត់ផ្គង់ពលកម្ម។

### ១.៥.១ តម្រូវការពលកម្ម (Labor Demand):

ក៏ដូចជាផ្សារផ្សេងៗទៀតដែរ ផ្សារការងារ ឬពលកម្មត្រូវបានគ្រប់គ្រងដោយការផ្គត់ផ្គង់ និងតម្រូវការ។ ផ្សារពលកម្មខុសប្លែកច្រើនពីផ្សារផ្សេងៗទៀត ពីព្រោះតម្រូវការពលកម្ម គឺជាតម្រូវ ការមែកធាង (Derived Demand) ។ សេវាពលកម្មភាគច្រើនគឺជាមុខចូលសម្រាប់ការផលិតមុខ ទំនិញ ជាជាងមុខទំនិញបញ្ចប់ដែលបានធ្វើឱ្យអ្នកប្រើប្រាស់ពេញចិត្តនោះឡើយ (ទេព ស្វ រ៉ែន ២០១៧) ។

[5] ដកស្រង់ពីគេហទំព័រ៖ http://www.ilo.org/global/statistics-and-databases/statistics-overview-and-topics/income/lang--en/index.htm

[6] ដកស្រង់ចេញពីគេហទំព័រ៖ http://www.investopedia.com/terms/l/labor-market.asp

ដើម្បីយល់ដឹងបានពីតម្រូវការពលកម្ម យើងត្រូវផ្តោតការយកចិត្តទុកដាក់លើសហគ្រាសទាំងឡាយណាដែលជួលពលកម្ម និងប្រើប្រាស់វាដើម្បីផលិតមុខទំនិញសម្រាប់លក់។ តាមរយៈការពិនិត្យមើលតំណភ្ជាប់រវាងការផលិតទំនិញ និងតម្រូវការពលកម្មសម្រាប់ផលិតទំនិញទាំងនោះ យើងឈានទៅកំណត់អំពីប្រាក់ឈ្នួលតុល្យភាព (Equilibrium Wage)។

**១.៥.២ ការផ្គត់ផ្គង់ពលកម្ម** ( Labor Supply):

ដើម្បីវិភាគលម្អិតតម្រូវការពលកម្ម យើងត្រូវងាកមកពិនិត្យមើលជ្រុងមួយផ្សេងទៀតនៃផ្សារពលកម្មនោះគឺជ្រុងផ្គត់ផ្គង់។ ការផ្គត់ផ្គង់លេចកើតមានពីការដោះដូររបស់បុគ្គលទាំងឡាយរវាងការធ្វើការ និងលំហែ។ ខ្សែកោងផ្គត់ផ្គង់ពលកម្មចោតឡើងមានន័យថា មនុស្សឆ្លើយតបទៅនឹងការកើនឡើងប្រាក់ឈ្នួលដោយការធ្វើការច្រើនម៉ោងជាង និងលំហែតិចម៉ោងជាង (ទេព សូរ៉ន ២០១៧) ។

**១.៥.៣ តុល្យភាពនៅក្នុងផ្សារពលកម្ម** (Labor Market Equilibrium):

ប្រាក់ឈ្នួលដែលកំណត់នៅក្នុងផ្សារពលកម្មប្រកួតប្រជែងមានពីរ។ ទី១ ប្រាក់ឈ្នួលប្រែលទៅតាមតុល្យការនៃការផ្គត់ផ្គង់ និងតម្រូវការពលកម្ម។ ទី២ ប្រាក់ឈ្នួលស្មើនឹងតម្លៃនៃផលិតផល ម៉ាស៊ីណាល់ពលកម្ម។

ប្រាក់ឈ្នួល និងបរិមាណពលកម្មប្រែប្រួលស្របទៅនឹងផ្គត់ផ្គង់ និងតម្រូវការពលកម្ម។ នៅពេលផ្សារពលកម្មស្ថិតក្នុងតុល្យភាព សហគ្រាសនីមួយៗទិញពលកម្មក្នុងចំនួនដែលអាចចំណេញ នៅត្រង់ប្រាក់ឈ្នួលតុល្យភាព។ មានន័យថា សហគ្រាសនីមួយៗគោរពប្រតិបត្តិទៅតាមបទបញ្ញត្តិ សម្រាប់ប្រាក់ចំណេញអតិបរមា។ សហគ្រាសជួលពលកររហូតដល់តម្លៃផលិតផលម៉ាស៊ីណាល់របស់វាស្មើនឹងប្រាក់ឈ្នួល។ នៅពេលនោះ ការផ្គត់ផ្គង់ នឹងតម្រូវការពលកម្មគឺស្មើគ្នា។ ហេតុការណ៍ណាមួយដែលធ្វើឱ្យប្រែប្រួលការផ្គត់ផ្គង់ ឬតម្រូវការពលកម្ម ត្រូវតែធ្វើឱ្យប្រែប្រួល ប្រាក់ឈ្នួលតុល្យភាព និងតម្លៃនៃផលិតផលម៉ាស៊ីណាល់ពលកម្មក្នុងចំនួនដូចគ្នា ពីព្រោះវាត្រូវតែស្មើរគ្នា ជានិច្ច (ទេព សូរ៉ន ២០១៧)។

## ១.៦ ករណីសិក្សាកម្រិតអប់រំរបស់ប្រទេសមួយចំនួន ប្រទេសថៃ វៀតណាម និងសិង្ហបុរី

### ១.៦.១ ករណីសិក្សាប្រព័ន្ធអប់រំរបស់ប្រទេសសិង្ហបុរី

ប្រទេសសិង្ហបុរី ជាប្រទេសមួយនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលមានសេដ្ឋកិច្ចរីកចម្រើនខ្លាំងហើយមានការរីកចម្រើនខ្ពស់លើវិស័យអប់រំធនធានមនុស្ស។ ប្រទេសនេះមានផ្ទៃដីប្រមាណ

៧០៧.១គម² មានប្រជាជនប្រមាណ ៥,៣៥៣,៩៩៥នាក់ (២០១២)។ លើកត្តាប្រជាសាស្ត្រ សឹង្ហបុរី មានអត្រាកំណើន ស្មើនឹង ១.៩៩៣ភាគរយ(២០១២) អាយុជាមធ្យមមានដល់ ៨៣.៧៥ឆ្នាំ (២០១២) ដែល ៨១.៤៧ឆ្នាំ (បុរស) និង ៨៦.២ឆ្នាំ (ស្ត្រី)។ ផ្នែកសុខភិបាល អត្រាមរណៈភាពមាន ៣នាក់/១០០,០០០នាក់(២០១០) អត្រាមរណៈភាពកុមារមាន ២.៦៥/១០០០នាក់ (២០១២) និង អត្រាមរណៈភាពរបស់មាតាមាន ៣នាក់/១០០,០០០នាក់(២០១០)។ កត្តាសេដ្ឋកិច្ច ផលិតផលក្នុងស្រុកសរុប (GDP) ២៥៩,៨កោដដុល្លារ (២០១១) ផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់ (GDP Per capital) មាន ៦០,៥០០$ (២០១១)។ អត្រាកំណើន GDP ស្មើនឹង ៤.៩ភាគរយ (២០១១) បានតាម រយៈការចូលរួមពីវិស័យសេដ្ឋកិច្ចមាន៖ កសិកម្មស្មើនឹង ០ភាគរយ (២០១០) ឧស្សាហកម្មស្មើ ២៦.៦ ភាគរយ (២០១០) និងសេវាកម្ម ស្មើនឹង ៧៣.៤ភាគរយ (២០១០)។ ការចូលរួមពីកម្លាំងពលកម្មរួមមានចំនួន ៣.២៣៧លាននាក់ (២០១១) អត្រានិកម្មភាព ២ភាគរយ (២០១១)។ និយាយពីវិស័យសិក្សាអប់រំ ការសិក្សានៅថ្នាក់បឋមសិក្សាមានរយៈពេល ៦ឆ្នាំ ជាកាតព្វកិច្ច អត្រាអក្ខរភាពជា មធ្យមមាន ៩២.៥ភាគរយ(២០០០) ក្នុងនោះបុរសមាន ៩៦.៦ភាគរយ ស្ត្រីមាន ៨៨.៦ភាគរយ (ស៊ិន សុឃន និង សិក ឡុងហេង, ផ្នែកទី៨៖ ប្រទេសសិង្ហបុរី ខែតុលា ឆ្នាំ២០១២)។ **ព័ត៌មានទូទៅ (សូមមើលឧបសម្ព័ន្ធ១)**

### ១.៦.១.១ កត្តាដែលប្រទេសសិង្ហបុរីប្រឈម

មានផ្ទៃដីតូច ខ្វះធនធានធម្មជាតិ បានធ្វើឱ្យប្រទេសសិង្ហបុរី មានការពិបាកយ៉ាងខ្លាំងក្នុងការអភិវឌ្ឍប្រទេស។ ចំពោះធនធានវត្ថុធាតុដើម ត្រូវនាំចូលទាំងអស់ដើម្បីកែច្នៃ (ស៊ិន សុឃន និង សិក ឡុងហេង, ផ្នែកទី៨៖ ប្រទេសសិង្ហបុរី ខែតុលា ឆ្នាំ២០១២) ។

### ១.៦.១.២ កត្តាដែលសិង្ហបុរីយកចិត្តទុកដាក់

ស្ថិតនៅក្នុងលក្ខណ្ឌជាប្រទេសតូច និងខ្សត់ធនធានធម្មជាតិ រដ្ឋាភិបាលសិង្ហបុរី បានចាប់យកនូវគោលនយោបាយអភិវឌ្ឍន៍ មូលធនមនុស្សដែលមានគុណភាព ដើម្បីបម្រើក្នុងវិស័យសេវាកម្ម និងឧស្សាហកម្ម ចាប់តាំងពីបានឯករាជ្យពីប្រទេស ម៉ាឡេស៊ី នៅឆ្នាំ ១៩៦៥ ហើយធនធានមនុស្សក្នុងកម្លាំងពលកម្ម ត្រូវមានជំនាញវិជ្ជាជីវៈបច្ចេកទេស (ស៊ិន សុឃន និង សិក ឡុងហេង, ផ្នែកទី៨៖ ប្រទេសសិង្ហបុរី ខែតុលា ឆ្នាំ២០១២) ។

### ១.៦.១.៣ លក្ខខណ្ឌចំពោះគ្រូបង្រៀននៅប្រទេសសិង្ហបុរី

អាជីពជាគ្រូបង្រៀន ត្រូវបានគេឱ្យតម្លៃយ៉ាងខ្ពស់នៅក្នុងផ្នត់គំនិតរបស់ប្រជាជន។ ពួកគេត្រូវបានរដ្ឋាភិបាលគិតគូជាអាទិភាព ដោយរៀបចំអោយមានប្រាក់ខែ និងប្រាក់ឧបត្ថមបន្ថែមខ្ពស់។ បេក្ខជនដែលត្រៀមប្រឡងចូលធ្វើជាគ្រូបង្រៀន ត្រូវមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ព្រោះការប្រឡង មានស្តង់ដារក្នុងការជ្រើសរើសខ្ពស់ ដើម្បីធានាគុណភាពជាទីទុកចិត្តបាន ដែលទាមទារ បេក្ខជន ត្រូវមានសមត្ថភាពកម្រិតស្តង់ដារខ្ពស់ និងក្រមសីលធម៌វិជ្ជាជីវៈ ខ្ពស់ផងដែរ។ ក្រៅពីការ ពិនិត្យលើសមត្ថភាព បេក្ខភាពគ្រូបង្រៀន មិនត្រឹមតែជាអ្នកផ្តល់នូវចំណេះដឹងប៉ុណ្ណោះទេ ថែមទាំងជាគំរូដល់សិស្សផងដែរ[7] ។

ក្នុងចំណោមបេក្ខជនដែលប្រឡងទាំងអស់ ជាទូទៅ ត្រូវបានជ្រើសរើសយកតែមួយភាគបីប៉ុណ្ណោះ ក្នុងចំណោមបេក្ខជន ដែលមានពិន្ទុខ្ពស់ជាងគេ។ ក្រោយពេលជាប់ក្នុងការជ្រើសរើសហើយ បេក្ខជនត្រូវចូលរួមក្នុងដំណើរនៃវគ្គបណ្តុះបណ្តាល គ្រូបំប៉ន ហើយពួកគេអាចទទួលបានប្រាក់ខែ ដូចពេលចេញបង្រៀនដំបូងដែរ។ គ្រូបំប៉នទាំងអស់ត្រូវឆ្លងកាត់វគ្គបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំថែមទៀត (NIE)[8] ។ បន្ថែមពីនេះ លោកគ្រូអ្នកគ្រូនៅប្រទេសសិង្ហបុរី អាចបង្រៀនបណ្តើរ រៀនបន្តខ្លួនឯងបណ្តើរ ដើម្បីទទួលបានសញ្ញាប័ត្រអនុបណ្ឌិតឬសញ្ញាបត្រកម្រិតខ្ពស់ ផ្សេង ៗ បន្ថែមទៀត នៅពេលដែលបានបំពេញលក្ខណ្ឌវេលាកាលបង្រៀនរួច (ដែលតម្រូវបានចេញបង្រៀនបានយ៉ាងហោចណាស់ បីឆ្នាំសិន) ។

ក្រសួងអប់រំសិង្ហបុរី បានយកចិត្តទុកដាក់យ៉ាងខ្លាំងលើប្រាក់ខែគ្រូបង្រៀន តាមរយៈរបាយការណ៍របស់វិទ្យាស្ថានជាតិអប់រំ ដើម្បីធានាបានថា អាជីពជាគ្រូបង្រៀន នៅតែជាអាជីពមួយដែល មានការទាក់ទាញសម្រាប់និស្សិតដែលទើបនឹងបញ្ចប់ការសិក្សា។ គ្រូបង្រៀនដែលពូកែនៅមានការលើកទឹកចិត្តជាប្រាក់រង្វាន់បន្ថែមទៀត[9] ។

### ១.៦.១.៤ គោលយោបាយ

ដើម្បីធានាល្បឿនតាមទាន់ការអភិវឌ្ឍ គ្រូបង្រៀនត្រូវបានផ្តល់សិទ្ធិ ដើម្បីអភិវឌ្ឍសមត្ថភាព របស់ខ្លួនជាផ្លូវការចំនួន ១០០ម៉ោង ឥតគិតថ្លៃ។ ក្នុងកំឡុងពេលបង្រៀននោះ

[7] វិទ្យាស្ថានជាតិអប់រំ (សិង្ហបុរី)៖ពត៌មានបន្ថែមសូមចូលទៅកាន់៖www.nie.edu.sg/

[8] NIE=National Institute of Education=វិទ្យាស្ថានជាតិអប់រំ(សិង្ហបុរី)៖ពត៌មានបន្ថែមសូមចូលទៅកាន់៖ www.nie.edu.sg/

[9] វិទ្យាស្ថានជាតិអប់រំ (សិង្ហបុរី)៖ពត៌មានបន្ថែមសូមចូលទៅកាន់៖www.nie.edu.sg/

គ្រូបង្រៀនទាំងអស់ តម្រូវអោយចូលរួមជាប្រចាំជាមួយសមាភាពគ្រូៗដូចគ្នា ដើម្បីដោះដូរនូវយុទ្ធសាស្ត្របង្រៀនពីគ្នា ទៅវិញទៅមក។ ក្នុងឆ្នាំ ២០០៩ ការជួបប្រជុំគ្នានេះ ត្រូវបានណែនាំដោយក្រសួងអប់រំ តាមរយៈ ការបង្កើតជាសមាគមន៍សិក្សាវិជ្ជាជីវៈ (PLC)[10]។ ការដោះដូរគំនិតគ្នានេះ មិនមែនធ្វើឡើងត្រឹមកម្រិត ថ្នាក់ជាតិនោះទេ ក៏មានផងដែរ ការរៀបចំជាកិច្ចពិភាក្សាលក្ខណៈអន្តរជាតិ ជាមួយគ្រូបង្រៀនមកពីសាលារៀនល្បីៗ នៅតាមបណ្តាលប្រទេសដ៏ទៃជាដៃគូ (ដោយប្រើប្រាស់វីដេអូខនហ្វើរ៉េន ឬក៏ កម្មវិធី ស្កៃប ជាដើម) ។

ដូចគ្នានឹងអាជីពដ៏ទៃៗទៀត អាជីពជាគ្រូបង្រៀន ត្រូវបានវាយតម្លៃជាប្រចាំ លើសមត្ថភាព និងការអភិវឌ្ឍខ្លួន។ ការវង្វាយតម្លៃ នឹងឆ្លុះបញ្ចាំងពីលទ្ធផលមួយ ដើម្បីជាការដាស់តឿនឱ្យគ្រូ បង្រៀន ខំប្រឹងពង្រីកសមត្ថភាពខ្លួនបន្តទៀតឆ្លើយតបនឹងការរីកចម្រើននៃបច្ចេកវិទ្យា និងបន្តសហា ការគ្នាល្អ រវាងគ្រូ ឪពុកម្តាយសិស្ស និងក្រុមសហាគមន៍មិត្តរួមអាជីព។ ចំពោះគ្រូដែលពុំមានការអភិវឌ្ឍ ឬកែប្រែសមត្ថភាពខ្លួនឆ្លើយតបតាមតម្រូវការបានទាន់ពេលទេ ជាដំណោះស្រាយបឋម ពួកគេនៅ អាចទទួលបានជំនួយបន្ថែមពីអ្នកជំនាញ ឬក៏ត្រូវស្នើឱ្យឈប់បង្រៀនតែម្តង បើសិនពួកគេនៅតែ គ្មានការរីកចម្រើន[11] ។

ចំពោះគ្រូបង្រៀនដែលទើបចេញបង្រៀនដំបូង ត្រូវបានផ្តល់នូវការប្រឹក្សាយោបល់បន្ថែមក្នុងរយៈពេលពី ពីរទៅបីឆ្នាំ។ គ្រូបង្រៀនណាដែលមានសមត្ថភាព អាចមានឱកាសក្នុងការឈានទៅចាប់តំណែងជាថ្នាក់ដឹកនាំសាលា ឬមុខងារផ្សេងៗតាមជំនាញរបស់ខ្លួន ដូចជាបម្រើជាមន្ត្រីក្នុង គណៈកម្មាការ ឬប្រធានដេប៉ាតេម៉ង់សិក្សាលើមុខវិជ្ជាផ្សេងៗផងដែរ[12] ។

**១.៦.១.៥ ចំពោះថ្នាក់នាយក**

ចំពោះថ្នាក់ដឹកនាំសាលារៀនដែលមានសមត្ថភាពនិងបទពិសោធន៍ខ្ពស់ ពួកគេ នឹងត្រូវបាន ស្នើសុំជ្រើសរើសដើម្បីធ្វើបទសម្ភាសន៍ ក្នុងគោលបំណងចែករំលែកចំណេះដឹង និងយុទ្ធសាស្ត្រ ថ្មីៗ។ ការសម្ភាសន៍នេះ ត្រូវបានត្រួតពិនិត្យដោយវិទ្យាស្ថានជាតិអប់រំ។ ចំពោះនាយករូបណាដែល មានទស្សនៈវិស័យខ្ពស់ រួមនឹងយោបល់ល្អៗ ពួកគេ នឹងត្រូវបានស្នើដោយវិទ្យាស្ថានជាតិ

[10] PLC=Professional Learning Community=ជាប្រភេទសមាគមន៍មួយបែបដែលផ្តល់នូវឱកាសអោយអ្នកដែលមានអាជីព ដូចគ្នាចូលរួមសិក្សានិងចែករំលែកចំណេះដឹងគ្នាទៅវិញទៅមក។ ពត៌មានបន្ថែមសូមចូលទៅកាន់គេហទំព័រ៖ http://en.m.wikipedia.org/wiki/Professional_leaning_community

[11] វិទ្យាស្ថានជាតិអប់រំ (សិង្ហបុរី)៖ពត៌មានបន្ថែមសូមចូលទៅកាន់៖www.nie.edu.sg/

[12] វិទ្យាស្ថានជាតិអប់រំ (សិង្ហបុរី)៖ពត៌មានបន្ថែមសូមចូលទៅកាន់៖www.nie.edu.sg

អប់រំ ដើម្បីទទួលបាននូវការបណ្តុះបណ្តាលបន្ថែមលើ ភាពជាអ្នកដឹកនាំដោយមានរួមបញ្ចូលទាំងទស្សនៈកិច្ចសិក្សាជាអន្តរជាតិតាមប្រទេសដទៃ ដើម្បីចូលរួមក្នុងដំណើរការសិក្សាគម្រោង ស្វែងរកអ្វី ដែលថ្មីសម្រាប់សាលារៀន។ ជាទូទៅ ក្នុងមួយឆ្នាំៗ មាននាយកប្រហែល ៣០ ទៅ ៤០នាក់ត្រូវបានគេស្នើឱ្យចូលរួម ។

**១.៦.១.៦ កម្មវិធីសិក្សា**

កម្មវិធីសិក្សាក្នុងប្រព័ន្ធអប់រំនៅសិង្ហបុរី ជាទូទៅបានអនុវត្តដូចតទៅៈ

- ការបង្រៀននិងកម្មវិធីសិក្សា គឺយកភាសាអង់គ្លេសជាផ្លូវការ
- សិស្ស រៀននៅបឋមសក្សា មានរយៈពេល ៦ឆ្នាំ
- សិស្សរៀននៅមធ្យមសិក្សា មានរយៈពេល ៤ ទៅ ៥ ឆ្នាំ
- ស្តង់ដាថ្នាក់រៀន ស្រដៀងនឹងស្តង់ដា OECD[13] (ចាប់តាំងពីថ្នាក់ទី៩)

**តារាងទី១៖** ចំនួនសិស្សក្នុងថ្នាក់រៀន និងម៉ោងសិក្សាតាមមុខវិជ្ជានៃស្តង់ដារបស់ប្រទេសសិង្ហបុរី និងស្តង់ដារបស់ OECD

| ស្តង់ដាចំនួនសិស្សក្នុងមួយថ្នាក់រៀន | |
|---|---|
| ស្តង់ដាសិង្ហបុរី (នាក់) | ស្តង់ដា OECD (នាក់) |
| ៣៦ | ២៥ |

| ម៉ោងសិក្សា (ក្នុងមួយសប្តាហ៍) | | |
|---|---|---|
| មុខវិជ្ជា | ស្តង់ដាសិង្ហបុរី | ស្តង់ដា OECD |
| ខ្លឹមសារមេរៀនផ្សេងៗ | ៣ម៉ោង២១នាទី | ៣ម៉ោង៣៧នាទី |
| គណិតវិទ្យា | ៤ម៉ោង៥៤នាទី | ៣ម៉ោង៣៤នាទី |
| វិទ្យាសាស្ត្រ | ៤ម៉ោង២៧នាទី | ៣ម៉ោង២២នាទី |

ប្រភពទិន្នន័យ៖ (OECD 2013)

[13] OECD=Organization for Economic Co-operation and Development=គឺជាអង្គការមួយដែលមានការរៀបចំជាវេទិការ ពិភាក្សារិះរកវិធីសាស្ត្រដើម្បីលើកកម្ពស់កំណើនសេដ្ឋកិច្ច។ ពត៌មានបន្ថែមសូមចូលទៅកាន់គេហទំព័រ៖ http://usoecd.usmission.gov/mobibe//mission/overview.html

ក្រៅពីមុខវិជ្ជាសំខាន់ៗទាំងប៉ុន្មានខាងលើ ប្រទេសសិង្ហបុរី បានយកចិត្តទុកដាក់យ៉ាងខ្លាំងលើការបង្រៀនមុខវិជ្ជាសីលធម៌ពលរដ្ឋវិទ្យា ព្រោះវាជាយានក្នុងការចងភ្ជាប់ទំនាក់ទំនងល្អរវាងគ្នានឹងគ្នា យល់ពីតម្លៃនៃភាពស្មោះត្រង់ ឆន្ទៈ ក្នុងការប្តេជ្ញាចិត្តដើម្បីចូលរួមសហការអនុវត្តនូវវិស័យការគោរពច្បាប់ និងការកសាងមោទនភាពជូនជាតិមាតុភូមិ តាមរយៈការឱ្យតម្លៃលើការធ្វើការងារជាក្រុម។

### **១.៦.១.៧ សមិទ្ធផលដែលប្រទេសសិង្ហបុរីទទួលបានពីការរួមចំណែកនៃវិស័យអប់រំ**

តាមរយៈការពង្រឹងគោលនយោបាយអប់រំនេះ ជាលទ្ធផលប្រទេសសិង្ហបុរីទទួលបាន៖

- ជាប្រទេសដែលមានសេដ្ឋកិច្ចអភិវឌ្ឍន៍ខ្លាំងមួយ (នាគសេដ្ឋកិច្ចអាស៊ីអាគ្នេយ៍)
- ប្រជាជន មានជីវភាពធូរធារសម្បូរសប្បាយ
- លក្ខខណ្ឌងាយស្រួលរស់នៅ និងការអនុវត្តច្បាប់ ទាំងនេះក៏ដោយសារតែចំណេះដឹងសីលធម៌របស់ពលរដ្ឋប្រទេសមួយនេះខ្ពស់
- ទទួលបាននាមជាប្រទេសនៃស្ថានសួគ៌ការងារ
- ការទទួលបាននូវធនធានមនុស្សប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់ក្នុងការងារ
- មានសីលធម៌ និងការយល់ដឹងពីសង្គម ទូលំទូលាយ
- ក្នុងឆ្នាំ ២០០៩ សិស្សសិង្ហបុរី ជាសិស្សដែលជាប់ចំណាត់ថ្នាក់ខ្ពស់ (Top Scorers) នៅក្នុងកម្មវិធីវាយតម្លៃស្តង់ដាសម្រាប់សិស្សអន្តរជាតិ (PISA[14])(OECD 2013)។

## **១.៦.២ ករណីសិក្សាប្រព័ន្ធអប់រំរបស់ប្រទេសថៃ**

នៅក្នុងឆ្នាំ ១៩៣២ ការធ្វើបដិវត្តន៍ដោយគ្មានបង្ហូរឈាមមួយបានធ្វើឡើង។ បដិវត្តនេះគឺជាការផ្ទេរអំណាចទាំងអស់របស់ព្រះមហាក្សត្រទាំងអស់ ឱ្យទៅរដ្ឋាភិបាលតាមបែបប្រជាធិបតេយ្យ។ បន្ទាប់ពីរដ្ឋាភិបាលបែបលោកសេរីបានចាប់កំណើតឡើង ប្រទេសថៃបានយកចិត្តទុកដាក់លើការ ពង្រឹងនិងអភិវឌ្ឍន៍វិស័យអប់រំយ៉ាងសស្រាក់សស្រាំ ទាំងលើផ្នែកមធ្យមសិក្សា និងឧត្តមសិក្សា ហើយបន្តកសាងហេដ្ឋារចនាសម្ព័ន្ធ។ មកទល់នឹងបច្ចុប្បន្ន រចនាសម្ព័ន្ធនៃ

[14] [14] PISA=Programs for International Students Assessment=ជាស្តង់ដាលក្ខណៈអប់រំជាសាកលរបស់OECDដែលមាន ការទទួលស្គាល់ថាជាស្តង់ដាអប់រំសិស្សកម្រិតខ្ពស់៖ ព័ត៌មានបន្ថែមសូមចូលទៅកាន់គេហទំព័រ៖ http://en.m.wikipedia.org/wiki/Programme_for_International_Student_Assessment

ឋានានុក្រមកម្រិតអប់រំ បានអនុ វត្តតាមប្រព័ន្ធ ៦.៣.៣ ដូចនៅប្រទេសកម្ពុជាដែរ។ ចាប់តាំងពីឆ្នាំ ២០០១ ដល់ ២០០៦ លទ្ធផលបានបង្ហាញថា ប្រព័ន្ធអប់រំនៅប្រទេសថៃមានការរីកចម្រើនយ៉ាងខ្លាំង ទាំងលើវិស័យបច្ចេកទេស កុំព្យូទ័រនៅតាមបណ្ដាសាលារៀននានា និងការអភិវឌ្ឍសមត្ថភាពរបស់គ្រូបង្រៀន (ស៊ិន សុឃន និង សិក ឡុងហេង, ផ្នែកទី៨៖ ប្រទេសសិង្ហបុរី ខែតុលា ឆ្នាំ ២០១២) ។ ការអប់រំនៅប្រទេសជិតខាងកម្ពុជាមួយរយៈនេះ ត្រូវកំណត់មានរយៈពេល១២ ឆ្នាំ សម្រាប់ ស្តង់ដាអប់រំចំណេះទូទៅ ហើយជាផ្លូវច្បាប់ ការសិក្សាត្រូវមានរយៈពេល ៩ ឆ្នាំ ជាកាតព្វកិច្ច។ **ព័ត៌មានទូទៅបន្ថែម (សូមមើលឧបសម្ព័ន្ធ១)**

### ១.៦.២.១ ព័ត៌មានអប់រំសង្ខេបរបស់ប្រទេសថៃ

**តារាងទី២៖ បង្ហាញពីកម្រិតថ្នាក់សិក្សា និងប្រភេទអាយុសិក្សាតាមថ្នាក់នីមួយៗតាមប្រព័ន្ធអប់រំរបស់ប្រទេសថៃ**

| កម្រិត/ថ្នាក់ | ប្រភេទអាយុ(ឆ្នាំ) |
|---|---|
| **កម្រិតមត្តេយ្យ** | |
| • មត្តេយ្យ (កម្រិត ១) | ២ទៅ៣ |
| • មត្តេយ្យ (កម្រិត ២) | ៣ទៅ៥ |
| **បឋមសិក្សា** | |
| • Prathom 1 | ៦ |
| • Prathom 2 | ៧ |
| • Prathom 3 | ៨ |
| • Prathom 4 | ៩ |
| • Prathom 5 | ១០ |
| • Prathom 6 | ១១ |
| **អនុវិទ្យាល័យ និងវិទ្យាល័យ** | |
| • Matthayom 1 | ១២ |
| • Matthayom 2 | ១៣ |
| • Matthayom 3 | ១៤ |

| | |
|---|---|
| • Matthayom 4<br>• Matthayom 5<br>• Matthayom 6 | ១៥<br>១៦<br>១៧ |
| **ឧត្តមសិក្សា** | |
| មានរយៈពេលឬចំនួនឆ្នាំនៃការសិក្សា អាស្រ័យតាមមុខវិជ្ជា ភាគច្រើននៃមុខវិជ្ជារៀនរយៈពេល ៤ ឆ្នាំ | មិនកំណត់ច្បាស់លាស់ |

ប្រភពទិន្នន័យ៖ (Education in Thailand n.d. ឆ្នាំ ២០១៣)

**១.៦.២.២ សាកលវិទ្យាល័យល្បីៗនៅប្រទេសថៃ**

សាកលវិទ្យាល័យល្បីមួយឈ្មោះ ជូឡាឡុងកន បានជាប់ចំណាត់ថ្នាក់ទី ៤៦ នៅលើពិភពលោកកាលពីឆ្នាំ ២០០៤ ផ្នែកវិទ្យាសាស្ត្រសង្គម និងចំណាត់ថ្នាក់លេខ ៦០ លើផ្នែកវេជ្ជសាស្ត្រ។ ឆ្នាំ ២០០៦ មានសាកលវិទ្យាល័យ ៣ល្បីៗទៀត បានជាប់ចំណាត់ថ្នាក់ខ្ពស់ជាបន្ទាប់តាមរយៈ ការវាយតម្លៃក្នុង បេសកកម្មលើការអប់រំកម្រិតខ្ពស់ (Commission on Higher Education) ចំពោះការផ្តល់នូវស្តង់ដាអប់រំកម្រិតខ្ពស់ទាំងក្នុង ការអប់រំ និងវិធីសាស្ត្រស្រាវជ្រាវ។ ក្នុងនោះមានសាកលវិទ្យាល័យ៖

- សាកលវិទ្យាល័យ **ជូឡាឡុងកន** (Chulalon Korn University)
- សាកលវិទ្យាល័យ **ឈៀងម៉ៃ** (Chiang Mai University)
- សាកលវិទ្យាល័យ ម៉ាហ៊ីដុល (Mahidol University)

**១.៦.២.៣ ការអប់រំវិជ្ជាជីវៈបច្ចេកទេស**

ការអប់រំផ្នែកវិជ្ជាជីវៈបច្ចេកទេស ត្រូវបានប្រទេសថៃ យកចិត្តទុកដាក់យ៉ាងខ្លាំង។ បច្ចុប្បន្នមានមហាវិទ្យាល័យវិជ្ជាជីវៈប្រមាណ ៤១២ របស់រដ្ឋ និងរបស់ឯកជនមាន ៤០១។ កាលពីឆ្នាំ ២០០៤ ចំនួនសិស្សសិក្សាមានជាង ១លានបីសែននាក់។ កម្មវិធីសិក្សា គឺមានការបែងចែកតាំងពីថ្នាក់វិទ្យាល័យមក។

| |
|---|
| **តារាងទី៣៖** កម្រិតសញ្ញាបត្រអប់រំវិជ្ជាជីវៈបច្ចេកទេសនៅប្រទេសថៃ<br>ត្រូវបានបែងចែកជាបីប្រភេទ |

| | |
|---|---|
| កម្រិត ១ | សម្រាប់សិស្សដែលរៀនបានត្រឹមថ្នាក់ទី ៩ ពួកគេអាចបន្តរៀនយកវិញ្ញាបនបត្រ អប់រំវិជ្ជាជីវៈ ជាភាសាអង់គ្លេសហៅថា Certificate of Vocational Education ឬជាភាសាថៃហៅថា Bor Wor Saw. |
| កម្រិត ២ | សម្រាប់សិស្សដែលរៀនបានត្រឹមថ្នាក់ទី ១២ ពួកគេអាចបន្តរៀនយក សញ្ញាបត្រ ផ្នែកបច្ចេកទេស ជាភាសាអង់គ្លេសហៅថា Technical Diploma ឬជាភាសាថៃហៅថា Bor Wor Chor |
| កម្រិត ៣ | សម្រាប់សិស្សដែលរៀនចប់ថ្នាក់ទី១២ ពួកគេអាចបន្តរៀនយកសញ្ញាបត្រផ្នែកបច្ចេកទេសកម្រិតខ្ពស់ ឬជាភាសាអង់គ្លេសហៅថា Higher Technical Diploma dដែលនេះជាកម្រិតសិក្សាវិជ្ជាជីវៈបច្ចេកទេសមួយដូចនៅឧត្តមសិក្សាដែរ។ |

ប្រភពទិន្នន័យ៖ (Education in Thailand n.d. ឆ្នាំ ២០១៣)

### ១.៦.៣ ករណីសិក្សាប្រព័ន្ធអប់រំរបស់ប្រទេសវៀតណាម

ប្រទេសវៀតណាម គឺជាប្រទេសមួយនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ មានប្រជាជនប្រមាណ ៨៩លាននាក់ក្នុងឆ្នាំ ២០១២។ ទោះមានឈ្មោះជាប្រទេសកំពុងអភិវឌ្ឍន៍ មានប្រជាជនប្រមាណ ៨0ភាគរយ រស់នៅទីជនបទ ប៉ុន្តែអត្រាអ្នកចេះអក្សរនៅក្នុងប្រទេសអាស៊ីមួយនេះ មានរហូតដល់ ៩២ភាគរយ។ នៅក្នុងប្រព័ន្ធអប់រំផ្នែកចំណេះដឹងទូទៅក្នុងប្រទេសវៀតណាម នៅមានបញ្ហាមួយចំនួនទាក់ទងនឹង ស្តង់ដាអប់រំ គឺពុំទាន់ដល់កម្រិតខ្ពស់នៅឡើយ។ លើផ្នែកបរិក្ខារសម្ភារបង្រៀន មានលក្ខណៈចាស់ ពុំទាន់សម័យ ហើយបញ្ហាចំនួនគ្រូបង្រៀនវិញ គឺនៅមានការខ្វះខាតចំពោះធនធានគ្រូដែលមានសមត្ថភាព។ **ព័ត៌មានទូទៅ (សូមមើលឧបសម្ព័ន្ធ១)**

#### ១.៦.៣.១ ផ្នែកចំណេះដឹងទូទៅ និងឧត្តមសិក្សា

| **តារាងទី៤៖ រយៈពេលសិក្សាតាមកម្រិតថ្នាក់សិក្សានៅប្រទេសវៀតណាម** | |
|---|---|
| **ផ្នែកចំណេះដឹងទូទៅ** | |
| **ថ្នាក់/កម្រិត** | **រយៈពេលសិក្សា(ឆ្នាំ)** |
| ទារកដ្ឋាន (មត្តេយ្យកម្រិតទាប) | ៣ |

| | |
|---|---|
| មត្តេយ្យកម្រិតខ្ពស់ | ៣ |
| បឋមសិក្សា | ៥ |
| អនុវិទ្យាល័យ | ៤ |
| វិទ្យាល័យ | ៣ |
| **ផ្នែកឧត្តមសិក្សា** | |
| ថ្នាក់មហាវិទ្យាល័យ (College) | ៣ |
| ថ្នាក់សាកលវិទ្យាល័យ (University) | ៤-៦ |
| ថ្នាក់អនុបណ្ឌិត | ២ |
| ថ្នាក់បណ្ឌិត | ២-៤ |

**ប្រភពទិន្នន័យ៖** (ARAdim 2012)

### ១.៦.៣.២ ផ្នែកអប់រំវិជ្ជាជីវៈ

គោលនយោបាយអប់រំមួយផ្នែកទៀតនៃប្រទេសកុម្មុយនីស្តមួយនេះ គឺផ្តោតខ្លាំងលើការបណ្តុះបណ្តាលកម្មករជំនាញ។ ប្រព័ន្ធអប់រំនៅប្រទេសវៀតណាមចែកចេញជា៖

**តារាងទី៥៖** ផ្នែកអប់រំវិជ្ជាជីវៈបច្ចេកទេសនៅប្រទេសវៀតណាម ត្រូវបានគេបែងចែកជាបួនកម្រិត

| ការអប់រំ | រយៈពេល | កម្រិតចំណេះដឹង | អាយុ |
|---|---|---|---|
| កម្រិតបណ្តុះបណ្តាលវិជ្ជាជីវៈ បន្ទាប់ពីបញ្ចប់បឋមសិក្សា | ក្រោម ១ឆ្នាំ | អនុវិទ្យាល័យ | ១៣-១៤ ឆ្នាំ |
| កម្រិតបណ្តុះបណ្តាលវិជ្ជាជីវៈ បន្ទាប់ពីបញ្ចប់អនុវិទ្យាល័យ | ១ទៅ២ ឆ្នាំ | អនុវិទ្យាល័យ | ១៥ឆ្នាំ |
| កម្រិតបណ្តុះបណ្តាលជំនាញ | ៣ទៅ៤ឆ្នាំ | អនុវិទ្យាល័យ | ១៥ឆ្នាំ |
| កម្រិតបណ្តុះបណ្តាលជំនាញ វិជ្ជាជីវៈ | ៣ទៅ៤ឆ្នាំ | អនុវិទ្យាល័យ | ១៥ឆ្នាំ |

ប្រភពទិន្នន័យ៖ (ARAdim 2012)

# ជំពូកទី២

# ការណីសិក្សាស្តីពីការអប់រំ

# នៅកម្ពុជា

# ជំពូកទី២
# ករណីសិក្សាស្តីពីការអប់រំនៅកម្ពុជា

## ២.១ ប្រវត្តិការអប់រំ

យោងតាមប្រវត្តិសាស្ត្រនៃសម័យកាលអប់រំនីមួយៗ យើងសូមបង្ហាញជូនជាដំណាក់កាលដូចតទៅ៖

### ២.១.១ មុនសម័យអាណានិគមបារាំង (កំឡុងឆ្នាំ ១៨០០)

នៅក្នុងឆ្នាំ ១៨០០ ប្រព័ន្ធអប់រំបែបប្រពៃណី បានប្រព្រឹត្តឡើងតាមទីវត្តអារាមនៅតាមតំបន់ នីមួយៗ ដែលមានព្រះសង្ឃដើរតួនាទីជាគ្រូបង្រៀន។ កូនសិស្សដែលមកសិក្សាទាំងអស់សុទ្ធសឹង តែជាក្មេងប្រុសៗ។ ចំណេះដឹងដែលទទួលបានពីការអប់រំតាមបែបប្រពៃណី គឺមានកំណត់។ ការសិក្សាដែលផ្តល់ឱ្យសិស្ស គឺមានត្រឹមតែចេះ និងចងចាំនូវព្រះធម៌ជាភាសាបាលី ចេះអាន ចេះសរសេរអក្សរ និងមានបង្ហាត់បង្រៀនការងារមួយចំនួន ដែលទាក់ទងទៅនឹងជីវភាពរស់នៅ តាមជនបទរបស់ប្រជាជនខ្មែរតែប៉ុណ្ណោះ ដូចជាការងារ ជាងឈើធ្វើ តុ ទូ ជាដើម។ សិស្សភាគច្រើនត្រូវបួសជាសាមណេរដើម្បីរៀន។

ការអប់រំនៅកម្ពុជាតាមពិតទៅ មានដើមកំណើតដំបូងបង្អស់នៅកំឡុងសតវត្សទី៧ ហើយភាគច្រើនបានទទួលបានតែលើគ្រួសារអភិជនតែប៉ុណ្ណោះ (Dy, Sideth S 2010) ។

### ២.១.២ សម័យអានិគមបារាំង (១៨៦៣ ដល់ ១៩៥៣)

ប្រទេសបារាំង បានធ្វើអាណានិគមកិច្ចលើប្រទេសកម្ពុជា ចាប់តាំងពីឆ្នាំ ១៨៦៣មក ប៉ុន្តែការជួយផ្នែកវិស័យអប់រំ គឺមិនត្រូវបានបារាំងយកចិត្តទុកដាក់អភិវឌ្ឍន៍ឡើយ។ តាមរយៈឯកសារមួយរបស់លោក ស៊ីដេត ឌី (Sideth S.Dy) បានបញ្ជាក់ថា ការជួយអនុវត្តប្រព័ន្ធអប់រំតាមបែបទំនើប គឺអវត្តមានរហូតដល់ទសវត្សទី៩០។

មកទល់នឹងអំឡុងឆ្នាំ ១៩៩០ ប្រព័ន្ធអប់រំដែលផ្អែកលើមូលដ្ឋានគំរូបែបបារាំង បានចាប់ផ្តើមដើរទន្ទឹមគ្នានឹងប្រព័ន្ធអប់រំបែបប្រពៃណីផងដែរ។ អ្នកដែលមានជីវភាពធូរធារភាគច្រើន បានចូលរៀនតាមប្រព័ន្ធអប់រំបារាំង ហើយសិស្សដែលរស់នៅតាមទីជនបទ នៅបន្តសិក្សាតាមទីវត្តអារាមតាមបែបប្រពៃណីដដែល។ ក្នុងលក្ខខណ្ឌនៃការអប់រំបែបទំនើបដែលបារាំងផ្តល់មកកម្ពុជាគេ សង្កេតឃើញថា ត្រូវបានផ្តល់ឱ្យតែគ្រួសារណាដែលមានទ្រព្យសម្បត្តិច្រើន និងជាពិសេសដែល បម្រើដល់នយោបាយបារាំងទៀត។ នៅពេលវត្តមាននៃការអប់រំបែបទំនើប កាន់តែពង្រីក

ទូលំទូលាយទៅ សាលារៀនប្រពៃណីតាមទីវត្តអារាម នៅសល់តួនាទីគ្រាន់តែជាកន្លែងដែលអភិរក្សវប្បធម៌ខ្មែរប៉ុណ្ណោះ។ ស្របពេលនោះដែរ បារាំងមានចេតនាអាក្រក់មួយ គឺចង់លុបបំបាត់ឱ្យបាន នូវវប្បធម៌ខ្មែរផងដែរ។ នៅក្នុងសៀវភៅរបស់លោក វ៉ាន់ឌី កាអុន មួយបានបរិយាយថា នៅឆ្នាំ ១៩១៦ សាលារៀនតាមវត្តអារាម ត្រូវបានលុបបំបាត់ទាំងស្រុង (វ៉ាន់ឌីកាអុន ថ្ងៃទី៩ ខែតុលា ឆ្នាំ២០១២) ។

ភាពមិនអើពើអស់រយៈពេលយ៉ាងយូររបស់បារាំងចំពោះប្រព័ន្ធអប់រំនៅកម្ពុជា គឺជាចេតនារបស់ប្រទេសមហាអំណាចមួយនេះ ពីព្រោះនយោបាយលើកកម្ពស់ការអប់រំ អាចធ្វើឱ្យប្រជាជនខ្មែររួមកម្លាំងគ្នា រើបម្រាស់ពីនឹមអាណានិគមរបស់ពួកគេ។ យ៉ាងនេះក្ដី កំណែទម្រង់រយៈពេលចុងក្រោយក្នុងវិស័យអប់រំដែលបារាំងបានផ្ដល់ឱ្យខ្មែរ គេឃើញមានការផ្ដល់ឱកាសឱ្យកុមារី បានចូលរៀនក្នុងប្រព័ន្ធអប់រំតាមរយៈសាលារៀនជាផ្លូវការផងដែរ (Dy, Sideth S 2010) ។

### ២.១.៣ ប្រព័ន្ធអប់រំសម័យសង្គមរាស្ត្រនិយម (១៩៥៣ ដល់ ១៩៧០)

នៅចុងសម័យនៃអាណានិគម រដ្ឋាភិបាលអាណានិគមបារាំង ត្រូវបានអង្គការយូណេស្កូ ( UNESCO[15]) ស្នើឱ្យអនុវត្តជាដាច់ខាតនូវកាតព្វកិច្ច ធានាផ្ដល់នូវការអប់រំដល់ប្រជាជនកម្ពុជា អាយុចាប់ពី ៦ឆ្នាំ ដល់ ១៣ឆ្នាំ។ ក្រោយមក នៅពេលទទួលបានឯករាជ្យឆ្នាំ ១៩៥៣ ព្រះបាទនរោត្តម សីហនុ បានបន្តនូវនយោបាយអភិវឌ្ឍន៍ធនធានមនុស្សនេះបន្តទៀត។ ការផ្ដល់នូវឱកាស អប់រំនានា នាសម័យក្រោយឯករាជ្យ មានភាពទូលំទូលាយជាងមុន។ ប្រព័ន្ធអប់រំ ត្រូវបានរៀបចំឡើងតាំងពីកម្រិតបឋមសិក្សារហូតដល់ ថ្នាក់មហាវិទ្យាល័យ និងការអប់រំវិជ្ជាជីវៈបច្ចេកទេសថែម ទៀតផង។

មកទល់នឹងចុងទសវត្សឆ្នាំ៦០ មានសិស្សជាងមួយលាននាក់ បានចុះឈ្មោះចូលរៀន បើប្រៀបធៀបនឹងឆ្នាំ ១៩៦០ មាន ០.៦លាននាក់ និងឆ្នាំ ១៩៥០ មានត្រឹមតែ ០.១៣លាននាក់ប៉ុណ្ណោះ។ ចាប់ពីឆ្នាំ ១៩៦០ ដល់ឆ្នាំ ១៩៦៥ ការចុះឈ្មោះសម្រាប់សិស្សជានារី មានការកើនឡើង ពី ៩ ទៅ ៣៥ ភាគរយ។ តាមរយៈការអនុវត្តគោលនយោបាយអភិវឌ្ឍន៍មូលធនមនុស្សក្នុង

[15] UNESCO = United Nations Educational, Scientific, and Cultural Organization = គឺជាអង្គការអន្តរជាតិដែលជាបណ្ដាញ នៃអង្គការសហប្រជាជាតិទទួលបន្ទុកខាង ការងារអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌។ ព័ត៌មានបន្ថែមសូមចូលទៅកាន់គេហទំព័រ៖ http://en.wikipediaa.org/wiki/UNESCO

ទសវត្ស ទី៦០ ជាលទ្ធផលបានបង្ហាញថា ប្រទេសកម្ពុជាជាប្រទេសដែលមានអត្រាអក្ខរកម្ម និង ប្រព័ន្ធអប់រំ ខ្ពស់ជាងគេនៅអាស៊ីអាគ្នេយ៍នាសម័យនោះ (Dy, Sideth S 2010) ។

**២.១.៤ ស្ថានភាពអប់រំសម័យសាធារណៈរដ្ឋខ្មែរ** ( **១៩៧០ ដល់ ១៩៧៥** )

បន្ទាប់ពីមានរដ្ឋប្រហារទម្លាក់ព្រះបាទ នរោត្តម សីហនុ ពីអំណាច នៅថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៧០ ប្រទេសកម្ពុជាបានធ្លាក់ចូលក្នុងរណ្តៅនៃជម្លោះផ្ទៃកនយោបាយជាបន្តបន្ទាប់។ រដ្ឋាភិបាល សាធារណៈរដ្ឋខ្មែរ ដែលដឹកនាំដោយ លោកសេនាប្រមុខ លន់ នល់ និងព្រះអម្ចាស់ ស៊ីសុវត្ថិ សិរិមត: នាពេលនោះ មាននិន្នាការទៅរកប្រទេសលោកខាងលិច និងសហរដ្ឋអាមេរិក ដែលគោរព លទ្ធិប្រជាធិតេយ្យ។ រដ្ឋាភិបាលខ្មែរនាពេលនោះ បានធ្វើការទប់ទល់យ៉ាងខ្លាំង ជាមួយនឹងចលនា កុំមុយនិស្ត ដែលមានឥទ្ធិពលយ៉ាងខ្លាំងក្លានៅភាគខាងកើត នឹងតាមទីជនបទ។ មានគ្រូបង្រៀន សិស្ស និស្សិតជាច្រើន បានចូលរួមជាមួយចលនាខ្មែរក្រហមកុំមុយនីស្ត ហើយបាតុកម្ម ក៏កើតមាន ជាហូរហែរនៅទីក្រុងភ្នំពេញ។ នៅដើមឆ្នាំ ១៩៧២ សង្គ្រាមមនោគមវិជ្ជា បាននាំប្រទេសកម្ពុជាឱ្យ ធ្លាក់ចូលក្នុងសង្គ្រាមស៊ីវិល។ នៅតាមតំបន់ជនបទភូមិភាគខាងកើត សហរដ្ឋអាមេរិកបានទម្លាក់ គ្រាប់បែកជាច្រើន ដើម្បីបន្ថយឥទ្ធិពលនៃការសាយភាយនៃលទ្ធិកុំមុយនីស្ត ដែលទង្វើនេះបានបង្ក នូវការបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធនៅកម្ពុជាជាច្រើន រួមទាំងហេដ្ឋារចនាសម្ព័ន្ធអប់រំផងដែរ (Dy, Sideth S 2010) ។

**២.១.៥ ការអប់រំសម័យកម្ពុជាប្រជាធិបតេយ្យ** ( **១៩៧៥ ដល់ ១៩៧៩** )

នាសម័យកាលនោះ ប្រទេសកម្ពុជាកំពុងស្ថិតក្នុងសម័យមួយដ៏ខ្មៅងងឹត គឺរបបប្រល័យពូជសាសន៍ ដែលដឹកនាំដោយលោក សាឡុត សរ ហៅ ប៉ុល ពត។ បដិវត្តន៍ជាពាក្យស្លោកមួយ ដែល ប្រជាជនខ្មែរជំនាន់មុន ភាគច្រើននូវចងចាំមិនអាចបំភ្លេចបាន **"មហាអស្ចារ្យ មហាលោតផ្លោះ"** របស់មេដឹកនាំផ្តាច់ការរូបនេះ បានលុបបំបាត់ចោលនូវទ្រព្យសម្បត្តិឯកជន ប្រព័ន្ធអប់រំ សាលារៀន សង្គមវិជ្ជា វប្បធម៌ ហើយបង្ខំឱ្យប្រជាជន ចាកចោលផ្ទះសំបែង ទៅរស់នៅទីជនបទស្រុកស្រែចំការ ក្នុងជំរុំជាមួយទាហាន ដោយធ្វើការងារកសិកម្មបែបសមូហភាព។ ការអប់រំផ្លូវការត្រូវបានលប់បំបាត់ចោល ហើយប្រជាជនទាំងអស់ ត្រូវបង្ខំឱ្យធ្វើការយ៉ាងជំណំនៅក្នុងរោងចក្រ និងកសិដ្ឋាន។ ការលប់បំបាត់ចោលប្រព័ន្ធអប់រំ គឺនៅមិនគ្រប់គ្រាន់សម្រាប់រដ្ឋាភិបាល ប៉ុល ពត ឡើយ។ គេនៅ ឃើញមានការបាត់បង់ធនធានមនុស្ស ជាពិសេសក្រុមបញ្ញាវន្តអស់ជាង បីភាគ

ប្អូនរបស់ខ្មែរ តាមរយៈការសម្លាប់ និងមួយចំនួនបានរត់គេចខ្លួនទៅប្រទេសក្រៅ (Dy, Sideth S 2010) ។

## ២.១.៦ ប្រព័ន្ធអប់រំសម័យសាធារណៈរដ្ឋប្រជាមានិតកម្ពុជា (១៩៧៩ ដល់ ១៩៨៩)

ក្រោយពីសម័យខ្មែរក្រហមបានដួលរលំនៅឆ្នាំ ១៩៧៩ គឺត្រូវបានជំនួសមកវិញដោយរបបមួយថ្មី ដែលដឹកនាំដោយសម្តេច ហេង សំរិន ( សព្វថ្ងៃលោកជាប្រធានរដ្ឋសភាជាតិកម្ពុជា)។ ពីឆ្នាំ ១៩៧៩ ដល់ ឆ្នាំ ១៩៨១ ការកសាងឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធ បានធ្វើឡើងយ៉ាងសស្រាក់សស្រាំង។ ការកសាងជាតិផ្តើមចេញពីឆន្ទៈរបស់រដ្ឋាភិបាលសម័យនោះ រួមជាមួយនឹងការសហការពីដៃគូអភិវឌ្ឍន៍ដូចជា អង្គការយូណេសេហ្វ ( UNECEF[16]) និងកាកបាទក្រហមអន្តរជាតិ ( International Red-Cross[17]) គេឃើញមាននូវការកសាងស្ថាប័នអប់រំឡើងវិញចំនួន ៦,០០០ ស្ថាប័ន ហើយគ្រូបង្រៀនរាប់សែននាក់ ត្រូវបានបណ្តុះបណ្តាលឡើងវិញនូវដំណាក់កាលដំបូង។ នាសម័យកាលនោះ សកម្មភាពចំពោះវិស័យអប់រំ គឺច្រើនផ្តោតតែលើផ្នែកកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត។ គេឃើញមានថ្នាក់រៀនជាច្រើនត្រូវបានបង្កើត តែក៏នៅមានសិស្សមួយចំនួនត្រូវរៀនតាមលក្ខណ្ឌ ដែលអាចទៅរួចផងដែរ ដូចជារៀនទៅក្រៅអគារ (Open-air Classroom) និងរៀននៅក្រោមដើមឈើជាដើម។

ការខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការកសាងប្រទេសមកទល់នឹងឆ្នាំ ១៩៨៩ គេឃើញមានកំណើននៃការចុះឈ្មោះចូលរៀនថ្នាក់បឋមសិក្សារហូតដល់ ១.៣លាននាក់ និងថ្នាក់អនុវិទ្យាល័យរហូតដល់ ០.២៩លាននាក់ ធៀបជាមួយនឹងឆ្នាំ ១៩៨០ ដែលសិស្សបឋមសិក្សាមាន ០.៩ លាននាក់ និងសិស្សអនុវិទ្យាល័យមានត្រឹម ៤,៨០០នាក់ នេះបើយោងតាមតួលេខក្រសួងអប់រំយុវជន និងកីឡា កាលពីឆ្នាំ ១៩៩៩។ នាពេលនោះមានសិស្សចំនួន ៣០ភាគរយ គ្មានឪពុក ១០ភាគរយ គ្មានម្តាយ និងចន្លោះពី ៥ទៅ១០ ភាគរយជាក្មេងកំព្រា (Dy, Sideth S 2010)។

---

[16] UNICEF= United Nations International Children's Emergency Fund= ជាអង្គការអន្តរជាតិធ្វើការដើម្បីកុមារ និងការពារសិទ្ធិកុមារ មាននៅតាមបណ្តាលប្រទេសជាង ១០៩ នៅលើពិភពលោក។ ព័ត៌មានបន្ថែមសូមចូលទៅកាន់គេហទំព័រ៖ http://www.unicef.org.uk/UNICEFs-Work/

[17] International Red-Cross= គឺជាចលនានៃសកម្មភាពជាលក្ខណៈអន្តរជាតិ ក្នុងន័យមនុស្សធម៌ជួយដល់សុខមាលភាព រស់នៅរបស់ប្រជាជនដែលជួបការលំបាក។ ព័ត៌មានបន្ថែមសូមចូលទៅកាន់គេហទំព័រ៖ http://en.m.wikipedia.org/wiki/International_Red_Cross_and_Red_Crescent_Movement

រហូតមកដល់បច្ចុប្បន្ន ប្រព័ន្ធអប់រំចំណេះទូទៅនៅកម្ពុជា បានអនុវត្តតាមប្រព័ន្ធ ៦-៣-៣ គឺមានរយៈពេល ៦ឆ្នាំសម្រាប់បឋមសិក្សា ៣ឆ្នាំសម្រាប់អនុវិទ្យាល័យ និង៣ឆ្នាំសម្រាប់វិទ្យាល័យ។ សម្រាប់ថ្នាក់ឧត្តមសិក្សា និស្សិតដែលរៀនមុខវិជ្ជាបម្រើក្នុងវិស័យរដ្ឋបាល សេវាកម្ម និងគ្រប់គ្រង ត្រូវសិក្សារយៈពេល ៤ឆ្នាំ សម្រាប់ថ្នាក់បរិញ្ញាបត្រ ឬក៏លើសពី ៤ឆ្នាំ សម្រាប់មុខវិជ្ជាបច្ចេកទេស ស៊ីជម្រៅមួយចំនួនដូចជា ស្ថាបត្យកម្ម វិស្វករ វេជ្ជបណ្ឌិត ជាដើម។

## ២.២ ស្ថានភាពទូទៅនៃការអប់រំនាពេលបច្ចុប្បន្ន

នៅចំណុចនេះ យើងនឹងធ្វើការរៀបរាប់អំពីសកម្មភាព ដែលសម្រេចបានតាមរយៈការអនុវត្តគោលនយោបាយអប់រំទៅតាមអនុវស័យនីមួយៗ៖

### ២.២.១ អនុវិស័យមត្តេយ្យសិក្សា

ផ្អែកលើរបាយការណ៍របស់ក្រសួងអប់រំ គិតក្នុងឆ្នាំ ២០១៤ កុមារដែលមានអាយុ ៥ឆ្នាំ មានចំនួន ៥៩.៩ភាគរយ បានចូលរៀនក្នុងកម្មវិធីអប់រំកុមារតូច នេះបើធៀបនឹងឆ្នាំសិក្សា ២០០៨-២០០៩ ដែលមានត្រឹមតែ ៣៥ភាគរយប៉ុណ្ណោះ។ ចំពោះកុមារស្ថិតក្នុងអាយុចន្លោះពី ៣-៤ឆ្នាំ បានចូលរៀន ២០.៥ភាគរយ។ ចំណែកឯការទទួលបានសេវាអប់រំចំពោះកុមារតូចគិតត្រឹមអាយុ ០-៣ ឆ្នាំ សម្រេចបាន ៣.៧៨ភាគរយ។ តាមរយៈគោលនយោបាយអប់រំនានាកន្លងមក ការពង្រីកចំនួនសាលាមត្តេយ្យសិក្សារបស់រដ្ឋមានចំនួន ៣,១៨៤ មត្តេយ្យសិក្សារបស់ឯកជនមានចំនួន ៤០៣ និងមត្តេយ្យសិក្សាសហគមន៍មានចំនួន ២,២២០ សរុបទាំងអស់មានចំនួន ៥,៨០៧។

យ៉ាងនេះក្តី ចំនួនមត្តេយ្យសិក្សានៅមានកម្រិតនៅឡើយដោយសារតែកង្វះធនធានរូបវន្ត និងផ្នែកហិរញ្ញវត្ថុ ព្រមទាំងបុគ្គលិកដែលមានសមត្ថភាព។

តម្រូវការ និងគុណភាពនៃសេវាអប់រំនៅកម្រិតនេះ នៅមានគម្លាតគ្នាឆ្ងាយ រវាងទីតាំងភូមិសាស្ត្រមួយទៅតាមភូមិសាស្ត្រមួយទៀត ជាពិសេសនៅតំបន់ ដែលមានការចូលរៀននៅបឋមសិក្សា មានកម្រិតទាប និងអត្រាបោះបង់ការសិក្សាខ្ពស់។ អនុវិស័យនេះបាន ផ្តោតការយកចិត្តទុកដាក់តិចតួច លើបញ្ហាអាហារូបត្ថម្ភ ការគាំពារ និងសុខភាពរបស់កុមារតូចៗ។ ក្នុងពេលបច្ចុប្បន្ន ក្របខណ្ឌធានាគុណភាព នៅមិនទាន់បានរៀបចំនៅឡើយ ហើយមានតែគ្រូមត្តេយ្យសិក្សានៅសាលាសាធារណៈប៉ុណ្ណោះ ដែលបានឆ្លងកាត់ការបណ្តុះបណ្តាល ចំនែកឯគ្រូមត្តេយ្យសិក្សាសហគមន៍ និងក្រុមម្តាយបង្គោលនៃកម្មវិធីអប់រំកុមារតូចតាមផ្ទះ-តាមខ្នងផ្ទះ បានទទួលការបំប៉ន តិចតួច រីឯសម្ភារៈរៀន និងការបង្រៀននៅមានកម្រិត។

អន្តរាគមន៍លក្ខណៈជាគោលនយោបាយ ក្នុងអំឡុងឆ្នាំ ២០០៩-២០១៣ កន្លងមក គឺជាមូលដ្ឋានគ្រឹះ សម្រាប់ការឈានទៅបង្កើនគុណភាពនៃសេវាអប់រំកុមារតូចនៅឆ្នាំ ២០១៨។ មូលដ្ឋានគ្រឹះទាំងនោះ មានដូចជា ការរៀបចំគោលនយោបាយជាតិ និងផែនការសកម្មភាពជាតិ ស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច ការរៀបចំឱ្យមានប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃផ្នែកលើលទ្ធផលសម្រាប់ចក្ខុវិស័យអប់រំកុមារតូចក្នុងគោលបំណងលើកកម្ពស់គុណភាពអប់រំ តាមរយៈការ ពង្រឹងទំនាក់ទំនងការងារជាមួយក្រសួងពាក់ព័ន្ធដ៏ទៃទៀត ស្របតាមគោលនយោបាយវិមជ្ឈការ និងសហវិមជ្ឈការ ពីថ្នាក់ជាតិដល់ថ្នាក់ឃុំ-សង្កាត់ និងជួយសម្របសម្រួលដល់ការចែករំលែក ធនធាននិងការទទួលខុសត្រូវ (ក្រសួងអប់រំ យុវជន និងកីឡា, អប់រំកុមារតូច គ្មានថ្ងៃ), (ណាត ប៊ុនរឿន ២០១៤) ។

### ២.២.២ អនុវិស័យបឋមសិក្សា

គិតមកដល់ត្រឹមឆ្នាំ ២០១៤ ចំនួនកុមារដែលបានចូលរៀននៅបឋមសិក្សា កាន់តែច្រើន។ ជាក់ស្តែង ចំនួនសាលាបឋមសិក្សាបច្ចុប្បន្នមាន ៦,៩៩៣ អត្រាពិតនៃការសិក្សា[18] បានកើនទៅដល់ ៩៨.១ ភាគរយ និងគ្មានគម្លាតយេនឌ័រ។ អត្រាត្រួតថ្នាក់ និងសិស្សបោះបង់ការសិក្សា ក៏បានថយចុះផងដែរ។ បច្ចុប្បន្ន សាលាបឋមសិក្សាណា ដែលមានស្តង់ដាមិនគ្រប់កម្រិតត្រូវបានបន្ថែមបន្ទប់ រៀន ដើម្បីក្លាយជាសាលាគ្រប់កម្រិត។ លើសពីនេះ ឧបករណ៍សម្រាប់វាយតម្លៃការសិក្សារបស់សិស្ស ត្រូវបានរៀបចំ និងបង្ហាញថា ការសិក្សារបស់សិស្ស បានល្អប្រសើរជាងមុន ជាពិសេស មុខវិជ្ជាភាសាខ្មែរនៅកម្រិតថ្នាក់ដំបូង។

និយាយពីនយោបាយចំពោះការអប់រំពីរភាសាវិញ គឺកំពុងត្រូវបានរៀបចំ និងពង្រីកជាមួយគ្នា និងនយោបាយពន្លឿនគុណភាពអប់រំ។ រាជរដ្ឋាភិបាល ត្រៀមរៀបចំឱ្យមានការសិក្សា លើកម្មវិធីភាសាអង់គ្លេស ចាប់ពីថ្នាក់ទី៤ នាពេលឆាប់ៗនេះ។ លើផ្នែកអាហារូបករណ៍ មានប្រមាណ ១៥,០០០កន្លែង ត្រូវបានផ្តល់ដល់សិស្សនៅបឋមសិក្សានានា ជាពិសេសលើសិស្សដែលក្រីក្រ។ ថវិកាកែលម្អសាលារៀន ត្រូវបានផ្តល់ជូនសាលាបឋមសិក្សាប្រមាណ ៦០០ ហើយក្នុងនោះ គ្រូបង្រៀនជាច្រើននាក់ ត្រូវបានបំពាក់បំប៉នអំពី ប្រសិទ្ធភាពនៃការរៀន និងបង្រៀន។ តួនាទីរបស់ការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ មានសារៈសំខាន់ណាស់ក្នុងការគាំទ្រដល់

[18] **អត្រាពិតនៃការសិក្សា៖** ជាចំនួនកុមារ ឬសិស្សទាំងឡាយណាដែលបានចូលរៀនក្នុងកម្រិតសិក្សាណាមួយ ក្នុងកំណត់អាយុតាមកម្រិតសិក្សានោះគិតជាភាគរយនៃចំនួនប្រជាជនតាមក្រុមអាយុនោះ

ប្រសិទ្ធភាពនៃការផ្តល់សេវាអប់រំ។ ថ្នាក់ដឹកនាំក្រសួង បានបែងចែកឱ្យមានជាក្រុមបំប៉ន និង ពិនិត្យតាមដានថ្នាក់ ក្រុង ស្រុក ខណ្ឌ ផ្តល់ជារបាយការណ៍ ដើម្បីបានជាព័ត៌មានក្នុងការផ្តល់ការ គាំទ្រ បានទាន់ពេលវេលាដល់សាលារៀន។ ចំពោះគ្រូឧទ្ទេសបង្គោលថ្នាក់ជាតិ ត្រូវបានបង្កើត ឡើង ដើម្បីជួយដល់ក្រុមបំប៉ន ពិនិត្យតាមដានថ្នាក់ ក្រុង ស្រុក ខណ្ឌ និងសាលារៀន។ ជាមួយគ្នា នេះ តួនាទីរបស់មាតាបិតា និងសហគមន៍ក្នុងការគ្រប់គ្រងសាលារៀន ត្រូវបានពង្រឹង ដើម្បី បង្កើនការសហការគ្នាល្អ ក្នុងដំណើរការអភិវឌ្ឍសមត្ថភាព និងកិរិយាមាយាទរបស់សិស្ស។ ចំពោះការបំពេញ ការងារជាគ្រូបង្រៀនវិញ ត្រូវបានធ្វើការពិនិត្យតាមដាន និងវាយតម្លៃជាទៀង ទាត់។

ការអប់រំបឋមសិក្សា ត្រូវបានចាត់ទុកជាអាទិភាពមួយ ដែលទទួលបាននូវចំណែកថវិកា ច្រើនជាងគេ ក្នុងថវិកាសរុបរបស់ក្រសួងអប់រំ យុវជន និងកីឡា។ ការផ្តល់ហិរញ្ញប្បទានសម្រាប់ បឋមសិក្សា បានបន្តស្ថិតនៅជាអាទិភាពទៅទៀត។ មានដៃគូអភិវឌ្ឍន៍ជាច្រើន បានបន្តការគាំទ្រ ជាហិរញ្ញវត្ថុ និងបច្ចេកទេស សម្រាប់អនុវិស័យនេះដូចជា "ថវិកាភាពជាដៃគូអប់រំនិងបង្កើតជាកម្ម វិធីមួយ" ការគាំទ្ររបស់ភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ ស៊ុយអែត (Sida) ក្នុងការផ្តល់ជាថវិកាកែលម្អ សាលារៀន ជំនួយជាថវិកាពីសហគមន៍អឺរ៉ុប ព្រមទាំងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនទៀត (ក្រសួងអប់រំ យុវជន និងកីឡា, បឋមសិក្សា n.d,) , (ណាត ប៊ុនរឿន ២០១៨)។

### ២.២.៣ អនុវិស័យអប់រំមធ្យមសិក្សាចំណេះទូទៅ និងការអប់រំបច្ចេកទេស

នាពេលបច្ចុប្បន្ន ស្ថានភាពនៃការអប់រំថ្នាក់មធ្យមសិក្សា មានការរីកចម្រើនបង្គួរ។ លើផ្នែក ហេដ្ឋារចនាសម្ព័ន្ធ គេឃើញមានអនុវិទ្យាល័យចំនួន ១,២៥៥ និងវិទ្យាល័យចំនួន៥៥៥។ ប្រព័ន្ធ វិក្រឹតការគ្រូបង្រៀនលើមុខវិជ្ជាគណិតវិទ្យានិងវិទ្យាសាស្ត្រ ក៏ត្រូវបានរៀបចំឡើងផងដែរ។ ចំពោះ កម្មវិធីបំណិនជីវិត បច្ចេកវិទ្យា ព័ត៌មាន និងទេសចរណ៍ ត្រូវបានអនុម័តហើយ ស្តង់ដានបណ្ណាល័ យ នៅមធ្យមសិក្សា កំពុងរៀបចំជាសេចក្តីព្រៀង។ ក្នុងរយៈពេលចុងក្រោយនេះ គេសង្កេតឃើញ ថា អត្រាត្រួតថ្នាក់បានថយចុះតិចតួច ប៉ុន្តែអត្រាបោះបង់ការសិក្សា គឺមិនមានប្រែប្រួលទេ។ តាមរ យៈ តួលេខថ្មីៗនេះបានបង្ហាញសិស្សភាគច្រើន បានជ្រើសរើសយកមុខវិជ្ជា វិទ្យាសាស្ត្រពិត។ ចំពោះ ផ្នែកអាហារូបករណ៍ គឺនៅតែបន្តផ្តល់ជូនរៀងរាល់ឆ្នាំដដែល។ ក្នុងការប្រកួតប្រជែងសិស្ស ពូកែ ក្នុងព្រឹត្តិការណ៍នានាវិញ ប្រទេសកម្ពុជា បានបញ្ជូនសិស្សឱ្យទៅចូលរួមប្រឡងផងដែរ

ហើយជា លទ្ធផល ពួកគេបានទទួលមេដាយលើមុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រ ពីកម្មវិធីដូចជាការប្រកួតស៊ីមេអូអូឡាំព្យាដ និងកម្មវិធីប្រកួតអន្តរជាតិផ្សេងៗ។

ចំពោះការប្រឡងថ្នាក់ជាតិនៅថ្នាក់ទី ៩និងទី១២ ត្រូវបានអនុវត្តជាទៀងទាត់តាមឆ្នាំសិក្សា។ តាមរយៈតួលេខរបស់ក្រសួងអប់រំ បានបង្ហាញបន្ថែមទៀតថា ចំនួនអនុវិទ្យាល័យ និងវិទ្យាល័យបានកើនឡើងជាលំដាប់ ក្នុងនោះមានសាលាមធ្យមសិក្សាបឋមភូមិ ៥០ភាគរយ បានអភិវឌ្ឍន៍ទៅជាសាលាមធ្យមសិក្សាទុតិយភូមិ។ នាពេលបច្ចុប្បន្ននេះ នៅតាមសាលាមធ្យមសិក្សាបឋមភូមិចំនួន ១៩១ ក្នុងខេត្ត៨ មានបន្ទប់កុំព្យូទ័រ។ ការអនុវត្តប្រព័ន្ធបណ្ដុះបណ្ដាល និងវិក្រឹតការគ្រូបង្រៀន ជាពិសេសគ្រូបង្រៀនកម្រិតអប់រំមូលដ្ឋាន នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងវិទ្យាស្ថានជាតិអប់រំ កំពុងត្រូវបានពង្រីក។ ចំពោះការងារលើវិក្រឹតការលើមុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រ ក៏កំពុងត្រូវបានពង្រីកផងដែរ។ បន្ថែមពីនេះ ចំពោះថ្នាក់ដឹកនាំ នាយកសាលាមធ្យមសិក្សាទុតិយភូមិទាំងអស់ និងនាយកសាលាមធ្យមសិក្សាបឋមភូមិមួយចំនួន បានទទួលការបំប៉នស្ដីពី ការគ្រប់គ្រង និងដឹកនាំ ហើយប្រធានក្រុមបច្ចេកទេស និងមជ្ឈមណ្ឌលធនធាននៅមធ្យមសិក្សា និងបណ្ដាញទាំងអស់ ក៏បានទទួលការបំប៉ន ស្ដីពីស្ដង់ដាកម្មវិធីសិក្សាផងដែរ។

ចំពោះមធ្យមសិក្សាទុតិយភូមិ គោលនយោបាយសាលាមេត្រី ត្រូវបានអនុវត្តនៅសាលាមធ្យមសិក្សាចំនួន ៨២៣ ដែលស្មើនឹង ៥០.៧៥ភាគរយ នៃសាលាមធ្យមសិក្សាបឋមភូមិទាំងអស់នៅកម្ពុជា។ បញ្ហាប្រឈមនៅតាមសាលាមធ្យមសិក្សា ភាគច្រើនពិសេសនៅតំបន់ជនបទ គឺនៅមានភាពខ្វះខាតធាតុចូលរួមដែលមានគុណភាពដូចជា គ្រូបង្រៀនតាមមុខវិជ្ជា សម្ភារៈបង្រៀន និង គ្រឿងបរិក្ខារ សៀវភៅសិក្សាគោល បន្ទប់ពិសោធវិទ្យាសាស្ត្រ បន្ទប់កុំព្យូទ័រនិងភាសា និងបរិក្ខារ បណ្ណាល័យជាដើម។ ចំណែកឯវិធីសាស្ត្រក្នុងការបង្រៀនក្នុងពេលបច្ចុប្បន្ន គឺនៅអនុវត្តតាមរបៀប ជាមេរៀន ចម្លងតាម ដកស្រង់ និងការចងចាំ។ វិធីសាស្ត្រទាំងនេះ គួរត្រូវបញ្ចូលនូវការគិត និងជំនាញវិភាគឱ្យបានច្រើន ទើបមានការរីកចម្រើន។

កំឡុងឆ្នាំ ២០០៩-២០១៣ សកម្មភាពគោលនយោបាយស្ដីពីការអប់រំនៅមធ្យមសិក្សា និងការអប់រំបច្ចេកទេស ត្រូវបានរៀបចំឡើងជាច្រើនដូចជា ផែនការគោលស្ដីពីការអភិវឌ្ឍមធ្យមសិក្សា និងកែលម្អកម្មវិធីសិក្សា។ នាពេលបច្ចុប្បន្ន ការអប់រំបច្ចេកទេស ជាមុខងារថ្មីមួយដែលក្រសួង ទើបនឹងបានអនុម័ត។ ក្នុងគោលនយោបាយនេះបានលើកឡើងពី ការបង្កើតវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស នៅគ្រប់រាជធានី និងខេត្ត។ កម្មវិធីអប់រំបច្ចេកទេស ដែលកំពុង

អនុវត្តនាពេល បច្ចុប្បន្ន មានកង្វះទាំងក្របខណ្ឌគុណភាពដ៏រឹងមាំ និងធាតុចូលដែលមានគុណភាព។ ប្រព័ន្ធទទួល ស្គាល់និងប្រព័ន្ធធានាគុណភាពសាលារៀនមិនទាន់បានបង្កើត ព្រមទាំងទំនាក់ទំនងរវាងប្រព័ន្ធ អប់រំនិងទីផ្សារការងារនៅមានកម្រិត។ ប្រព័ន្ធគ្រប់គ្រង រដ្ឋបាលនិងហិរញ្ញវត្ថុសាលារៀនក៏មិនទាន់ បង្កើត ចំណែកឯការងារអប់រំបច្ចេកទេស គឺចាំបាច់ត្រូវដកបទពិសោធ ពីប្រទេសដ៏ទៃ។

នាពេលបច្ចុប្បន្ន មានសាលាមធ្យមសិក្សាចំណេះទូទៅនិងបច្ចេកទេស ចំនួន៣កំពុងដំណើរការ និងផ្តល់មុខវិជ្ជាសំខាន់បួន មានសិស្សសរុបចំនួន ៦៥៣នាក់ ក្នុងនោះស្រី ២៣៨នាក់ (ឆ្នាំសិក្សា ២០១៣-២០១៤)។ សិស្សដែលបញ្ចប់ការសិក្សានៅសាលាទាំងនេះ អាចរកការងារបាន។ ការអភិវឌ្ឍលើការអប់រំចំណេះវិជ្ជាជីវៈ ត្រូវបានគេសម្លឹងឃើញថាមានផលប្រយោជន៍ និងដើរតួនាទីយ៉ាងសំខាន់ ក្នុងការធ្វើឱ្យមានកំណើនសេដ្ឋកិច្ចស្របពេលដែលកម្ពុជាបច្ចុប្បន្ន កំពុងខ្វះខាតកម្លាំងពលកម្មជំនាញ និងចំពេលដែលសមាហរណកម្មអាស៊ានបានចូលមកដល់។ ការអភិវឌ្ឍលើអនុវិស័យអប់រំប្រភេទមួយនេះ ក៏មានដៃគូអភិវឌ្ឍន៍ជាច្រើនបានចាប់អារម្មណ៍គាំទ្រផងដែរ (ក្រសួងអប់រំ យុវជន និងកីឡា n.d), (ណាត ប៊ុនរឿន ២០១៤)។

### ២.២.៤ អនុវិស័យឧត្តមសិក្សា

ក្នុងកំឡុងឆ្នាំ២០០៩-២០១៣ ការអប់រំនៅឧត្តមសិក្សា មានការរីកចម្រើនគួរឱ្យកត់សម្គាល់។ អគ្គនាយកដ្ឋានឧត្តមសិក្សា និងគ្រឹះស្ថានឧត្តមសិក្សា បានអភិវឌ្ឍន៍សមត្ថភាពរបស់ខ្លួន ក្នុងការងារ កសាងផែនការ និងពិនិត្យតាមដាន ការគ្រប់គ្រងមូលនិធិស្រាវជ្រាវ អាហារូបករណ៍ និងមាន លទ្ធភាពទាញយកមូលនិធិកាន់តែច្រើន។ គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំកម្ពុជា មាន សមត្ថភាពខ្ពស់ ក្នុងការគ្រប់គ្រងដំណើរការប្រព័ន្ធទទួលស្គាល់គុណភាព។ វប្បធម៌នៃការស្រាវជ្រាវ បានចាប់ផ្តើមផុសឡើងតាមរយៈការអនុវត្តកម្មវិធីផ្តល់មូលនិធិស្រាវជ្រាវ និងមានកិច្ចសហប្រតិបត្តិ ការក្នុងតំបន់រឹងមាំ តាមរយៈការបង្កើតក្រុមការងារបច្ចេកទេស ចូលរួមក្នុងវេទិការជជែកនិងពិភាក្សាអំពីបញ្ហានៅកម្រិតឧត្តមសិក្សា។

បញ្ហាប្រឈមចម្បងសម្រាប់ឆ្នាំខាងមុខនេះគឺជា ការដោះស្រាយពីភាពខុសគ្នារវាងតម្រូវការទីផ្សារការងារ ជាពិសេសលើគុណភាព និងតម្រូវការកម្លាំងពលកម្មជំនាញ។ កត្តានេះទាមទារឱ្យមានការយល់ដឹងកាន់តែប្រសើរឡើងអំពីទីផ្សារការងារ ការសម្របសម្រួលល្អប្រសើរជាមុន

ជាមួយនឹងវិស័យឧស្សាហកម្ម សេវាកម្ម និងផ្តលព័ត៌មានកាន់តែប្រសើរឡើងសម្រាប់និស្សិត ទើបពួកគេអាចជ្រើសរើសវគ្គសិក្សាបានសមស្រប។

គិតមកទល់នឹងឆ្នាំ ២០១៤ ចំនួនគ្រឹះស្ថានឧត្តមសិក្សាសរុបទាំងអស់មានចំនួន ១០៥ ដែល មាននៅក្នុងរាជធានី-ខេត្តទាំង១៩ នៃព្រះរាជាណាចក្រកម្ពុជា។ តួលេខបានបង្ហាញថា ក្នុងចំណោម គ្រឹះស្ថានឧត្តមសិក្សាទាំងអស់មានគ្រឹះស្ថានចំនួន ៣៩ជារបស់រដ្ឋ និងចំនួន ៦៦ជារបស់ឯកជន។ ក្រៅពីនេះគ្រឹះស្ថានអប់រំជាន់ខ្ពស់មួយចំនួនទៀតដែលនៅសេសសល់គឺមាន ៦៥ស្ថិតនៅក្រោមការ គ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា ៤០ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួង-ស្ថាប័ន ១៣ផ្សេងៗទៀត។ យោងតាមតួលេខបច្ចុប្បន្ន និស្សិតដែលកំពុងសិក្សាសរុបមានចំនួន ២៥៣,៧៦៤នាក់ ស្រី៤០.១២ភាគរយ ក្នុងនោះមាននិស្សិតបរិញ្ញាបត្ររងចំនួន ២៤,៣៥០ នាក់ ស្រីមានចំនួន ៣៥.៨ភាគរយ និស្សិតជាប់អាហារូបករណ៍មានចំនួន ៩,១០៣នាក់ ស្រី ៣៧.២៩ភាគរយ និស្សិតបរិញ្ញាបត្រមានចំនួន ២២៩,៤១៤នាក់ ស្រី ៤០.៥៨ភាគរយ និស្សិតជាប់អាហារូបករណ៍ មានចំនួន ២៨,៣៤៨នាក់ ស្រី ៣៦.៤៦ភាគរយ និស្សិតដែលប្រឡងបញ្ចប់ការសិក្សាមានចំនួន ៤៨,៥៤៩នាក់ ស្រីចំនួន ៤០.៦ភាគរយ។ ការពង្រឹងគុណភាពគ្រឹះស្ថានឧត្តមសិក្សាមានចំនួន ៩៣ (ក្រសួងអប់រំ យុជន និងកីឡា, ឧត្តមសិក្សា n.d ), ណាត ប៊ុនរឿន ២០១៤)។

## ២.៣ គោលនយោបាយអប់រំឆ្ពោះទៅ ឆ្នាំ ២០១៤-២០១៨

### គោលនយោបាយទី១៖ ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌

កុមារគ្រប់រូបបានទទួលសេវាអប់រំកុមារតូចតាចតាមគ្រប់រូបភាព បានចូលរៀននៅបឋមសិក្សា មធ្យមសិក្សា និងមានឱកាសបន្តការសិក្សាទៅមុខទៀត។ សម្រាប់កុមារដែលកំពុងមានលទ្ធភាពចូលរៀនក្នុងប្រព័ន្ធ ជម្រើសផ្សេងទៀតនឹងត្រូវផ្តល់លទ្ធភាពឱ្យអ្នកទាំងនោះទទួលបានការអប់រំ។

ការបង្កើនចំនួនកុមារ និងយុវជន ឱ្យទទួលបានការអប់រំនៅគ្រប់កម្រិតដោយផ្តោតលើសមធម៌ និងតំបន់ និងក្រុមកុមារជួបការលំបាក។ ការបង្កើនឱកាសដល់សិស្សដែលបញ្ចប់ការសិក្សានៅថ្នាក់ទី១២ ឱ្យទទួលបាននូវចំណេះដឹង នឹងជំនាញក្នុងការគិតហេតុផល និងអាចជាមូលដ្ឋានសម្រាប់បន្តការសិក្សា នៅក្នុងការបណ្តុះបណ្តាលបច្ចេកទេស និងឧត្តមសិក្សាតទៅទៀត។

### គោលនយោបាយទី២៖ លើកកម្ពស់គុណភាពនិងភាពឆ្លើយតប

កុមារនិងយុជនគ្រប់រូបមានបទពិសោធក្នុងការសិក្សា ប្រកបដោយគុណភាព និងភាពឆ្លើយ តបដែលអាចឱ្យពួកគេអាចចូលរួមចំណែកដល់ការអភិវឌ្ឍប្រទេសជាតិ។ ការធានាថា ការអប់រំ ប្រកបដោយគុណភាព និងមានទំនាក់ទំនងទៅនឹងគោលដៅអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេស។ ក្របខណ្ឌគុណភាពដែលផ្តល់ដល់អ្នកសិក្សា មាតាបិតា សហគមន៍ គ្រូបង្រៀន និងអ្នកគ្រប់គ្រងជាមួយនឹងស្តង់ដានៃផលសម្រេច ការពិនិត្យតាមដាននិងរបាយការណ៍។

**គោលនយោបាយទី៣៖ ធានាភាពស័ក្តសិទ្ធនៃភាពជាអ្នកដឹកនាំនិងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់**

ការផ្តល់សេវាអប់រំនឹងត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពនិងទន់ភ្លន់។ ការគ្រប់គ្រងដោយប្រសិទ្ធភាពនិងវិជ្ជាជីវៈនឹងផ្តល់នូវតម្លៃដ៏ល្អបំផុត (ផ្តោតលើលទ្ធផល) ទាន់ពេវេលា ការពិនិត្យតាមដានរបាយការណ៍នូវលទ្ធផលនិងយោបល់ត្រឡប់ វិធានការណ៍ប្រកបដោយគណនេយ្យ ភាព និងយន្តការសម្រាប់កែលម្អគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធី ទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ក្រោមជាតិ។ ការគ្រប់គ្រងគ្រឹះស្ថានសាធារណៈ នឹងអាចឆ្លើយតបយ៉ាងមានប្រសិទ្ធភាពទៅនឹងតម្រូវការជាក់ស្តែងនៅកម្រិតសាលារៀន។ តាមរយៈការអនុវត្តគោលនយោបាយទាំងបី ខាងលើនេះរាជរដ្ឋាភិបាល ព្យាករណ៍ថានឹងសម្រេចបានលទ្ធផលដូចតទៅ៖

| តារាងទី៦៖ សូចនាករស្នូលនៃគោលនយោបាយដែលបានដាក់ចេញ | | |
|---|---|---|
| សូចនាករស្នូល | ស្ថានភាពបច្ចុប្បន្ន ២០១២-១៣ | ចំណុចដៅ ២០១៧-១៨ |
| **គោលនយោបាយទី១៖ ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌** | | |
| ១-ភាគរយកុមារអាយុ៥ឆ្នាំក្នុងការអប់រំកុមារតូចគ្រប់រូបភាព | ៥៦.៥ភាគរយ | ៨០ភាគរយ |
| ២-ចំនួនស្រុកដែលបានសម្រេចអត្រាបញ្ចប់បឋមសិក្សាយ៉ាងតិ៨០ភាគរយ | ១១៩ស្រុក | ១៤៥ស្រុក |
| ៣-ចំនួនខេត្តដែលបានសម្រេចអត្រាបញ្ចប់មធ្យមសិក្សាបឋមសិក្សាយ៉ាងតិច៤០ភាគរយ | ៧ខេត្ត/ក្រុង | ១៧ខេត្ត/ក្រុង |
| **គោលនយោបាយទី២៖ លើកកម្ពស់គុណភាពនិងភាពឆ្លើយតប** | | |
| ៤-អត្រាអក្ខរកម្មយុវជន(អាយុ ១៥-២៤) | ៩១.៥ភាគរយ | ៩៧.៥ភាគ |

| | | |
|---|---|---|
| | | រយ |
| ៥-អត្រាអក្ខរកម្មជនពេញវ័យ(អាយុ ១៥ឆ្នាំ-៤៥ឆ្នាំ | ៨៧.០៥ភាគរយ | ៩០.៥ភាគរយ |
| ៦-ការវាយតម្លៃថ្នាក់ជាតិលទ្ធផលសិក្សារបស់សិស្សថ្នាក់ទី៣, ទី៦ និងទី៨ លើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា | កំពុងអនុវត្តថ្នាក់ទី៣ | អនុវត្តថ្នាក់ទី៨ |
| ៧-ចំនួនគ្រូបង្រៀនឧត្តមសិក្សាមានបរិញ្ញបត្រជាន់ខ្ពស់ | ៦,៣១១នាក់ | ៧,៣១១នាក់ |
| ៨-ចំនួនគ្រូបង្រៀនមានសញ្ញាបត្របណ្ឌិត | ៨០៨នាក់ | ១,០៥៨នាក់ |
| **គោលនយោបាយទី៣៖ ធានាភាពស័ក្តសិទ្ធនៃភាពជាអ្នកដឹកនាំនិងគ្រប់គ្រងរបស់មន្ត្រីអប់រំ គ្រប់លំដាប់ថ្នាក់** | | |
| ៩-ភាគរយថវិការកម្មវិធីធៀបនឹងថវិកាសរុបក្រសួងអប់រំ យុវជន និងកីឡា | ១៣.៦៩ភាគរយ (២០១៣) | ១០០ភាគរយ |
| ១០-ភាគរយការទូទាត់ចំណាយថវិកាកម្មវិធី | ៨៦.៧ភាគរយ | ១០០ភាគរយ |

**ប្រភពទិន្នន័យ៖ (ស្ទូចនាករស្នូល ក្រសួងអប់រំ យុវជន និងកីឡា២០១៤)**

**សម្រាប់ផែនការគោលនយោបាយអប់រំតាមអនុវិស័យ២០១៤-១៨ (សូមចូលទៅកាន់ឧបសម្ព័ន្ធទី២)**

## ២.៤ កំណែទម្រង់វិស័យអប់រំនាពេលថ្មីៗនេះ

### ២.៤.១ វិធានការណ៍ចំពោះថ្នាក់មធ្យមសិក្សា

ក្រសួងអប់រំ យុវជននិងកីឡា សហការជាមួយស្ថាប័នមានសមត្ថកិច្ចមានគម្រោងចុះរឹបអូស យកសៀវភៅសិក្សាគោល ដែលមានស្លាក "**ហាមលក់**" និងស្លាក '**កម្មសិទ្ធរបស់រដ្ឋ**' នៅលើក្រប ដែលបានអនុវត្តកាលពីថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៤ (ឯម មាយ ២០១៤)។ ការលក់សៀវភៅ កម្មសិទ្ធរដ្ឋទាំងនេះគឺខុសច្បាប់ ហើយអាជីវករមិនត្រឹមតែមិនទទួលការទូទាត់ប្រាក់សំណង ពីក្រសួងទេ តែត្រូវប្រឈមមុខនឹងការដាក់ទោសតាមច្បាប់ជាធរមានថែមទៀត។

គួរបញ្ជាក់ដែលថា ធនាគារអភិវឌ្ឍន៍អាស៊ីដែលបានផ្តល់ជំនួយ ១,៣៤៦,០០០ដុល្លា សម្រាប់ ការបោះពុម្ព និងចែកចាយសៀវភៅសិក្សាគោលកម្រិតមធ្យមសិក្សា នៅតាមសាលា ក្នុង

ឆ្នាំ ២០១២ ដល់ ២០១៣[19] ហើយទង្វើនេះជាការបង្ហាញអំពីសុឆន្ទៈជំហានដំបូង ក្នុងការធ្វើកំណែទម្រង់ពិតប្រាកដមួយឆ្ពោះទៅរកភាពប្រសើរលើកំណែទម្រង់វិស័យអប់រំ។ (**សេចក្តីប្រកាសរបស់ក្រសួង សូមមើល 'សេចក្តីជូនដំណឹងរឹបអូសសៀវភៅ' ក្នុងឧបសម្ព័ន្ធ២)**

ក្នុងពិធីបើកសន្និបាតបូកសរុបការងារក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា ២០១២-២០១៣ និងទិសដៅឆ្នាំសិក្សា ២០១៣-២០១៤ ឯកឧត្តម ហង់ ជួនណារ៉ុង រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានអះអាងថានៅក្នុងចំណោមពលរដ្ឋកម្ពុជាបួននាក់ មានម្នាក់បានទៅសាលារៀន។ ក្នុងនាមជាអធិបតីភាពនាឱកាសនោះផងដែរ ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី បានចូលរួមផ្តល់នូវអនុសាសន៍ល្អៗ ចំនួន១០ ចំណុចៗ លើគោលនយោបាយពង្រឹងគុណវិស័យអប់រំៈ

- **ទី១** អនុវត្តឱ្យបានសម្រេចគោលដៅអប់រំជាតិ និងគោលដៅសហស្សវត្សរ៍ ដែលតម្រូវឱ្យប្រទេសនីមួយៗ ខិតខំរំដោះអនក្ខរភាពឱ្យបានសម្រេចជាស្ថាពរនៅឆ្នាំ ២០១៥ ខាងមុខ ក្នុងក្របខណ្ឌនៃ 'ការអប់រំសម្រាប់ទាំងអស់គ្នា ទាំងអស់គ្នាសម្រាប់ការអប់រំ' ។
- **ទី២** គប្បីផ្តោតអាទិភាពលើគុណភាពអប់រំជាចម្បង។
- **ទី៣** ចំពោះគ្រឹះស្ថានឧត្តមសិក្សា គួរលើកម្ពស់ការសិក្សាស្រាវជ្រាវប្រកបដោយគុណភាពខ្ពស់ ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការបង្រៀន និងការផ្សារភ្ជាប់ទ្រឹស្តីនៅនឹងការអនុវត្តជាក់ស្តែង ហើយលទ្ធផលនៃការស្រាវជ្រាវត្រូវលើទឹកចិត្តឱ្យបោះពុម្ព ក្នុងទិនានុប្បវត្តិវិទ្យាសាស្ត្រ ជាពិសេសទិន្នានុប្បវត្តិវិទ្យាសាស្ត្រក្នុងតំបន់ និងអន្តរជាតិ។
- **ទី៤** គប្បីជំរុញការអភិវឌ្ឍកម្មវិធីសិក្សាដើម្បីលើកម្ពស់គុណភាពអប់រំ ឆ្លើយតបទៅនឹងតម្រូវ ការជាក់ស្តែងនៅក្នុងទីផ្សារការងារដែលកាន់តែមានការប្រកួតប្រជែងខ្លាំង។
- **ទី៥** គួរយកចិត្តទុកដាក់លើការកែលម្អជីវភាពរស់នៅរបស់លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ ព្រមទាំងបុគ្គលិកសិក្សាទាំងអស់ ដើម្បីបង្កើនប្រសិទ្ធភាពការងារអប់រំឱ្យបានកាន់តែប្រសើរ ថែមទៀត។
- **ទី៦** ដោយការអប់រំ ជាការវិនិយោគរយៈពេលវែង គឺត្រូវឱ្យមានការយកចិត្តទុកដាក់ខ្ពស់លើ ការកៀរគរហិរញ្ញប្បទាន ការជំរុញកំណែទម្រង់អភិបាលកិច្ចក្នុងវិស័យអប់រំ ឱ្យកាន់តែ

[19] នេះបើយោងតាមប្រសាសន៍របស់ លោក សន ជ័យ អ្នកតំណាង សម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាល

មាន ប្រសិទ្ធភាពខ្ពស់ ការផ្សារភ្ជាប់ការអប់រំទៅនឹងការអភិវឌ្ឍ និងការជំរុញវិទ្យាសាស្ត្របច្ចេកទេស។

- **ទី៧** គ្រប់ស្ថាប័នជាតិនិងអន្តរជាតិ វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាលដែលបំពេញការងារក្នុងវិស័យអប់រំ មេត្តាពិនិត្យលើអាទិភាពសំខាន់ក្នុងផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល និងផ្តល់ការគាំទ្រឱ្យបានពេញលេញតាមសមត្ថកិច្ច និងលទ្ធភាពរបស់ ខ្លួន ទាំងបច្ចេកទេស ហិរញ្ញវត្ថុ និងសម្ភារៈ។
- **ទី៨** គួរបន្តកៀរគរបញ្ញាវ័ន្តកម្ពុជា ដែលមានសញ្ញាបត្រខ្ពស់ ជាពិសេសអ្នកដែលមានសញ្ញាបត្រថ្នាក់បណ្ឌិតដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ និងមានបទពិសោធ ឱ្យរួមចំណែកដល់ការអភិវឌ្ឍវិស័យអប់រំនៅកម្ពុជា ប្រកបដោយគុណភាពនិងចីរភាព។
- **ទី៩** គួរយកចិត្តទុកដាក់អនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជាសំដៅអភិវឌ្ឍន៍ទាំងខាង ចំណេះដឹង ចំណេះធ្វើ សុខភាព កាយសម្បទាន និងសីលធម៌ ឱ្យក្លាយទៅជាមូលធនមនុស្ស ប្រកបដោយសក្តានុពល និងធានាបាននូវការបង្កើតកាលានុវត្តភាពការងារសម្រាប់យុវជន ជាពិសេសតាមរយៈការបង្កើតវេទិកាស្វែងរកការងារសម្រាប់យុវជន
- **ទី១០** គួរផ្សារភ្ជាប់ការអប់រំទៅនឹងការអភិវឌ្ឍវិស័យសេដ្ឋកិច្ចឱ្យកាន់តែប្រសើរឡើងថែមទៀត តាមរយៈការបង្រួមឱ្យបានជាអប្បរមានូវគម្លាតរវាងការផ្គត់ផ្គង់ និងតម្រូវការជំនាញក្នុងទីផ្សារការងារ និងបណ្តុះបណ្តាលបច្ចេកទេសនិងជំនាញឱ្យស្របទៅតាម តម្រូវការកម្លាំងពលកម្មទាំងជំនាញបច្ចេកទេស និងជំនាញទន់។

**ប្រភពព័ត៌មានៈ (វិទ្ធី ២០១៤)**

ទាក់ទងនឹងការធ្វើកំណែទម្រង់លើវិស័យអប់រំ ឯកឧត្តម ហង់ ជួនណារ៉ុន បានធ្លាប់លើឡើង ហើយថា 'ការលើកកម្ពស់ជីវភាពគ្រូបង្រៀនគឺជាចំណុចស្នូលមួយនៅក្នុងយុទ្ធសាស្ត្រកំណែទម្រង់ទាំងមូល' ។ ក្នុងនោះឯកឧត្តមបានប្រើវិធានការណ៍៨ចំណុចគាំទ្របន្ថែមគឺៈ

- ការពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- ការពង្រឹងការគ្រប់គ្រងបុគ្គលិក
- ការពង្រឹងការប្រឡងគ្រប់ប្រភេទ
- ការបង្កើតធនាគាខួរក្បាលវិស័យអប់រំ

- កំណែទម្រង់ឧត្តមសិក្សា
- ការបង្កើនគុណភាព និងប្រសិទ្ធភាពនៃសេវាអប់រំនៅគ្រប់កម្រិតសិក្សា
- ការអភិវឌ្ឍសម្រាប់យុវជននូវជំនាញបច្ចេកទេស និងជំនាញទន់
- កែទម្រង់ការអប់រំកាយ និងកីឡា។

**ប្រភពព័ត៌មានៈ** (អ៊ុក សាវបូរី ២០១៣)

ចំពោះកំណែទម្រង់លើការប្រឡងមធ្យមសិក្សាទុតិយភូមិ ត្រូវបានរាជរដ្ឋាភិបាលបាននឹងកំពុងយកចិត្តទុកដាក់ជាងគេនៅពេលនេះ។ គិតមកត្រឹម ថ្ងៃទី៨ ខែ ឧសភា ឆ្នាំ ២០១៤ មានអ្នកស្មគ្រចិត្តចុះឈ្មោះចូលរួមធ្វើការសង្កេតការណ៍ក្នុងដំណើរការប្រឡងចំនួន ១,៤០០នាក់ ដែលភាគច្រើនជានិស្សិត ហើយមានស្ថាប័នសង្គមស៊ីវិលប្រមាណពី ៥ ទៅ ៦ ចូលរួមផងដែរ[20]។

### ២.៤.២ វិធានការណ៍ចំពោះថ្នាក់ឧត្តមសិក្សា

តាមរយៈការអនុវត្តគោលនយោបាយធនធានមនុស្ស រាជរដ្ឋាភិបាលកម្ពុជានីតិកាលទីប្រាំនេះបានយកចិត្តទុកដាក់កាន់តែខ្លាំងតាមរយៈការបង្កើនគុណភាពអប់រំជាចំបង ខណៈពេលដែលអត្រាសិស្សានុសិស្សដែលសិក្សាមុខវិជ្ជាគ្រប់គ្រង និងការងាររដ្ឋបាលហាក់មានអតិផរណា ហើយធនធានមនុស្ស ធ្វើការងារវិជ្ជាជីវៈបច្ចេកទេសក្នុងដំណើរការផលិតកម្មនៅមានចំនួនតិចនៅឡើយ។ នៅក្នុងឆ្នាំសិក្សាឆ្នាំ ២០១៣-២០១៤ ក្រសួងអប់រំ យុវជន និងកីឡា មិនអនុញ្ញាតឱ្យបើកសាកល វិទ្យាល័យណាមួយថ្មីឡើយទោះមានការស្នើសុំក៏ដោយលើមុខវិជ្ជាសាស្ត្រសង្គម ជាពិសេសសាលា ឯកជន។ ការរឹតបន្តឹងនេះ ធ្វើឡើងក្នុងគោលបំណងឱ្យគ្រឹះស្ថានឧត្តមសិក្សាដែលមានស្រាប់ពង្រឹង គុណភាពអប់រំផ្ទៃក្នុង ពង្រឹងគុណភាពគ្រូដែលត្រូវបណ្តុះបណ្តាល ឱ្យដល់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ឬថ្នាក់បណ្ឌិត ហើយក៏ដូចជាពង្រឹងកម្មវិធីសិក្សាផងដែរ។ ជាមួយលក្ខខណ្ឌនេះ ក្រសួងចង់បង្វែរ ឱ្យមានការបង្កើតថ្នាក់មុខវិជ្ជាវិទ្យាសាស្ត្រពិត វិស្វកម្ម ដើម្បីបង្កើន និងពង្រឹងគុណភាពធនធាន មនុស្សផ្នែកជំនាញបច្ចេកទេស ចូលរួមបម្រើដល់កម្លាំងពលកម្មដែលកំពុងមានតម្រូវការនាពេល បច្ចុប្បន្នស្របតាមការរីកចម្រើនរបស់សង្គម។

និស្សិតថ្នាក់ឧត្តមសិក្សាបានបន្តការកើនឡើងពីឆ្នាំទៅមួយឆ្នាំ គិតពីទស្សវត្សរ៍ទី៩០ មានត្រឹមតែ ១០,០០០នាក់ ក្នុងឆ្នាំ ២០០៣ មានចំនួន ៥០,០០០នាក់ និងឆ្នាំសិក្សា ២០១២-២០១៣

[20] នេះបើយោងតាមប្រសាសន៍លោកស្រី **ម៉ា សូឃឹនដា** ប្រធាននាកយដ្ឋានអប់រំ បង្ការ និងទប់ស្កាត់នៃអង្គភាពប្រឆាំងអំពើពុករលួយ។

មានរហូតដល់ ២៥,០០០នាក់ ប៉ុន្តែចំនួនគ្រូឧត្តមសិក្សាមិនបានកើនឡើងសោះ។ តាមគ្រឹះស្ថានឧត្តមសិក្សាភាគច្រើនមានតែថ្នាក់សិក្សាផ្នែកសង្គម ដូចជា គណនេយ្យ ច្បាប់ គ្រប់គ្រង សេដ្ឋកិច្ចជាដើម ដែលមុខវិជ្ជាទាំងនេះកំពុងធ្វើឱ្យលើសតម្រូវការធនធានមនុស្សក្នុងទីផ្សារកម្លាំងពលកម្ម។

គោលដៅរយៈពេលវែងក្នុងវិស័យឧត្តមសិក្សា គឺជាការត្រៀមខ្លួនធ្វើសមាហរណកម្មឧត្តមសិក្សាកម្ពុជាទៅក្នុងសមាគមន៍សេដ្ឋកិច្ចអាស៊ាន ដែលតម្រូវជំរុញឱ្យសាកលវិទ្យាល័យ ចាប់ដៃគូជាមួយប្រទេសក្នុងតំបន់តាមរយៈការបង្កើតធ្វើជាទស្សនៈកិច្ចសិក្សារបស់គ្រូបង្រៀន ឬនិស្សិតការធ្វើការស្រាវជ្រាវរួមគ្នា ដើម្បីជំរុញការផ្ទេរក្រេឌីតឈានទៅបង្កើតកម្មវិធីសិក្សារួមមួយដែលចេញ សញ្ញាបត្ររួមគ្នា (ឆាយ ច័ន្ទនីដា ២០១៤) ។

### ២.៤.៣ ការផ្តោតលើគុណភាពគ្រូបង្រៀនជាបញ្ហាចម្បង

នៅក្នុងរបាយការណ៍ 'អប់រំសម្រាប់ទាំងអស់គ្នាឆ្នាំ ២០១៤ គុណភាពគ្រូបង្រៀនជាបញ្ហាចម្បង " ក្រសួងអប់រំ យុវជន និងកីឡា និងអង្គការយូណេស្កូ ( UNESCO) បានសិក្សានិងបង្ហាញថា ប្រសិនបើចង់ពង្រឹងគុណភាពអប់រំឱ្យកាន់តែប្រសើរ និងមានតម្លាភាព គឺត្រូវពង្រឹងគុណភាពគ្រូ បង្រៀន និងការបង្រៀនមូលដ្ឋានគ្រឹះឱ្យកាន់តែលម្អិតដល់សិស្ស (សួង, សុភារី ២០១៤) ។ សូមបញ្ជាក់ថា របាយការណ៍របស់អង្គការយូណេស្កូបានឱ្យដឹងថា បញ្ហាគ្រូបង្រៀន នៅតែជាបញ្ហាចម្បង ហើយពិភពលោកនៅតែត្រូវការគ្រូបង្រៀនជានិច្ច។ នៅកម្ពុជាក៏ដូចគ្នាដែរ កង្វះគ្រូបង្រៀនទាំងផ្នែកបរិមាណនិងគុណភាព បានធ្វើឱ្យប៉ះពាល់ដល់គុណភាពវិស័យអប់រំយ៉ាងខ្លាំង នាពេលបច្ចុប្បន្ននេះ។

# ជំពូកទី៣

# ការវិភាគទិន្នន័យ

# ជំពូកទី៣ ការវិភាគទិន្នន័យ

## ៣.១ ការរៀបចំទិន្នន័យ

នៅក្នុងកិច្ចដំណើរការរកមធ្យោបាយបង្កើនប្រាក់ចំណូលបុគ្គលតាមរយៈការអប់រំ ដែលបាន លើកជាប្រធានបទនេះ តាមបច្ចេកទេស គឺប្រមូលទិន្នន័យដែលជាប់ពាក់ព័ន្ធនឹងបុគ្គលដែលមានការងារធ្វើក្រោយបញ្ចប់ការសិក្សានៅសាលា ឬសាកលវិទ្យាល័យនានា។ ការប្រើប្រាស់កម្រងសំណួរ មានសារៈសំខាន់ក្នុងការស្វែងរក និងប្រមូលព័ត៌មានដែលជាប់ពាក់ព័ន្ធពីប្រាក់ចំណូលរបស់បុគ្គល ដែលជាប់ទាក់ទងនឹងការអប់រំរបស់ពួកគេ។

ការប្រមូលព័ត៌មាន ទិន្នន័យមួយចំនួនសម្រាប់លទ្ធផលនៃការស្រាវប្រធានបទនេះ គឺប្រើប្រាស់កម្រងសំណួរចំនួន១១សំណួរ ហើយសម្ភាសន៍លើអ្នកពាក់ព័ន្ធចំនួន១៥០នាក់នៅទីក្រុង ភ្នំពេញ ចាប់ពីខែ មីនា ឆ្នាំ ២០១៧ ដល់ខែ មេសា ឆ្នាំ ២០១៧ ដែលបានចូលរួមឆ្លើយសំណួរក្នុងនោះមាន បុរសចំនួន ៣៩.៣% (n=59) និង ៦០.៧% (n=91) ជាស្ត្រី។

ការស្វែងរកលទ្ធផលនៃការស្រាវជ្រាវធ្វើទៅលើចំណុចសំខាន់មួយចំនួនដូចជា បរិញ្ញាបត្រ ជំនាញ កម្រិតនៃការអប់រំ ចំនួនឆ្នាំនៃការអប់រំ ការងារធ្វើ វិស័យការងារ ជំនាញការងារ ផ្នែកការងារ បទពិសោធការងារ ប្រាក់ចំណូល និងកត្តាដែលធ្វើអោយប្រាក់ចំណូលប្រែប្រួល។ រាល់ទិន្ន័យ ដែលប្រមូលបានធ្វើការវិភាគដោយ SPSS Program ។ ការបកស្រាយទិន្ន័យផ្អែកលើការពិពណ៌នា តាម ( Mean )។

## ៣.២ ការបកស្រាយទិន្ន័យ

### ៣.២.១ បរិយាយទិន្ន័យព័ត៌មានអង្កេត ( Data Description )

បុគ្គលដែលបានចូលរួមឆ្លើយសំណួរស្រាវជ្រាវនេះមកពីជំនាញផ្សេងៗគ្នា

**តារាងទី៧៖** បុគ្គលនៅតាមជំនាញផ្សេងៗដែលបានចូលរួមឆ្លើយកម្រងសំណួរ

| ជំនាញ | ចំនួន (នាក់) | ភាគរយ (%) |
|---|---|---|
| នីតិសាស្ត្រ | ៤ | ២.៧ |
| រដ្ឋបាលសាធារណៈ | ២ | ១.៣ |
| គ្រប់គ្រងអាជីវកម្ម | ២៣ | ១៥.៣ |

| | | |
|---|---|---|
| សេដ្ឋកិច្ចអភិវឌ្ឍន៍ | ២០ | ១៣.៣ |
| គណនេយ្យ | ២១ | ១៤.០ |
| ធនាគារ និងហិរញ្ញវត្ថុ | ៨ | ៥.៣ |
| សេដ្ឋកិច្ចព័តិមានវិទ្យា | ៤ | ២.៧ |
| គ្រប់គ្រងទេសចរណ៍ | ២ | ១.៣ |
| ទំនាក់ទំនងអន្តរជាតិ | ១ | ០.៧ |
| ទីផ្សារ | ៧ | ៤.៧ |
| សំណង់ស៊ីវិល | ២ | ១.៣ |
| ភាសាអង់គ្លេស | ១៣ | ៨.៧ |
| ផ្សេងពីនេះ | ៣២ | ២១.៣ |
| សរុប | ១៥០ | ១០០ |

តាមតារាងទី៧ ខាងលើបានបង្ហាញថាៈ ចំនួនបុគ្គលដែលបានចូលរួមឆ្លើយនូវកម្រងសំណួរមានចំនួន ១៥០នាក់ ក្នុងមានជំនាញនីតិសាស្រ្តចំនួន ៤នាក់ ស្មើនឹង ២.៧% ជំនាញរដ្ឋបាលសាធារណៈចំនួន ២នាក់ ស្មើនឹង ១.៣% ជំនាញគ្រប់គ្រងអាជីវកម្មចំនួន ២៣នាក់ ស្មើនឹង ១៥.៣% ជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍ចំនួន២០នាក់ ស្មើនឹង ១៣.៣% ជំនាញគណនេយ្យចំនួន២១នាក់ ស្មើនឹង ១៤.០% ជំនាញធនាគារ និងហិរញ្ញវត្ថុចំនួន ៨នាក់ ស្មើនឹង ៥.៣% ជំនាញសេដ្ឋកិច្ចព័តិមានវិទ្យាចំនួន ៤នាក់ ស្មើនឹង ២.៧% ជំនាញគ្រប់គ្រងទេសចរណ៍ចំនួន ២នាក់ ស្មើនឹង ២.៣% ជំនាញទំនាក់ទំនងអន្តរជាតិចំនួន ១នាក់ ស្មើនឹង ០.៧% ជំនាញទីផ្សារ ៧នាក់ ស្មើនឹង ៤.៧% ជំនាញសំណង់ស៊ីវិលចំនួន ២នាក់ ស្មើនឹង ១.៣% ជំនាញភាសាអង់គ្លេសចំនួន ១៣នាក់ ស្មើនឹង ៨.៧% ជំនាញផ្សេងពីនេះចំនួន៣២នាក់ ស្មើនឹង ២១.៣% ។

### ៣.២.២ លទ្ធផលនៃការវិភាគការបង្កើនប្រាក់ចំណូលបុគ្គលតាមរយៈការអប់រំ

#### ៣.២.២.១ ការវិភាគប្រាក់ចំណូលបុគ្គល តាមសាកលវិទ្យាល័យ

**តារាងទី៨៖** ការវិភាគប្រាក់ចំណូលបុគ្គល តាមសាកលវិទ្យាល័យ

| សាលកវិទ្យាល័យ | ប្រាក់ចំណូលបុគ្គលជាមធ្យម (ដុល្លារ) | ចំនួន (នាក់) | ភាគរយ% |
|---|---|---|---|
| សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច | ២២២ | ៤៨ | ៣៦.៦% |
| សាកលវិទ្យាល័យជាតិគ្រប់គ្រង | ២២៤ | ៥ | ៣.៨% |
| សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | ២១២ | ២៤ | ១៨.៣% |
| វិទ្យាស្ថានវ៉ាន់ដាគណនេយ្យ | ២១៥ | ២ | ១.៥% |
| សាកលវិទ្យាល័យបៀលប្រាយ | ២៦៥ | ៥ | ៣.៨% |
| ផ្សេងពីនេះ | ២៣៣ | ៤៧ | ៣៥.៩% |
| សរុប | ២២៥ | ១៣១ | ១០០% |

តាមតារាងទី៨ ខាងលើបានបង្ហាញថា៖ ប្រាក់ចំណូលបុគ្គល តាមសាកលវិទ្យាល័យនានាដែលបានផ្តល់ការសម្ភាសន៍ចំនួនសរុប ១៣១នាក់ ហើយប្រាក់ចំណូលជាមធ្យមមាន ២២៥ ដុល្លារ ក្នុងនោះបុគ្គលដែលសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចមានចំនួន ៤៨នាក់ ស្មើនឹង៣៦.៦% ហើយប្រាក់ចំណូលជាមធ្យមមាន ២២២ដុល្លារ បុគ្គលដែលសិក្សានៅសាកលវិទ្យាល័យជាតិគ្រប់គ្រងមានចំនួន ៥នាក់ ស្មើនឹង៣.៨% ហើយប្រាក់ចំណូលជាមធ្យមមាន ២២៤ ដុល្លារ បុគ្គលដែលសិក្សានៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញមានចំនួន ២៤នាក់ ស្មើនឹង១៨.៣% ហើយប្រាក់ចំណូលមធ្យមមាន ២១២ដុល្លារ បុគ្គលដែលសិក្សានៅវិទ្យាស្ថានវ៉ាន់ដាគណនេយ្យមានចំនួន ២នាក់ ស្មើនឹង១.៥% ហើយប្រាក់ចំណូលមធ្យមមាន ២១៥ដុល្លារ បុគ្គលដែលសិក្សានៅសាកលវិទ្យាល័យបៀលប្រាយមានចំនួន ៥នាក់ ស្មើនឹង៣.៨% ហើយប្រាក់ចំណូលមធ្យមមាន ២៦៥ដុល្លារ ចំណែក បុគ្គលដែលសិក្សានៅសាកលវិទ្យាល័យផ្សេងពីនេះមានចំនួន ៤៧នាក់ ស្មើនឹង៣៥.៩% ហើយប្រាក់ចំណូលជាមធ្យមមាន ២៣៣ ដុល្លារ។

### ៣.២.២.២ ការវិភាគប្រាក់ចំណូលបុគ្គល តាមកម្រិតនៃការអប់រំ

**តារាងទី៩៖** ការវិភាគប្រាក់ចំណូលបុគ្គល តាមកម្រិតនៃការអប់រំ

| កម្រិតនៃការអប់រំដែលបានសម្ភាសន៍ | ប្រាក់ចំណូលជាមធ្យម (ដុល្លារ) | ចំនួន (នាក់) | ភាគរយ% |
|---|---|---|---|
| អនុវិទ្យាល័យ | ៣៧០ | ១ | ០.៧% |
| វិទ្យាល័យ | ២០៨ | ៦ | ៤.៤% |
| បរិញ្ញាបត្ររង | ២៦២ | ៤ | ២.៩% |
| បរិញ្ញាបត្រ | ២១០ | ១១៨ | ៨៦.៨% |
| បរិញ្ញាបត្រជាន់ខ្ពស់ | ៤៥០ | ៧ | ៥.១% |
| សរុប | ២២៥ | ១៣៦ | ១០០% |

តារាងទី៩ ខាងលើបានបង្ហាញថា៖ ប្រាក់ចំណូលបុគ្គល តាមកម្រិតនៃការអប់រំ ដែលបានផ្តល់ការសម្ភាសន៍ចំនួនសរុបមាន ១៣៦នាក់ ហើយប្រាក់ចំណូលមធ្យមមាន ២២៥ដុល្លារ ក្នុងនោះបុគ្គលដែលសិក្សាកម្រិតអនុវិទ្យាល័យមានចំនួន ១នាក់ ស្មើនឹង០.៧% ហើយប្រាក់ចំណូលមធ្យមមាន ៣៧០ដុល្លារ បុគ្គលដែលសិក្សាកម្រិតវិទ្យាល័យមានចំនួន ៦នាក់ ស្មើនឹង៤.៤% ហើយប្រាក់ចំណូលមធ្យមមាន ២០៨ដុល្លារ បុគ្គលដែលសិក្សាកម្រិតបរិញ្ញាបត្ររងមានចំនួន ៤នាក់ ស្មើនឹង២.៩% ហើយប្រាក់ចំណូលមធ្យមមាន ២៦២ដុល្លារ បុគ្គលដែលសិក្សាកម្រិតបរិញ្ញាបត្រមានចំនួន ១១៨នាក់ ស្មើនឹង៨៦.៨% ហើយប្រាក់ចំណូលមធ្យមមាន ២១០ដុល្លារ ចំណែកឯបុគ្គលដែលសិក្សាកម្រិតបរិញ្ញាបត្រជាន់ខ្ពស់មានចំនួន ៧នាក់ ស្មើនឹង៥.១% ហើយប្រាក់ចំណូលមធ្យមមាន ៤៥០ដុល្លារ។

### ៣.២.២.៣ ការវិភាគប្រាក់ចំណូលបុគ្គល តាមចំនួនឆ្នាំនៃការអប់រំ

| **តារាងទី១០៖** ការវិភាគប្រាក់ចំណូលបុគ្គល តាមចំនួនឆ្នាំនៃការអប់រំ | | | |
|---|---|---|---|
| ចំនួនឆ្នាំនៃការអប់រំ (ឆ្នាំ) | ប្រាក់ចំណូលជាមធ្យម (ដុល្លារ) | ចំនួន (នាក់) | ភាគរយ% |
| ៨ | ១៨០ | ១ | ០.៧% |
| ១២ | ២១៤ | ៥ | ៣.៧% |
| ១៤ | ១៨០ | ៣ | ២.២% |

| | | | |
|---|---|---|---|
| ១៥ | ១៧១ | ៦ | ៤.៤% |
| ១៦ | ២០៨ | ១០៣ | ៧៦.៣% |
| ១៧ | ៣០៥ | ៨ | ៥.៩% |
| ១៨ | ៤៩៥ | ៤ | ៣.០% |
| ១៩ | ២២៥ | ២ | ១.៥% |
| ២០ | ៤៣៣ | ៣ | ២.២% |
| សរុប | ២២៥ | ១៣៥ | ១០០% |

តាមតារាងទី១០ ខាងលើបានបង្ហាញថាៈ ប្រាក់ចំណូលបុគ្គល តាមចំនួនឆ្នាំនៃការអប់រំ ដែលបានផ្ដល់ការសម្ភាសន៍សរុបចំនួន ១៣៥នាក់ ហើយប្រាក់ចំណូលមធ្យមមាន ២២៥ដុល្លារ ក្នុងនោះបុគ្គលដែលសិក្សាបាន ៨ឆ្នាំ មានចំនួន ១នាក់ ស្មើនឹង០.៧% ហើយប្រាក់ចំណូលមធ្យមមាន ១៨០ដុល្លារ បុគ្គលដែលសិក្សាបាន ១២ឆ្នាំ មានចំនួន ៥នាក់ ស្មើនឹង៣.៧% ហើយប្រាក់ចំណូលមធ្យមមាន ២១៤ដុល្លារ បុគ្គលដែលសិក្សាបាន ១៤ឆ្នាំ មានចំនួន ៣នាក់ ស្មើនឹង២.២% ហើយប្រាក់ចំណូលមធ្យមមាន ១៨០ដុល្លារ បុគ្គលដែលសិក្សាបាន ១៥ឆ្នាំ មានចំនួន ៦នាក់ ស្មើនឹង៤.៤% ហើយប្រាក់ចំណូលមធ្យមមាន ១៧១ដុល្លារ បុគ្គលដែលសិក្សាបាន ១៦ឆ្នាំ មានចំនួន ១០៣នាក់ ស្មើនឹង៧៦.៣% ហើយប្រាក់ចំណូលមធ្យមមាន ២០៨ដុល្លារ បុគ្គលដែលសិក្សាបាន ១៧ឆ្នាំ មានចំនួន ៨នាក់ ស្មើនឹង៥.៩% ហើយប្រាក់ចំណូលមធ្យមមាន ៣០៥ដុល្លារ បុគ្គលដែលសិក្សាបាន ១៨ឆ្នាំ មានចំនួន ៤នាក់ ស្មើនឹង៣.០% ហើយប្រាក់ចំណូលមធ្យមមាន ៤៩៥ដុល្លារ បុគ្គលដែលសិក្សាបាន ១៩ឆ្នាំ មានចំនួន ២នាក់ ស្មើនឹង១.៥% ហើយប្រាក់ចំណូលមធ្យមមាន ២២៥ដុល្លារ បុគ្គលដែលសិក្សាបាន ២០ឆ្នាំ មានចំនួន ៣នាក់ ស្មើនឹង២.២% ហើយប្រាក់ចំណូលមធ្យមមាន ៤៣៣ដុល្លារ។

### ៣.២.២.៤ ការវិភាគប្រាក់ចំណូលបុគ្គល តាមការមានការងារធ្វើ

| **តារាងទី១១៖** ការវិភាគប្រាក់ចំណូលបុគ្គល តាមការមានការងារធ្វើ | | | |
|---|---|---|---|
| ការមានការងារធ្វើដែលបានសម្ភាសន៍ | ប្រាក់ចំណូលជាមធ្យម(ដុល្លារ) | ចំនួន (នាក់) | ភាគរយ% |

| | | | |
|---|---|---|---|
| បុគ្គលដែលមានការងារធ្វើ | ២២៦ | ១៣២ | ៩៧.៨% |
| បុគ្គលដែលអត់មានការងារធ្វើ | ២០៣ | ៣ | ២.២% |
| សរុប | ២២៥ | ១៣៥ | ១០០% |

តាមតារាងទី១១ ខាងលើបានបង្ហាញថា៖ ប្រាក់ចំណូលបុគ្គល ដែលមានការងារធ្វើ ដែលបានផ្ដល់ការសម្ភាសន៍សរុបមានចំនួន ១៣៥នាក់ ហើយប្រាក់ចំណូលមធ្យមមាន ២២៥ដុល្លារ ក្នុងនោះបុគ្គលដែលមានការងារធ្វើមានចំនួន ១៣២នាក់ ស្មើនឹង៩៧.៨% ហើយប្រាក់ចំណូលមធ្យមមាន ២២៦ដុល្លារ បុគ្គលដែលអត់មានការងារធ្វើមានចំនួន ៣នាក់ ស្មើនឹង២.២% ហើយប្រាក់ចំណូលមធ្យមមាន ២០៣។

### ៣.២.២.៥ ការវិភាគប្រាក់ចំណូលបុគ្គល តាមអំឡុងពេលទទួលបានការងារក្រោយបញ្ចប់ការសិក្សា

**តារាងទី១២៖** ការវិភាគប្រាក់ចំណូលបុគ្គល តាមអំឡុងពេលទទួលបានការងារក្រោយបញ្ចប់ការសិក្សា

| អំឡុងពេលទទួលបានការងារ (ខែ) | ប្រាក់ចំណូលជាមធ្យម (ដុល្លារ) | ចំនួន (នាក់) | ភាគរយ |
|---|---|---|---|
| ១ | ២០០ | ១ | ១.១% |
| ១ | ២៥៩ | ២៦ | ២៩.៥% |
| ២ | ២២០ | ១៨ | ២០.៥% |
| ៣ | ២០៧ | ១៤ | ១៥.៩% |
| ៤ | ២៤០ | ៣ | ៣.៤% |
| ៥ | ១៨៨ | ៧ | ៨.០% |
| ៦ | ១៨៥ | ៥ | ៥.៧% |
| ៧ | ២៨៣ | ៣ | ៣.៤% |
| ៨ | ២១៥ | ២ | ២.៣% |

| | | | |
|---|---|---|---|
| ៩ | ១៥០ | ១ | ១.១% |
| ១០ | ២០០ | ១ | ១.១% |
| ១១ | ២៣៥ | ២ | ២.៣% |
| ១២ | ៣៥០ | ២ | ២.៣% |
| ១៧ | ៦៥ | ១ | ១.១% |
| ២៤ | ១៥០ | ១ | ១.១% |
| ២៤ | ២៤០ | ១ | ១.១% |
| សរុប | ២២៧ | ៨៨ | ១០០% |

តាមតារាងទី១២ ខាងលើបានបង្ហាញថាៈ ប្រាក់ចំណូលបុគ្គល តាមអំឡុងពេលទទួលបានការងារក្រោយបញ្ចប់ការសិក្សាដែលបានផ្តល់ការសម្ភាសន៍សរុបមានចំនួន ៨៨នាក់ ហើយប្រាក់ចំណូលមធ្យមមាន ២២៧ដុល្លារ ក្នុងនោះបុគ្គលដែលទទួលបានការងារធ្វើនៅខែទី១ក្រោយបញ្ចប់ការសិក្សាមានចំនួន ១នាក់ ស្មើនឹង១.១% ហើយប្រាក់ចំណូលមធ្យមមាន ២០០ដុល្លារ បុគ្គលដែលទទួលបានការងារធ្វើនៅខែទី១ក្រោយបញ្ចប់ការសិក្សាមានចំនួន ២៦នាក់ ស្មើនឹង២៩.៥% ហើយប្រាក់ចំណូលមធ្យមមាន ២៥៩ដុល្លារ បុគ្គលដែលទទួលបានការងារធ្វើនៅខែទី២ក្រោយបញ្ចប់ការសិក្សាមានចំនួន ១៨នាក់ ស្មើនឹង២០.៥% ហើយប្រាក់ចំណូលមធ្យមមាន ២២០ដុល្លារ បុគ្គលដែលទទួលបានការងារធ្វើនៅខែទី៣ក្រោយបញ្ចប់ការសិក្សាមានចំនួន ១៤នាក់ ស្មើនឹង ១៥.៩% ហើយប្រាក់ចំណូលមធ្យមមាន២០៧ដុល្លារ បុគ្គលដែលទទួលបានការងារធ្វើនៅខែទី៤ក្រោយបញ្ចប់ការសិក្សាមានចំនួន ៣នាក់ ស្មើនឹង៣.៤% ហើយប្រាក់ចំណូលមធ្យមមាន ២៤០ ដុល្លារ បុគ្គលដែលទទួលបានការងារធ្វើនៅខែទី៥ក្រោយបញ្ចប់ការសិក្សាមានចំនួន ៧នាក់ ស្មើនឹង៨.០% ហើយប្រាក់ចំណូលមធ្យមមាន ១៨៨ដុល្លារ បុគ្គលដែលទទួលបានការងារធ្វើនៅខែទី៦ក្រោយបញ្ចប់ការសិក្សាមានចំនួន ៥នាក់ ស្មើនឹង៥.៧% ហើយប្រាក់ចំណូលមធ្យមមាន ១៨៥ ដុល្លារ បុគ្គលដែលទទួលបានការងារធ្វើនៅខែទី៧ក្រោយបញ្ចប់ការសិក្សាមានចំនួន ៣នាក់ ស្មើនឹង៣.៤% ហើយប្រាក់ចំណូលមធ្យមមាន ២៨៣ដុល្លារ បុគ្គលដែលទទួលបានការងារធ្វើនៅខែទី៨ក្រោយបញ្ចប់ការសិក្សាមានចំនួន ២នាក់ ស្មើនឹង២.៣% ហើយប្រាក់ចំណូលមធ្យមមាន ២១៥

ដុល្លារ បុគ្គលដែលទទួលបានការងារធ្វើនៅខែទី៩ក្រោយបញ្ចប់ការសិក្សាមានចំនួន ១នាក់ ស្មើនឹង១.១% ហើយប្រាក់ចំណូលមធ្យមមាន ១៥០ដុល្លារ បុគ្គលដែលទទួលបានការងារធ្វើនៅខែទី១០ក្រោយបញ្ចប់ការសិក្សាមានចំនួន ១នាក់ ស្មើនឹង១.១% ហើយប្រាក់ចំណូលមធ្យមមាន ២០០ ដុល្លារ បុគ្គលដែលទទួលបានការងារធ្វើនៅខែទី១១ក្រោយបញ្ចប់ការសិក្សាមានចំនួន ២នាក់ ស្មើនឹង២.៣% ហើយប្រាក់ចំណូលមធ្យមមាន ២៣៥ដុល្លារ បុគ្គលដែលទទួលបានការងារធ្វើនៅខែទី១២ក្រោយបញ្ចប់ការសិក្សាមានចំនួន ២នាក់ ស្មើនឹង២.៣% ហើយប្រាក់ចំណូលមធ្យមមាន ៣៥០ ដុល្លារ បុគ្គលដែលទទួលបានការងារធ្វើនៅខែទី១៧ក្រោយបញ្ចប់ការសិក្សាមានចំនួន ១នាក់ ស្មើនឹង១.១% ហើយប្រាក់ចំណូលមធ្យមមាន ៦៥ដុល្លារ បុគ្គលដែលទទួលបានការងារធ្វើនៅខែទី២៤ ក្រោយបញ្ចប់ការសិក្សាមានចំនួន ១នាក់ ស្មើនឹង១.១% ហើយប្រាក់ចំណូលមធ្យមមាន ១៥០ ដុល្លារ បុគ្គលដែលទទួលបានការងារធ្វើនៅខែទី២៨ក្រោយបញ្ចប់ការសិក្សាមានចំនួន ១នាក់ ស្មើនឹង១.១% ហើយប្រាក់ចំណូលមធ្យមមាន ២៥០ដុល្លារ។

### ៣.២.២.៦ ការវិភាគប្រាក់ចំណូលបុគ្គល តាមវិស័យការងារ

**តារាងទី១៣៖** ការវិភាគប្រាក់ចំណូលបុគ្គល តាមវិស័យការងារ

| វិស័យការងារដែលបានសម្ភាសន៍ | ប្រាក់ចំណូលជាមធ្យម (ដុល្លារ) | ចំនួន (នាក់) | ភាគរយ% |
|---|---|---|---|
| រដ្ឋ | ២២៥ | ២១ | ១៥.៤% |
| ឯកជន | ២២៥ | ១០៨ | ៧៩.៤% |
| អង្គការសង្គមស៊ីវិល | ២១៩ | ៧ | ៥.១% |
| សរុប | ២២៥ | ១៣៦ | ១០០% |

តាមតារាងទី១៣ ខាងលើបានបង្ហាញថា៖ ប្រាក់ចំណូលបុគ្គល តាមវិស័យការងារ ដែលបានផ្តល់ការសម្ភាសន៍សរុបមានចំនួន ១៣៦នាក់ ហើយប្រាក់ចំណូលមធ្យមមាន ២២៥ដុល្លារ ក្នុងនោះបុគ្គលដែលធ្វើការងារក្នុងវិស័យរដ្ឋមានចំនួន ២១នាក់ ស្មើនឹង១៥.៤% ហើយប្រាក់ចំណូលមធ្យមមាន ២២៥ដុល្លារ បុគ្គលដែលធ្វើការងារក្នុងវិស័យឯកជនមានចំនួន ១០៨នាក់ ស្មើនឹង៧៩.៤% ហើយប្រាក់ចំណូលមធ្យមមាន ២២៥ បុគ្គលដែលធ្វើការងារនៅក្នុងវិស័យអង្គការសង្គមស៊ីវិលមានចំនួន ៧នាក់ ស្មើនឹង៥.១% ហើយប្រាក់ចំណូលមធ្យមមាន ២១៩ដុល្លារ។

### ៣.២.២.៧ ការវិភាគប្រាក់ចំណូលបុគ្គល តាមជំនាញ

**តារាងទី១៤៖** ការវិភាគប្រាក់ចំណូលបុគ្គល តាមជំនាញ

| ជំនាញ | ប្រាក់ចំណូលជាមធ្យម (ដុល្លារ) | ចំនួន (នាក់) | ភាគរយ% |
|---|---|---|---|
| ត្រូវជំនាញ | ២៦៨ | ៦៤ | ៤៨.១% |
| ខុសជំនាញ | ១៨៦ | ៦៩ | ៥១.៩% |
| សរុប | ២២៥ | ១៣៣ | ១០០% |

តាមតារាងទី១៤ ខាងលើបានបង្ហាញថា៖ ប្រាក់ចំណូលបុគ្គល តាមជំនាញដែលបានផ្តល់ការសម្ភាសន៍សរុបចំនួន ១៣៣នាក់ ហើយប្រាក់ចំណូលមធ្យមមាន ២២៥ដុល្លារ ក្នុងនោះ បុគ្គលដែលធ្វើការងារត្រូវជំនាញមានចំនួន ៦៤នាក់ ស្មើនឹង៤៨.១% ហើយប្រាក់ចំណូលមធ្យមមាន ២៦៨ដុល្លារ បុគ្គលដែលធ្វើការងារខុសជំនាញមានចំនួន ៦៩នាក់ ស្មើនឹង៥១.៩% ហើយប្រាក់ចំណូលមធ្យមមាន ១៨៦ដុល្លារ។

### ៣.២.២.៨ ការវិភាគប្រាក់ចំណូលបុគ្គល តាមផ្នែកការងារ

**តារាងទី១៥៖** ការវិភាគប្រាក់ចំណូលបុគ្គល តាមផ្នែកការងារ

| ផ្នែកការងារ | ប្រាក់ចំណូលជាមធ្យម (ដុល្លារ) | ចំនួន (នាក់) | ភាគរយ% |
|---|---|---|---|
| គណនេយ្យ | ២០៧ | ១១ | ៨.៣% |
| ទីផ្សារ | ២៣១ | ៣៥ | ២៦.៥% |
| គ្រប់គ្រង | ២៦៨ | ៧ | ៥.៣% |
| ច្បាប់ | ២៥០ | ១ | ០.៨% |
| រដ្ឋបាល | ១៩៥ | ១២ | ៩.១% |
| ធនាគារ | ២៦៥ | ២ | ១.៥% |
| បេឡា | ២១៤ | ៥ | ៣.៨% |

| | | | |
|---|---|---|---|
| គ្រូបង្រៀន | ២៤៧ | ២១ | ១៥.៩% |
| ផ្សេងពីនេះ | ២១៥ | ៣៨ | ២៨.៨% |
| សរុប | ២២៥ | ១៣២ | ១០០% |

តាមតារាងទី១៥ ខាងលើបានបង្ហាញថា៖ ប្រាក់ចំណូលបុគ្គល តាមផ្នែកការងារដែលបានផ្តល់ការសម្ភាសន៍សរុបចំនួន ១៣២នាក់ ហើយប្រាក់ចំណូលមធ្យមមាន ២២៥ដុល្លារ ក្នុងនោះ បុគ្គលដែលធ្វើការងារផ្នែកគណនេយ្យមានចំនួន ១១នាក់ ស្មើនឹង៨.៣% ហើយប្រាក់ចំណូលមធ្យមមាន ២០៧ដុល្លារ បុគ្គលដែលធ្វើការងារផ្នែកទីផ្សារមានចំនួន ៣៥នាក់ ស្មើនឹង២៦.៥% ហើយប្រាក់ចំណូលមធ្យមមាន ២៣១ដុល្លារ បុគ្គលដែលធ្វើការផ្នែកគ្រប់គ្រងមានចំនួន ៧នាក់ ស្មើនឹង៥.៣% ហើយប្រាក់ចំណូលមធ្យមមាន ២៦៨ដុល្លារ បុគ្គលដែលធ្វើការផ្នែកច្បាប់មានចំនួន ១នាក់ ស្មើនឹង០.៨% ហើយប្រាក់ ចំណូលមធ្យមមាន ២៥០ដុល្លារ បុគ្គលដែលធ្វើការផ្នែករដ្ឋបាលមានចំនួន ១២នាក់ ស្មើនឹង៩.១% ហើយប្រាក់ចំណូលមធ្យមមាន ១៩៥ដុល្លារ បុគ្គលដែលធ្វើការផ្នែកធនាគារ និងហរិញ្ញវត្ថុមានចំនួន ២នាក់ ស្មើនឹង១.៥% ហើយប្រាក់ចំណូលមធ្យមមាន ២៦៥ដុល្លារ បុគ្គលដែលធ្វើការផ្នែកបេឡាមានចំនួន ៥នាក់ ស្មើនឹង៣.៨% ហើយប្រាក់ចំណូលមធ្យមមាន ២១៨ដុល្លារ បុគ្គលដែលធ្វើការផ្នែក គ្រូបង្រៀនមានចំនួន ២១នាក់ ស្មើនឹង១៥.៩% ហើយប្រាក់ចំណូលមធ្យមមាន ២៤៧.០៤៧៦ដុល្លារ បុគ្គលដែលធ្វើការផ្នែកផ្សេងពីនេះមានចំនួន ៣៨នាក់ ស្មើនឹង២៨.៨% ហើយប្រាក់ចំណូលមធ្យមមាន ២១៥.២៨៩៥ដុល្លារ។

### ៣.២.២.៩ ការវិភាគប្រាក់ចំណូលបុគ្គល តាមបទពិសោធក្នុងការងារ

| **តារាងទី១៦៖** ការវិភាគប្រាក់ចំណូលបុគ្គល តាមបទពិសោធក្នុងការងារ | | | |
|---|---|---|---|
| បទពិសោធ (ឆ្នាំ) | ប្រាក់ចំណូលជាមធ្យម (ដុល្លារ) | ចំនួន (នាក់) | ភាគរយ% |
| ០.២ | ១៨០ | ១ | ០.៨% |
| ០.៣ | ១១៧ | ១ | ០.៨% |
| ០.៥ | ១៩៣ | ៣ | ២.៣% |
| ០.៦ | ២៣៤ | ៥ | ៣.៨% |
| ០.៩ | ២៤៥ | ២ | ១.៥% |

| | | | |
|---|---|---|---|
| ១ | ១៩៧ | ៤២ | ៣២.១% |
| ១.៥ | ៣០០ | ២ | ១.៥% |
| ២ | ២០៣ | ២០ | ១៥.៣% |
| ២.៥ | ២២៥ | ១ | ០.៨% |
| ៣ | ២២៤ | ២៣ | ១៧.៦% |
| ៤ | ២២៤ | ១៤ | ១០.៧% |
| ៥ | ៣២១ | ៦ | ៤.៦% |
| ៦ | ២៦០ | ៣ | ២.៣% |
| ៧ | ៤៥០ | ១ | ០.៨% |
| ៨ | ២៩០ | ៣ | ២.៨% |
| ១០ | ៤១០ | ២ | ១.៥% |
| ១៣ | ៥៥០ | ១ | ០.៨% |
| ១៩ | ៦០០ | ១ | ០.៨% |
| សរុប | ២២៨ | ១៣១ | ១០០% |

តាមតារាងទី១៦ ខាងលើបង្ហាញថា៖ ប្រាក់ចំណូលបុគ្គល តាមបទពិសោធការងារដែលបានផ្តល់ការសម្ភាសន៍សរុបចំនួន ១៣១នាក់ ហើយប្រាក់ចំណូលមធ្យមមាន ២២៨ដុល្លារ ក្នុងនោះ បុគ្គលដែលមានបទពិសោធការងាររយៈពេល ០.២ឆ្នាំ មានចំនួន ១នាក់ ស្មើនឹង០.៨% ហើយប្រាក់ចំណូលមធ្យមមាន ១៨០ដុល្លារ បុគ្គលដែលមានបទពិសោធការងាររយៈពេល ០.៣ឆ្នាំ មានចំនួន ១នាក់ ស្មើនឹង០.៨% ហើយប្រាក់ចំណូលមធ្យមមាន ១១៧ដុល្លារ បុគ្គលដែលមានបទពិសោធការងាររយៈពេល ០.៥ឆ្នាំ មានចំនួន៣នាក់ ស្មើនឹង២.៣% ហើយប្រាក់ចំណូលមធ្យមមាន ១៤៣ដុល្លារ បុគ្គលដែលមានបទពិសោធការងាររយៈពេល ០.៦ឆ្នាំ មានចំនួន៥នាក់ ស្មើនឹង៣.៨% ហើយប្រាក់ចំណូលមធ្យមមាន ២៣៩ដុល្លារ បុគ្គលដែលមានបទពិសោធការងាររយៈពេល ០.៩ឆ្នាំ មានចំនួន២នាក់ ស្មើនឹង១.៥% ហើយប្រាក់ចំណូលមធ្យមមាន ២៤៥ដុល្លារ បុគ្គល

ដែលមាន បទពិសោធការងាររយៈពេល ១ឆ្នាំ មានចំនួន៤២នាក់ ស្មើនឹង៣២.១% ហើយប្រាក់ចំណូលមធ្យមមាន ១៩៧ដុល្លារ បុគ្គលដែលមានបទពិសោធការងាររយៈពេល ១.៥ឆ្នាំ មានចំនួន២នាក់ ស្មើនឹង១.៥% ហើយប្រាក់ចំណូលមធ្យមមាន ៣០០ដុល្លារ បុគ្គលដែលមានបទពិសោធការងាររយៈពេល ២ឆ្នាំ មានចំនួន២០នាក់ ស្មើនឹង១៥.៣% ហើយមានប្រាក់ចំណូលមធ្យម ២០៣ដុល្លារ បុគ្គលដែលមានបទពិសោធការងាររយៈពេល ២.៥ឆ្នាំ មានចំនួន១នាក់ ស្មើនឹង០.៨% ហើយប្រាក់ចំណូលមធ្យមមាន ២២៥ដុល្លារ បុគ្គលដែលមានបទពិសោធការងាររយៈពេល ៣ឆ្នាំ មានចំនួន២៣នាក់ ស្មើនឹង១៧.៦% ហើយប្រាក់ចំណូលមធ្យមមាន ២២៤ដុល្លារ បុគ្គលដែលមានបទពិសោធការងារ រយៈពេល ៤ឆ្នាំ មានចំនួន ១៤នាក់ ស្មើនឹង១០.៧% ហើយប្រាក់ចំណូលមធ្យមមាន ២២៤ដុល្លារ បុគ្គលដែលមានបទពិសោធការងាររយៈពេល ៥ឆ្នាំ មានចំនួន៦នាក់ ស្មើនឹង៤.៦% ហើយប្រាក់ចំណូលមធ្យមមាន ៣២១ដុល្លារ បុគ្គលដែលមានបទពិសោធការងាររយៈពេល ៦ឆ្នាំ មានចំនួន៣នាក់ ស្មើនឹង២.៣% ហើយប្រាក់ចំណូលមធ្យមមាន ២៦០ដុល្លារ បុគ្គលដែលមានបទពិសោធការងាររយៈពេល ៧ឆ្នាំ មានចំនួន១នាក់ ស្មើនឹង០.៨% ហើយប្រាក់ចំណូលមធ្យមមាន ៤៥០ដុល្លារ បុគ្គលដែលមានបទពិសោធការងាររយៈពេល ៨ឆ្នាំ មានចំនួន៣នាក់ ស្មើនឹង២.៣% ហើយប្រាក់ចំណូលមធ្យមមាន ២៩០ដុល្លារ បុគ្គលដែលមានបទពិសោធការងាររយៈពេល ១០ឆ្នាំ មានចំនួន ២នាក់ ស្មើនឹង១.៥% ហើយប្រាក់ចំណូលមធ្យមមាន ៤១០ដុល្លារ បុគ្គលដែលមាន បទពិសោធការងាររយៈពេល ១៣ឆ្នាំ មានចំនួន១នាក់ ស្មើនឹង០.៨% ហើយប្រាក់ចំណូលមធ្យមមាន ៥៥០ដុល្លារ បុគ្គលដែលមានបទពិសោធការងាររយៈពេល ១៩ឆ្នាំ មានចំនួន១នាក់ ស្មើនឹង០.៨ ហើយប្រាក់ចំណូលមធ្យមមាន ៦០០ដុល្លារ។

### ៣.២.២.១០ ការវិភាគប្រាក់ចំណូលបុគ្គល និងកត្តាដែលធ្វើអោយប្រែប្រួល

**តារាងទី១៧៖** វិភាគប្រាក់ចំណូលបុគ្គល និងកត្តាដែលធ្វើឱ្យប្រែប្រួល

| កត្តាដែលធ្វើឱ្យប្រែប្រួលប្រាក់ចំណូលបុគ្គល | ប្រាក់ចំណូលជាមធ្យម (ដុល្លារ) | ចំនួន (នាក់) | ភាគរយ% |
|---|---|---|---|
| លទ្ធផលការងារ | ២៤១ | ៦២ | ៤៥.៦% |
| ភាពស្មោះត្រង់ក្នុងការងារ | ២១៤ | ១២ | ៨.៨% |
| ការងារបន្ថែមម៉ោង | ២១៣ | ៤៣ | ៣១.៦% |
| របរបន្ថែម | ២៣៩ | ១០ | ៧.៤% |

| | | | |
|---|---|---|---|
| ផ្សេងពីនេះ | ១៧១ | ៩ | ៦.៦% |
| សរុប | ២២៥ | ១៣៦ | ១០០% |

តាមតារាងទី១៧ ខាងលើបានបង្ហាញថា៖ ប្រាក់ចំណូលបុគ្គល និងកត្តាដែលធ្វើឱ្យប្រែប្រួលដែលបានផ្តល់ការសម្ភាសន៍សរុបមានចំនួន ១៣៦នាក់ ហើយប្រាក់ចំណូលមធ្យមមាន ២២៥ដុល្លារ ក្នុងនោះបុគ្គលចំនួន ៦២នាក់ ស្មើនឹង៤៥.៦% ហើយប្រាក់ចំណូលមធ្យមមាន ២៤១ ដុល្លារ បានគិតថា កត្តាដែលធ្វើអោយប្រាក់ចំណូលប្រែប្រួលគឺដោយសារ លទ្ធផលការងារ បុគ្គលចំនួន ១២នាក់ ស្មើនឹង៨.៨% ហើយប្រាក់ចំណូលមធ្យមមាន ២១៩ដុល្លារ បានគិតថា កត្តាដែលធ្វើឱ្យ ប្រាក់ចំណូលប្រែប្រួលគឺដោយសារ ភាពស្មោះត្រង់ក្នុងការងារ បុគ្គលចំនួន ៤៣នាក់ ស្មើនឹង៣១.៦% ហើយប្រាក់ចំណូលមធ្យមមាន ២១៣ដុល្លារ បានគិតថា កត្តាដែលធ្វើអោយប្រាក់ចំណូលប្រែប្រួលគឺដោយសារ ការងារបន្ថែមម៉ោង បុគ្គលចំនួន ១០នាក់ ស្មើនឹង៧.៤% ហើយប្រាក់ចំណូលមធ្យមមាន ២៣៩ដុល្លារ បានគិតថា កត្តាដែលធ្វើអោយប្រាក់ចំណូលប្រែប្រួលគឺដោយសារ របរបន្ថែម បុគ្គលចំនួន ៩នាក់ ស្មើនឹង៦.៦% ហើយប្រាក់ចំណូលមធ្យមមាន ១៧១ ដុល្លារ បានគិតថា កត្តាដែលធ្វើឱ្យប្រាក់ចំណូលប្រែប្រួលគឺដោយសារ កត្តាផ្សេងពីនេះ។

### ៣.៣ លទ្ធផលស្រាវជ្រាវ

**តារាងទី១៨៖** ការធ្វើតេស្តលទ្ធផលស្រាវជ្រាវ

| អថេរ | មេគុណ | P-Valule |
|---|---|---|
| ចំនួនអថេរ | -១៧៥.៣០៥ | 0.0៣៩ |
| ចំនួនឆ្នាំដែលបានរៀន | ២0.៤៦១ | 0.000 |
| ចំនួនឆ្នាំបទពិសោធ | ១៦.៥៥៥ | 0.000 |
| ជំនាញ | ៤៦.១១៤ | 0.00២ |
| ភេទ | ២២.៨១២៥ | 0.១២៥ |
| R-Squar | 0.៤៤៦ | |
| F | ២៤.៥៣៦ | |
| n | ១២៦ | |

- **មេគុណនៃចំនួនឆ្នាំដែលបានរៀន (២០.៩៦១$)** ៖ ជាចំនួនវិជ្ជាមានមានន័យថា ប្រាក់ចំណូលជាអនុគមន៍កើននៃចំនួនឆ្នាំដែលបុគ្គលម្នាក់ៗបានសិក្សារៀនសូត្រ។
- **មេគុណចំនួនឆ្នាំបទពិសោធ (១៦.៥៥៥$)** ៖ ជាចំនួនវិជ្ជមានមានន័យថា ប្រាក់ចំណូលជាអនុគមន៍កើននៃចំនួនឆ្នាំដែលបុគ្គលម្នាក់ៗបានធ្វើការងារ។
- **មេគុណជំនាញ (៩៦.១១៩$)** ៖ ជាចំនួនវិជ្ជមានមានន័យថា ប្រាក់ចំណូលជាអនុគមន៍កើនចំពោះការងារដែលត្រូវជំនាញរបស់បុគ្គលម្នាក់ៗ។
- **ករណីភេទ (២២.៨១២៥$)** ៖ ក្នុងករណីនេះភេទមិនមានឥទ្ធិពលទៅលើប្រាក់ចំណូលទេ (ពីព្រោះ P-value > 10%) ។

# សេចក្ដីសន្និដ្ឋាន

# និងអនុសាសន៍

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

យោងតាមការស្រាវជ្រាវ និងការអង្កេតក្នុងស្នាដៃសារណានេះ យើងអាចសន្និដ្ឋានបានថា ការអប់រំ បទពិសោធក្នុងការងារ និងជំនាញក្នុងការងារពិតជាមានសារៈសំខាន់សម្រាប់លើកម្ពស់ប្រាក់ចំណូលរបស់បុគ្គលម្នាក់ៗនៅក្នុងប្រទេសកម្ពុជាដូចបានចែងនៅក្នុងទ្រឹស្តី (Eric, Hanushek A; L, Wobmann) ។ ម្យ៉ាងវិញទៀត តាមលទ្ធផលស្រាវជ្រាវបានឱ្យដឹងថា យេនឌ័រគ្មានឥទ្ធិពលទៅលើប្រាក់ចំណូល ឡើយ។

ទន្ទឹមគ្នានេះ បុគ្គលដែលធ្វើការងារក្នុងផ្នែក ទីផ្សារ គ្រប់គ្រង ច្បាប់ និងគ្រូបង្រៀន (តារាងទី១៨) តាមលទ្ធផលស្រាវជ្រាវបានបង្ហាញថា ពួកគេទទួលបានប្រាក់ចំណូលច្រើនជាងផ្នែកផ្សេងៗក្នុងតម្រូវការទីផ្សារ។ នេះក៏ដោយសារ ពួកគេដឹងពីតម្រូវការទីផ្សារ ដូច្នេះពួកគេអាចរកសាលាសិក្សាលើមុខវិជ្ជាដែលត្រូវជំនាញ។

បុគ្គលម្នាក់ៗ គួរសិក្សារៀនសូត្រឱ្យបានច្រើន ទទួលយកនូវបទពិសោធថ្មីៗ និងបង្កើនជំនាញសមត្ថភាពផ្ទាល់ខ្លួនឱ្យបានល្អប្រសើរ និងជ្រើសរើសរកមុខវិជ្ជាណាដែលអាចផ្គត់ផ្គង់តម្រូវការទីផ្សារ ជាជាងសិក្សាលើមុខវិជ្ជាដែលតម្រូវការទីផ្សារមានការថយចុះ (តម្រូវការឆ្អែត) នាពេលបច្ចុប្បន្ន។ ដូចនេះ បុគ្គលត្រូវសិក្សាឱ្យបានច្រើនដើម្បីលើកម្ពស់ជីវភាព នឹងឈានទៅជំរុញវិសាលភាពនៃកំណើនសេដ្ឋកិច្ច ការអភិវឌ្ឍសង្គមអោយកាន់តែប្រសើរ។

## ២.អនុសាសន៍

ដើម្បីបង្កើនប្រាក់ចំណូលឱ្យបានល្អប្រសើរ បុគ្គលម្នាក់ៗគួរពិចារណាលើវិធីសាស្ត្រងាយៗដូចតទៅ៖

**ទីមួយ៖** បុគ្គលម្នាក់ៗ គួរសិក្សានូវមុខវិជ្ជាដែលខ្លួនពេញចិត្ត និងត្រូវតាមតម្រូវការទីផ្សារ ព្រមទាំងអាចទទួលបានចំណូលល្អប្រសើរសម្រាប់ផ្គង់ផ្គង់ជីវភាពប្រចាំថ្ងៃ និងក្រុមគ្រួសារ។

**ទីពីរ៖** បុគ្គលម្នាក់ៗ គួរសិក្សារៀនសូត្រយ៉ាងហោចណាស់ត្រឹមកម្រិតបរិញ្ញាបត្រ ពីព្រោះនៅកម្រិតនេះ វាអាចទទួលបានចំណូលមធ្យមល្អប្រសើរជាជាងកម្រិតដែលទាបជាងនេះ។

**ទីបី៖** បុគ្គលម្នាក់ៗ គួរបង្កើនសមត្ថភាពជំនាញរបស់ខ្លួនបន្ថែមទៀត ដោយការសិក្សារៀនសូត្រ វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីបង្កើនផលិតភាពការងារអោយបានល្អប្រសើរ។

**ទីបួនៈ** បុគ្គលម្នាក់ៗ គួរមានពង្រឹងបទសោធពិសោធបន្ថែមលើការងារជំនាញរបស់ខ្លួន ដើម្បីទទួលបានប្រាក់ចំណូលបន្ថែម។

**ទីប្រាំៈ** តាមការស្រាវជ្រាវបានឱ្យដឹងថា ការងារផ្នែក ទីផ្សារ គ្រប់គ្រង ច្បាប់ និងគ្រូបង្រៀន ជាការងារដែលទទួលបានប្រាក់ចំណូលច្រើនជាងផ្នែកផ្សេងៗដ៏ទៃទៀត ដូចនេះបុគ្គលម្នាក់ៗ គួរគប្បីងាកមកសិក្សាលើជំនាញទាំងនេះវិញ ដើម្បីទទួលបានប្រាក់ចំណូលល្អប្រសើរ។

**ទីប្រាំមួយៈ** បុគ្គលម្នាក់ៗ គួរតែខិតខំសម្រេចការងាររបស់ខ្លួនដែលក្រុមហ៊ុន ឬអង្គភាពរបស់ខ្លួនប្រគល់ឱ្យបានល្អប្រសើរ ពីព្រោះតាម (តារាងទី១៥) បានបង្ហាញថាលទ្ធផលការងារអាចធ្វើឱ្យចំណូលរបស់បុគ្គលនីមួយៗប្រែប្រួលបានតិច ឬច្រើន គឺអាស្រ័យលើលទ្ធផលការងារ។

# ឯកសារយោង

# ឯកសារយោង


1. ARAdmin. *Vietnam Education.* Aguest 29, 2012. http://www.asian-recipe.com/vietnam/vn-information/vietnam-education.html (ចូលបាន March 27, 2017 ).

2. Dy, Sideth S. ‶BACKGROUND: KHMER TRADITIONAL EDUCATION SYSTEM VERSUS THE FRENCH MODERN EDUCATION SYSTEM. *Strategies and Policies for Basic Education in Cambodia: Historical Perspectives, 2010: 92.*

   - Dy, Sideth S. ‶EDUCATION CRISIS AND DECLINE: 1970-1975.″ *Strategies and Policies for Basic Education in Cambodia: Historical Perspectives, 2010: 95.*

   - Dy, Sideth S. ‶EDUCATIONAL REHABILITATION AND RECONSTUCTION: 1979-1989.″ *Strategies and Policies for Basic Education in Cambodia: Historical Perspectives, 2010: 96.*

   - Dy, Sideth S.″ENHANGCING BACIS EDUCATION OPPORTUNITY: 1950-1960.″ *Strategies and Policies for Basic Education in Cambodia: Historical Perspectives, 2010: 94.*

   - Dy, Sideth S. ‶SCHOOLING ABOLITION: 1975-1979.″ *Strategies and Policies for Basic Education in Cambodia: Historical Perspectives, 2010: 95.*

3. *Education in Thailand.* Wikipedia. គ្មានថ្ងៃ.

   htpp://en.wikipedia.org/wiki/Education_in_Thailand (ចូលបាន March 15, 2017).

4. Eric, Hanushek A; L, Wobmann;. ‶Introduction.″ ក្នុង *Education and Economic Growth, 245-251. 2010.*

5. Hash Vongdara. "Economic Growth Part2."ក្នុង *Economic Growth Part2,* ដោយ Vongdara Hash, 4. 2017.

_ . Resources. Phnom Penh, Phnom Penh, 2017

6. International Labour Ogarnization. *Income Statistics*. 2017. http://www.ilo.org/global/statistics-and-databases/statistics-overview-and-topics/income/lang--en/index.htm. (ចូលបាន May 2, 2017).

7. Labour Market. 2017. http://www.investopedia.com/terms/l/labor-market.asp (ចូលបាន April 21, 2017).

8. OECD. *Strong Performers and Successful Reformers in Education.* 2013.

http://www.pearsonfundation.org/oecd/sigarpore.html#sthash.GL66kPf5.dpuf (ចូលបាន March 4, 2017).

9. "Structural Policy Country Notes Cambodia."PDF, OECD, 2013, 03.

10. កាអុន វ៉ាន់ឌី. "ជំពូក២ វត្តមានបារាំងនៅក្នុងស្រុកខ្មែរ." ក្នុសុបិន និងការពិត (ភាគ១), ដោយ កាអុន វ៉ាន់ឌី, ៩០. ប៉ារីស, ថ្ងៃទី៩ តុលា ឆ្នាំ២០១២.

11. ក្រសួងអប់រំ យុវជន និងកីឡា. *បឋមសិក្សា.* គ្មានថ្ងៃ. http://www.moeys.gov.kh/kh/primary-education.html#.U5xTDfmSxIE (ចូលបាន ឧសភា ១៥, ២០១៧).

- ឧត្តមសិក្សា.គ្មានថ្ងៃ. http://www.moeys.gov.kh/kh/higher-education.html#.U5xR1_mSxIE (ចូលបាន ឧសភា ១៥, ២០១៧).

- អប់រំកុមារតូច. គ្មានថ្ងៃ. http://www.moeys.gov.kh/kh/early-childhood.html#.U5xWhfmSxIE (ចូលបាន ឧសភា ១៥, ២០១៧).

- ក្រសួងអប់រំ យុវជន និងកីឡា. *អប់រំចំណេះទូទៅ.* គ្មានថ្ងៃ.

http://www.moeys.gov.kh/kh/general-secondary-education.html#.U5xQu_mSxIE (ចូលបាន ឧសភា ១៥, ២០១៧).

12. "គោលនយោបាយ យុទ្ធសាស្ត្រ សូចនាករស្នូល និងចំណុចដៅអប់រំ." ក្នុង *ផែនការ យុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០១៤-២០១៨, ១៧. ភ្នំពេញ, ភ្នំពេញ, ២០១៧.*

13. យួន, ធារ៉ា. *អ្នកស្រាវជ្រាវសុំឱ្យមានការយកចិត្តទុកដាក់លើការសិក្សាវិទ្យាសាស្ត្រ និងបច្ចេកទេស.* វិច្ឆកា ២៧, ២០១៣. http://m.khmer.voanews.com/a/education-in-cambodia-lagging-in-science-technology-experts-say/1798385.html (ចូលបាន ឧសភា ០៣, ២០១៧)

14. ឆាយ ច័ន្ទនីដា. *ដើម្បីពង្រឹងគុណភាពអប់រំរដ្ឋាភិបាលមិនអនុញ្ញាតឱ្យបើកសាកលវិទ្យាល័យថ្មី.* មេសា ០១, ២០១៤. http://postkhmer.com/national/1-national-news/112645-2014-04-01-04-09-41 (ចូលបាន ឧសភា ៣,២០១៧).

15. ណាត ប៊ុនរឿន. "របាយការណ៍បូកសរុបការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា ២០១២-២០១៣." ភ្នំពេញ, ២០១៤. ១២-១៤.

 - ណាត ប៊ុនរឿន. "របាយការណ៍បូកសរុបការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា ២០១២-២០១៣." ភ្នំពេញ, ២០១៤. ២០.
 - ណាត ប៊ុនរឿន. "របាយការណ៍បូកសរុបការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា ២០១២-២០១៣." ភ្នំពេញ, ២០១៤. ១១.
 - _. "របាយការណ៍បូកសរុបការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា ២០១២-២០១៣. " ភ្នំពេញ, ២០១៤. ១៥-១៧.

16. ទេព សូរ៉ន. "ផ្សារកត្តាផលិតកម្ម". ភ្នំពេញ, ២០១៧. (២-១០).

17. រិទ្ធី. *ក្នុងចំណោមពលរដ្ឋកម្ពុជា ៤នាក់ មានម្នាក់បានចូលសាលារៀន.* មីនា ១៩, ២០១៤. http://cen.com.kh/localnews/show_detail/24?token=YTdiNDU1ND#sthash.gFjg9JYD.dpuf (ចូលបាន មេសា ២៥,២០១៧).

18. ស៊ិនសុឃុន, និង សិក ហេងឡុង. "ផ្នែកទី២៖ ប្រទេសកម្ពុជា." ក្នុង *ប្រព័ន្ធនីតិ អាស៊ាន,* ដោយ សុឃុន ស៊ិន និង ហេងឡុង សិក, ២៣៩. ភ្នំពេញ, ២០១២.

– ស៊ិន សុឃុន និង សិក ឡុងហេង. "ផ្នែកទី៨៖ ប្រទេសសិង្ហបុរី." ក្នុង *ប្រព័ន្ធនីតិ អាស៊ាន ,* ដោយ សុឃុន ស៊ិន និង ហេងឡុង សិក, ២៣៩. ភ្នំពេញ, ខែតុលា ឆ្នាំ ២០១២.

19. សន្និបាតបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា ២០១២-២០១៣ និងទិសដៅឆ្នាំសិក្សា២០១៣-២០១៤. "PDF", ក្រសួងអប់រំ យុវជន និងកីឡា; ភ្នំពេញ, ២០១៧, ៣១, ៣៣.

– "សន្និបាតបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា២០១២-២០១៣និងទិសដៅឆ្នាំសិក្សា២០១៣-២០១៤."PDF, ក្រសួងអប់រំ យុវជន និងកីឡា; ភ្នំពេញ, ២០១៧, ២០, ២១.

– "សន្និបាតបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា២០១២-២០១៣និងទិសដៅឆ្នាំសិក្សា២០១៣-២០១៤."PDF, ក្រសួងអប់រំ យុវជន និងកីឡា; ភ្នំពេញ, ២០១៧, ៤១.

– "សន្និបាតបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា២០១២-២០១៣និងទិសដៅឆ្នាំសិក្សា២០១៣-២០១៤."PDF, ក្រសួងអប់រំ យុវជន និងកីឡា; ភ្នំពេញ, ២០១៧, ៩.

– "សន្និបាតបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា២០១២-២០១៣និងទិសដៅឆ្នាំសិក្សា២០១៣-២០១៤."PDF, ក្រសួងអប់រំ យុវជន និងកីឡា; ភ្នំពេញ, ២០១៧, ៥៤.

– "សន្និបាតបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា២០១២-២០១៣និងទិសដៅឆ្នាំសិក្សា២០១៣-២០១៤."PDF, ក្រសួងអប់រំ យុវជន និងកីឡា; ភ្នំពេញ, ២០១៧, ៣៤.

20. សួង, សុភារី. *របាយការណ៍អប់រំសម្រាប់ទាំងអស់គ្នា ឆ្នាំ២០១៤៖ គុណភាពគ្រូបង្រៀន ជាបញ្ហាចម្បង.* មីនា ០៦, ២០១៤. http://www.khmer.rfi.fr/education-for-all-global-monitoring-report (ចូលបាន មេសា ០៥, ២០១៧).

21. ឯម មាឃ. *រដ្ឋមន្ត្រីអប់រំនឹងរឹបអូសសៀវភៅ"កម្មសិទ្ធរបស់រដ្ឋ"ដោយគ្មានសំណង.* កុម្ភៈ ០២, ២០១៤. http://www.khmer.rfi.fr/cambodia-education-book (ចូលបាន មេសា ២១, ២០១៧).

22. អ៊ុក សាវបូរី. *ក្រសួងប្រកាសកែទម្រង់និងពង្រឹងវិស័យអប់រំ.* តុលា ២១, ២០១៣. http://www.rfa.org/khmer/news/social-economy/ministry-of-education-reform-and-strenthen-education-10212013234341.html (ចូលបាន ឧសភា ១៩, ២០១៧)

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ១

# ផ្នែកទី៨ ប្រទេសសិង្ហបុរី

## ៨.១. ស្ថានភាពទូទៅ

### ៨.១.១. ឈ្មោះជាផ្លូវការ

សាធារណរដ្ឋសិង្ហបុរី

### ៨.១.២. រាជធានី

Singapore

### ៨.១.៣. ការបែងចែកតំបន់រដ្ឋបាល

ប្រទេសសិង្ហបុរី មាន២៨សង្កាត់។

### ៨.១.៤. ផ្ទៃដី

- ផ្ទៃដីសរុប ៖ ៧០៧.១ គម² (ឆ្នាំ២០០៨)
- ទីតាំង ៖ ប្រទេសសិង្ហបុរី ជារដ្ឋដីកោះ ឋិតនៅចុងខាងត្បូងនៃជ្រោយម៉ាឡេស៊ី ដែលជាប្រទេសមួយក្នុងចំណោមប្រទេសដែលមានដង់ស៊ីតេប្រជាជនច្រើនបំផុតលើពិភពលោក។
- អាកាសធាតុ៖ ត្រូពិច ក្ដៅហើយសើម។

### ៨.១.៥. ប្រជាពលរដ្ឋ

ក. ចំនួនប្រជាជនសរុប

- ៥.៣៥៣.៤៩៥នាក់ (ឆ្នាំ២០១២)
- ភាគរយភេទ៖ ០,៩៦ បុរស/ស្ត្រី (ឆ្នាំ២០១១)

ខ. ស្ថានភាពទូទៅរបស់ប្រជាជន

- អត្រាកំណើនប្រចាំឆ្នាំ៖ ១,៩៩៣% (ឆ្នាំ២០១២)
- អាយុជាមធ្យម៖៨៣,៧៥ឆ្នាំ បុរស៖ ៨១,៤៧ឆ្នាំ ស្ត្រី៖ ៨៦,២ឆ្នាំ (ឆ្នាំ២០១២)
- កម្លាំងពលកម្ម៖ ៣,២៣៧លាននាក់ (ឆ្នាំ២០១១)
- អត្រាគ្មានការងារធ្វើ៖ ២% (ឆ្នាំ២០១១)

គ. ក្រុមជនជាតិ

- ចិន៖ ៧៦%
- ម៉ាឡេ៖ ១៥%
- ឥណ្ឌា៖ ៧%
- អឺរ៉ុប-ជប៉ុន-ផ្សេងទៀត៖ ២%

ឃ. សាសនា

- Folk religions៖ ៤៣%
- ឥស្លាម៖ ១៨%

- ព្រះពុទ្ធ៖ ១៥%
- ហិនឌូ៖ ៥%
- Roman Catholic៖ ៤%
- Protestant៖ ៤%
- គ្មានសាសនា៖ ៥%
- ផ្សេងទៀត៖ ៦%។

ង. ភាសា

ចិន ម៉ាឡេ តាមិឡ្យ និងអង់គ្លេស (ផ្លូវការទាំងអស់)

ច. ការអប់រំ

- ការអប់រំនៅបឋមសិក្សា ( រយៈពេល៦ឆ្នាំ ជាកាតព្វកិច្ច )
- អត្រាអក្ខរភាពសរុប៖ ៩២,៥% បុរស៖ ៩៦,៦% ស្ត្រី៖ ៨៨,៦% (ឆ្នាំ២០០០)

ឆ. សុខភាព

- អត្រាមរណៈភាព៖ ៣,៤១នាក់/១០០០នាក់ (ឆ្នាំ២០១២)
- អត្រាមរណៈភាពកុមារ៖ ២,៦៥នាក់/១០០០នាក់ កើតរស់ (ឆ្នាំ២០១២)
- អត្រាមរណៈភាពមាតា៖ ៣នាក់/១០០.០០០នាក់ ស្ត្រីសម្រាលកូន (ឆ្នាំ២០១០)[៩៤០]

### ៨.១.៦. ការទទួលឯករាជ្យ

ថ្ងៃទី៩ ខែសីហា ឆ្នាំ១៩៦៥ ផ្តាច់ចេញពីសហព័ន្ធម៉ាឡេស៊ី

### ៨.១.៧. ធនធានធម្មជាតិ

ត្រី កំពង់ផែដែលមានជម្រៅជ្រៅ

### ៨.១.៨. សេដ្ឋកិច្ច

- ផលិតផលសរុបក្នុងស្រុក GDP៖
  - តាមតម្លៃទីផ្សារបច្ចុប្បន្ន = ២៥៩,៨ កោតដុល្លា (ឆ្នាំ២០១១)
  - GDP Per Capita (PPP) = ៦០៥០០US$ (ឆ្នាំ២០១១)
- អត្រាកំណើន GDP៖ ៤,៩% (ឆ្នាំ២០១១)
- សមាសភាព GDP តាមវិស័យ៖
  - កសិកម្ម៖ 0% (ឆ្នាំ២០១០)
  - ឧស្សាហកម្ម៖ ២៦,៦% (ឆ្នាំ២០១០)
  - សេវាកម្ម៖ ៧៣,៤% (ឆ្នាំ២០១០)

[៩៤០] Singapore-CIA- the world facebook, ១០ កញ្ញា ឆ្នាំ២០១២។

- រូបិយវត្ថុ៖ ដុល្លាសិង្ហបុរី
- ផលិតផលនាំចេញ៖ គ្រឿងម៉ាស៊ីន (ឧបករណ៍អេឡិចត្រូនិច និងទូរគមនាគមន៍) ឱសថ និងសារធាតុគីមី និងប្រេង។
- ដៃគូនាំចេញ៖ ប្រទេសម៉ាឡេស៊ី សហរដ្ឋអាមេរិក ហុងកុង ជប៉ុន តៃវ៉ាន់ ឥណ្ឌូនេស៊ី ។ល។
- ផលិតផលនាំចូល៖ គ្រឿងម៉ាស៊ីន និងឧបករណ៍នានា ប្រេងឆៅ សារធាតុគីមី ចំណីអាហារ និងប្រដាប់ប្រដាប្រើប្រាស់។
- ដៃគូនាំចូល៖ ប្រទេសដៃគូ មាន ជប៉ុន ម៉ាឡេស៊ី ចិន តៃវ៉ាន់ សហរដ្ឋអាមេរិក និង កូរ៉េខាងត្បូង។

#### ៨.១.៩. ការចូលជាសមាជិកអង្គការផ្សេងៗ

ADB, AOSIS, APEC, ARF, ASEAN, BIS, C, CP, EAS, FATF, G-77, IAEA, IBRD, ICAO, ICC, ICRM, IDA, IFC, IFRCS, IHO, ILO, IMF, IMO, IMSO, Interpol, IOC, IPU, ISO, ITSO, ITU, ITUC, MIGA, NAM, OPCW, PCA, UN, UNCTAD, UNESCO, UNMIT, UPU, WCO, WHO, WIPO, WMO, WTO។[៦៨៦]

### ៨.២. ប្រព័ន្ធនយោបាយគ្រប់គ្រង

#### ៨.២.១. ប្រវត្តិនៃការគ្រប់គ្រងប្រទេស

កាលពីដើមឡើយ ប្រទេសសិង្ហបុរីជាផ្នែកមួយនៃប្រទេសម៉ាឡេស៊ី ដែលមានមនុស្សរស់នៅប្រហែលតែ ១៥០នាក់ ប៉ុណ្ណោះ។ កាលនោះទឹកដីម៉ាឡេស៊ីនៅក្រោមអាណានិគមរបស់ប្រទេស Portugal នៅឆ្នាំ១៥៨១។ ក្រោយមកនៅឆ្នាំ១៦៤១ ប្រទេសហូឡង់បានដាក់អាណានិគមជំនួស Portugal ។ អង់គ្លេសបានដាក់អាណានិគមទៅលើប្រទេសឥណ្ឌា និងចិន ហើយដោយចង់ធ្វើដំណើរពីប្រទេសខ្លួនមកកាន់ប្រទេសក្រោមអាណានិគមទាំងពីររបស់ខ្លួន អង់គ្លេសមានគំនិតចង់ដណ្តើមកោះម៉ាឡេស៊ីមកធ្វើជារបស់ខ្លួន។

- នៅឆ្នាំ១៧៩៤ អង់គ្លេសបានបណ្តេញ ហូឡង់ ចេញពីម៉ាឡេស៊ី។
- នៅឆ្នាំ១៨១៩ អង់គ្លេសបានចូលដល់កោះសិង្ហបុរី ដែលពេលនោះមានមនុស្សរស់នៅតែ ១៥០នាក់ប៉ុណ្ណោះ ភាគច្រើនជាអ្នកនេសាទ និងជាអ្នកជំនួញចិន។
- នៅឆ្នាំ១៨២៤ អង់គ្លេសបានត្រួតត្រាប្រទេសម៉ាឡេស៊ីពេញលេញ ដែលកាលនោះនៅសិង្ហបុរីគ្មានច្បាប់ទំលាប់ទេ ដោយឃើញមានមនុស្សមករស់នៅកាន់តែច្រើនឡើងៗថែមទៀតនោះ ប្រទេសអង់គ្លេសក៏បានរៀបចំឱមានរចនាសម្ព័ន្ធរដ្ឋបាល(ឆ្នាំ១៨២៦) ដោយយកបែបបទតាមច្បាប់អង់គ្លេសទាំងស្រុង ដែលប្រើប្រាស់ច្បាប់នេះជាប្រៀងរហូតមក

[៦៨៦] Singapore-CIA- the world facebook, ១០ កញ្ញា ឆ្នាំ២០១២។

# Strong Performers and Successful Reformers in Education

A strong education system has enabled Singapore to develop a modern vibrant economy. Well trained and highly motivated teachers are central to its success.

FILMS: Select a Country ▾

# Singapore





+ Embed + Download + Transcripts

## Key facts

A city state with a population of five million in an area of around 700 square kilometres, Singapore has made high-quality education the cornerstone of its economic development. High teaching standards support a culture of continuous

## Building a strong and effective teaching force

As a sovereign state since 1965, Singapore is one of Asia's great success stories. In less than half a century, it has transformed itself from a developing country to a vibrant modern economy. Education has been central to this process and a focus on teacher training and strong school leadership has been one of the key factors in Singapore's success.

A stable government under the same political party has provided a basis for stable education policies. Since the 1990s, Singapore has developed a comprehensive system



Read the full report

*benchmark Singapore's practices against the best in the world and yet take into account the local context.*

- Singapore is a multi-ethnic society comprising primarily of ethnic Chinese, Malays and Indians. English is the language of government and workplace. Since the 1980s, English has been the primary medium of instruction in schools. Students also receive instruction in their mother tongue language — primarily Malay, Tamil or Chinese. About 59 percent of students speak a language other than English at home.

- In 2010, Singapore spent the equivalent of 3.1% of its gross domestic product on education, approximately 20% of total government expenditure and second only to defense.

- With approximately 522,000 students and 360 schools, Singapore's education system has the advantage of being small in scale. Students receive six years of primary education and four to five years of secondary education.

- In Grades 9-10, class sizes in Singapore are bigger than in most OECD countries (class size for lessons in the language of instruction is 36 students in Singapore, while the OECD average is 25), and children spend more time in class. Grade 9-10 students in Singapore spend an average of 3 hours 21 minutes per week in regular lessons at school in the language of instruction (OECD average 3 hours 37 minutes), an average of 4 hours 54 minutes in regular lessons at school in mathematics (OECD average 3 hours 34 minutes) and an average of 4 hours 27 minutes in regular lessons at school in science (OECD average 3 hours 22 minutes).

the delivery of high-quality education that in turn would lead to high-quality student outcomes.

Teaching is a greatly honored profession, in part because the standards for selection are high. Prospective teachers are selected from the top one-third of each cohort by panels that include current principals. Strong academic ability and non-academic qualities are essential considerations during the recruitment process, such that only candidates who possess the character, aptitude and abilities to teach and develop students are recruited as teachers.

Once accepted for training, prospective teachers receive full tuition as well as a monthly stipend that is competitive with the monthly salary of fresh graduates in other fields. All teachers are trained at the National Institute of Education (NIE), part of Singapore's Nanyang Technological University. They study either a diploma, postgraduate diploma, or a degree course depending on their level of education at entry, and they must commit to teaching for at least three years.

There is a close working relationship between the NIE and schools. The Ministry of Education keeps a close watch on salaries to ensure that teaching remains an attractive occupation for new graduates, and high-performing teachers can earn significant additional amounts in performance bonuses.

To keep pace with change and be able to constantly improve their practice, teachers are entitled to 100 hours of professional development per year, mostly at no cost to the teacher. Like many other professions in Singapore, teachers are appraised annually. Their appraisal takes into account their contribution to the academic and character development of their students, their collaboration with parents and community groups, and their contribution to colleagues and the school as a whole. It also helps them identify areas of growth that form the basis of personal professional development plans. Poor-performing teachers are also given help and leave the service only if they do not improve.

All new teachers are mentored in their first few years in the service. Teachers with the potential to take up school leadership are continuously assessed for their leadership capabilities and given opportunities to learn and to demonstrate their abilities, for example by serving on committees, by being promoted to head of department and through short stints working in the Ministry of Education. Through these experiences, potential vice-principals are selected for interviews and go through leadership situational exercises. If they pass these, they go on to NIE for six months of executive leadership training — this includes an international study trip and a project on school innovation. Only 30-40 people per year are selected for this "Leaders in Education" course, a milestone program to prepare potential principals. The Ministry regularly posts principals to different schools as part of leadership renewal and talent circulation.

- Civics and moral education in schools plays a major role in inculcating values of honesty, commitment to excellence, teamwork, discipline, loyalty, humility and national pride and places an emphasis on the common good.

## Outcomes

Singapore students regularly rank among the top scorers in international assessments. They were among the top performers in the PISA tests in 2009, the first time Singapore participated in PISA.

- Singapore students scored an average 526 points in reading in PISA 2009, putting Singapore among the top eight participating education systems. 15.7% of Singapore students achieved Levels 5 and 6, against an average of 7.6% for OECD countries.
- In mathematics, Singapore students scored an average 562 points, surpassed only by students in Shanghai, China. In science, Singapore students scored 542 points, putting Singapore among the top four education systems.

## Resources

- PISA 2009 at a Glance
- Singapore: Rapid Improvement Followed by Strong Performance

OECD BETTER POLICIES FOR BETTER LIVES

**The OECD Programme for International Student Assessment (PISA)**

PEARSON FOUNDATION

©2013 Pearson Foundation | Terms of Use | Privacy Statement
The opinions expressed and arguments employed herein do not necessarily reflect the official views of the OECD or of the governments of its member countries

# ផ្នែកទី៩ ប្រទេសថៃ

## ៩.១. ស្ថានភាពទូទៅ

### ៩.១.១. ឈ្មោះជាផ្លូវការ

ព្រះរាជាណាចក្រថៃឡង់ដ៍

### ៩.១.២. រាជធានី

បាងកក ទីក្រុងផ្សេងទៀតមាន Nakhon Ratchasima, Chiang Mai

### ៩.១.៣. ការបែងចែកតំបន់រដ្ឋបាល

- ការបែងចែករដ្ឋបាល៖ ៧៧ខេត្ត ៨៧៧ស្រុក
- តំបន់រដ្ឋបាល៖ ៧២៥៥ ភូមិ៖ ៧៤៩៤៤

### ៩.១.៤. ផ្ទៃដី

- ផ្ទៃដីសរុប៖ ៥១៣.០២០គម² (ដីគោក៖ ៥១០.៨៩០គម² ដីទឹក៖ ២២៣០គម²)
- អាកាសធាតុ៖ ត្រូពិចមូសុង

### ៩.១.៥. ប្រជាពលរដ្ឋ

ក. ប្រជាជន

- ប្រជាជនសរុប៖ ៦៧.០៩១.០៨៩នាក់ (ឆ្នាំ២០១២)

ខ. កម្លាំងពលកម្ម

- កម្លាំងពលកម្ម ៣៩,៦២លាននាក់(ឆ្នាំ២០១១)
- អត្រាអត់ការងារធ្វើ៖ ០,៧% (ឆ្នាំ២០១១)
- អ្នករស់នៅក្រោមបន្ទាត់ក្រីក្រ៖ ៨,១% (ឆ្នាំ២០០៩)

គ. ស្ថានភាពទូទៅរបស់ប្រជាជន

- អត្រាកំណើនប្រចាំឆ្នាំ៖ ០,៥៤៣% (ឆ្នាំ២០១២)
- អត្រាកំណើត៖ ១២,៨១នាក់/១០០០នាក់ (ឆ្នាំ២០១២)
- ភាគរយភេទ៖ ០,៩៨% ប្រុស/ស្រី (ឆ្នាំ២០១២)
- អត្រាមរណភាព៖ ៧,៣៨នាក់/១០០០នាក់ (ឆ្នាំ២០១២)
- អាយុជាមធ្យម៖ ៧៣,៨៣ឆ្នាំ បុរស៖ ៧១,៤៥ឆ្នាំ ស្ត្រី៖ ៧៦,៣៣ឆ្នាំ (ឆ្នាំ២០១២)[១៤៣]

ឃ. ក្រុមជនជាតិ

- ថៃ៖ ៧៥%
- ចិន៖ ១៤%

[១៤៣] Thailand-CIA- the world facebook, ១០កញ្ញា ឆ្នាំ២០១២។

- ក្រុមជនជាតិផ្សេងទៀត ១១%

ង. សាសនា

- ព្រះពុទ្ធ៖ ៩៤% (សាសនាផ្លូវការ)
- ឥស្លាម៖ ៥%
- គ្រឹស្ត៖ ១%

ច. ភាសា

- ថៃ (ផ្លូវការ)
- ភាសាអង់គ្លេស ជាភាសាទី២
- ភាសាចិន
- ម៉ាឡេ និង
- ភាសាតំបន់ផ្សេងទៀត

ឆ. ការអប់រំ

- សិក្សា ១២ឆ្នាំជាកាតព្វកិច្ច
- អត្រាអក្ខរកម្ម៖ ៩២,៦ បុរស៖ ៩៤,៩% ស្ត្រី៖ ៩០,៥%

ជ. សុខាភិបាល

- អត្រាមរណភាពកុមារ៖ ១៥,៩នាក់/១០០០ទារកកើតរស់
- អត្រាមរណភាពមាតា៖ ៤៨នាក់/១០០.០០០ ស្ត្រីសម្រាលកូន

### ៩.១.៦. ការទទួលឯករាជ្យ

ឆ្នាំ១២៣៨ មិនដែលស្ថិតនៅក្រោមអាណានិគម

### ៩.១.៧. ធនធានធម្មជាតិ

សំណប៉ាហាំង កៅស៊ូ ឧស្ម័នធម្មជាតិ ឈើ ត្រី ម្នាងសិលា ត្បូងអរ ត្បូងថ្ម។ល។

### ៩.១.៨. សេដ្ឋកិច្ច

- ផលិតផលក្នុងស្រុកសរុប GDP៖ ៣៤៥,៦កោដិដុល្លា (ឆ្នាំ២០១១)
- អត្រាកំណើន GDP៖ ០,១% (ឆ្នាំ២០១១)
- GDP Per Capita (PPP)៖ ៩៥០០ដុល្លា (ឆ្នាំ២០១១)
- សមាសភាព GDP តាមវិស័យ៖
    - កសិកម្ម៖ ១៣,៣% (ឆ្នាំ២០១១)
    - ឧស្សាហកម្ម៖ ៣៤% (ឆ្នាំ២០១១)
    - សេវាកម្ម៖ ៥២,៧% (ឆ្នាំ២០១១)

- រូបិយវត្ថុ៖ បាត (B)
- អតិផរណា៖ ៣,៨% (ឆ្នាំ២០១១)
- ទំនិញនាំចេញ៖ វាយនភ័ណ្ឌ សំលៀកបំពាក់ ទំនិញអេឡិចត្រូនិច បង្គា អង្ករ កៅស៊ូ ត្បូងថ្ម ជ័រឡុង និងស្ករ ។ ប្រទេសដៃគូមាន ចិន ឥណ្ឌូនេស៊ី សហរដ្ឋអាមេរិក ជប៉ុន សិង្ហបុរី ហុងកុង និងម៉ាឡេស៊ី។ល។
- ទំនិញនាំចូល៖ ប្រេង ផលិតផលប្រេង គ្រឿងយន្ត និងគ្រឿងគីមី។ប្រទេសដៃគូមាន ជប៉ុន កូរ៉េខាងត្បូង សហរដ្ឋអាមេរិក សិង្ហបុរី ចិន ហុងកុង និងម៉ាឡេស៊ី។ល។

### ៥.១.៥. ការចូលជាសមាជិកអង្គការផ្សេងៗ

ADB, APEC, ARF, ASEAN, BIMSTEC, BIS, CICA, CP, EAS, FAO, G-77, IAEA, IBRD, ICAO, ICC, ICRM, IDA, IFAD, IFC, IFRCS, IHO, ILO, IMF, IMO, IMSO, Interpol, IOC, IOM, IPU, ISO, ITSO, ITU, ITUC, MIGA, NAM, OAS (observer), OIC (observer), OIF (observer), OPCW, OSCE (partner), PCA, PIF (partner), UN, UNAMID, UNCTAD, UNESCO, UNHCR, UNIDO, UNWTO, UPU, WCO, WFTU, WHO, WIPO, WMO, WTO។[៥៨៨]

## ៥.២. ប្រព័ន្ធនយោបាយគ្រប់គ្រង

### ៥.២.១. ប្រវត្តិនៃការគ្រប់គ្រងប្រទេស

ខាងផ្នែកប្រព័ន្ធនីតិ ព្រះអង្គម្ចាស់ រាជបុរី ឌិរិក្រិត (Rajburi Direkrit) ត្រូវបានគេចាត់ទុកជាបិតាស្ថាបនិកច្បាប់ថៃទំនើប (Founder of Thai Modern Law)។ ព្រះអង្គជាព្រះរាជបុត្រទី១៤ នៃព្រះមហាក្សត្រ ជូឡាឡុងករ (King Chulalongkorn) ហើយទ្រង់ជូឡាឡុងករ ជាព្រះរាជាទី១៥ នៃរាជវង្សចក្រី និងចៅចមម៉ាន់ដា តាឡុព (The Fifth King of the Chakri Dynasty and Choa Chom Manda Ta-Lup)។ ទ្រង់រាជបុរី (Rajburi) ប្រសូត្រនៅថ្ងៃទី២១ ខែតុលា ឆ្នាំ១៨៧៤ ហើយព្រះអង្គបានយាងទៅសិក្សាវិស័យច្បាប់នៅប្រទេសអង់គ្លេស នៅសាលា (Christ Church College)សាកលវិទ្យាល័យអុកស្វ័ត (Oxford University) ហើយព្រះអង្គទ្រង់ទទួលបានបរិញ្ញាបត្រច្បាប់ផ្នែកយុត្តិសាស្ត្រប្រកបដោយកិត្តិយសនាឆ្នាំ១៨៩៦ (Graduate Bachelor of Arts "Jurisprudence with honours in 1896 ") ។ នៅពេលព្រះអង្គវិលត្រលប់មកកាន់ប្រទេសថៃវិញ ព្រះអង្គបានកាន់តួនាទីជាច្រើន ដូចជា Privy Counciler ប្រធានគណៈកម្មការពិសេសកំណែទម្រង់ប្រព័ន្ធតុលាការ (President of the special commission) និងធ្វើមានវឌ្ឍនភាពលើរឿងជាច្រើនទូទាំងព្រះរាជាណាចក្រ។ព្រះអង្គជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ព្រះប្រធានគណៈកម្មាធិការកំណែទម្រង់ផ្នែកច្បាប់ និងជារដ្ឋមន្ត្រីក្រសួងកសិកម្ម (Minister of Justice, President of the Law Reform

[៥៨៨] Thailand-CIA- the world facebook, ១០កញ្ញា ឆ្នាំ២០១២។

Committee and Minister of Agriculture)។

នៅពេលព្រះអង្គជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ព្រះអង្គជាព្រះប្រធានគណៈកម្មការពិសេសធ្វើកំណែទម្រង់ច្បាប់ជាច្រើនពាក់ព័ន្ធតុលាការ ។ គណៈកម្មការពិសេសនេះប្រមូលផ្តុំ និងចងក្រងជាក្រមនូវច្បាប់ជាច្រើន។ជាលទ្ធផល ក្រមព្រហ្មទណ្ឌថៃដំបូងបំផុតត្រូវបានដាក់ឲប្រើប្រាស់។នៅពេលនោះប្រព័ន្ធតុលាការ និងការងាររដ្ឋបាលក្រសួងយុត្តិធម៌នៅមានកម្រិតទាប និងហួសសម័យ។ ព្រះអង្គជាអ្នកកែទម្រង់ និងធ្វើទំនើបនីយកម្មប្រព័ន្ធតុលាការ និងការងាររដ្ឋបាលក្រសួងយុត្តិធម៌ ព្រះអង្គជាកម្លាំងដ៏សំខាន់មួយដែលនៅពីក្រោយការកែប្រែក្រមនីតិវិធីព្រហ្មទណ្ឌ និងរដ្ឋប្បវេណី។

នៅពេលដែលព្រះអង្គជាប់ព្រះទ័យយ៉ាងជ្រៅលើការអប់រំផ្នែកច្បាប់នៅឆ្នាំ១៨៩៧ សាលាច្បាប់ដំបូងរបស់ថៃបានបង្កើតឡើងដោយស្នាព្រះហស្តព្រះអង្គ ហើយគឺនៅទីនោះហើយដែលព្រះអង្គបានបង្រៀនលើមុខវិជ្ជាជាច្រើន ។ និស្សិតជាច្រើនដែលបានបញ្ចប់ការសិក្សានៅសាលានេះ គឺជាជំនួយការយ៉ាងធំធេងចំពោះតុលាការយុត្តិធម៌ ។ ព្រះអង្គបានសរសេរសៀវភៅសិក្សាជាច្រើនពាក់ព័ន្ធផ្នែកច្បាប់នានា និងបានបោះពុម្ពផ្សាយរបាយការណ៍ជាច្រើន ស្តីពី បណ្តឹងតុលាការ និងរដ្ឋបាលក្រសួងយុត្តិធម៌ដែលផ្តល់ផលប្រយោជន៍យ៉ាងធំធេងចំពោះតុលាការ មេធាវី និងសាធារណជនទាំងមូល។

ព្រះអង្គទ្រង់ចូលទីវង្គតនៅថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩២០។ ជាការរំលឹកដល់ការបូជាដ៏ធំធេងចំពោះប្រព័ន្ធច្បាប់របស់ប្រទេស ថ្ងៃទី០៧ ខែសីហា ត្រូវបានឲឈ្មោះថា Rabi Dayបន្ទាប់ពីឈ្មោះដើមរបស់ព្រះអង្គ។ ជារៀងរាល់ឆ្នាំអ្នកច្បាប់ និស្សិតច្បាប់ បានបំពាក់កំរងផ្កាដល់រូបសំណាករបស់ព្រះអង្គដែលស្ថិតនៅពីមុខក្រសួងយុត្តិធម៌ ដើម្បីសំដែងការកោតសរសើរ និងគោរពចំពោះព្រះអង្គ។

### ៩.២.២. ការគ្រប់គ្រងប្រទេស

ក. របបនយោបាយ

- ទម្រង់រដ្ឋាភិបាល៖ រាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ
- ប្រមុខរដ្ឋ៖ ព្រះមហាក្សត្រ (Phum Phon Adunyadet ឬ ហៅ Bhumibol Adulyadet) ព្រះមហាក្សត្របន្តរាជវង្ស
- ប្រមុខរដ្ឋាភិបាល៖ នាយករដ្ឋមន្ត្រី(Yinglak Chin Nawat)

ខ. រដ្ឋធម្មនុញ្ញ

រដ្ឋធម្មនុញ្ញ៖ រដ្ឋធម្មនុញ្ញចុងក្រោយអនុម័តដោយធ្វើប្រជាមតិថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៧

គ. អំណាចនីតិបញ្ញត្តិ

សភាថៃ ត្រូវបានបង្កើតឡើងនៅក្នុងរដ្ឋធម្មនុញ្ញបណ្តោះអាសន្ននៅឆ្នាំ១៩៣២។ សភាជួបប្រជុំលើកទី១ នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៣២ នៅក្នុង Ananda Samakhom Throw Hall។ សភាជាតិថៃ គឺទ្វិកសភា ដែលរួមមាន សភា២៖ ព្រឹទ្ធសភា និងសភាតំណាង។

សភាជាតិមានសមាជិក ៦៣០រូប ។ សភាទាំងពីរប្រជុំនៅវិមានសភារបស់ថៃ។

# ផ្នែកទី១០ ប្រទេសវៀតណាម

## ១០.១. ស្ថានភាពទូទៅ

### ១០.១.១. ឈ្មោះជាផ្លូវការ

សាធារណរដ្ឋសង្គមនិយមវៀតណាម

### ១០.១.២. រាជធានី

ហាណូយ(Hanoi)

### ១០.១.៣. ការបែងចែកតំបន់រដ្ឋបាល

ប្រទេសវៀតណាម មានខេត្ត៥៨ និងក្រុងធំ៦៥។

### ១០.១.៤. ផ្ទៃដី

- ផ្ទៃដីសរុប៖ ៣៣១.២១០គម$^{២}$ (ដីគោក៖ ៣១០.០៧០គម$^{២}$ ដីទឹក៖ ២១.១៤០គម$^{២}$)
- អាកាសធាតុ៖ មូសុងត្រូពិច

### ១០.១.៥. ប្រជាពលរដ្ឋ

ក. ចំនួនប្រជាពលរដ្ឋសរុប

៩១.៥១៩.២៨៩នាក់ (ឆ្នាំ២០១២)

ខ. ស្ថានភាពទូទៅរបស់ប្រជាជន

- អត្រាកំណើនប្រចាំឆ្នាំ៖ ១,០៥៤% (ឆ្នាំ២០១២)
- កម្លាំងពលកម្ម៖ ៤៦,៤៨លាននាក់ (ឆ្នាំ២០១១)
- អត្រាអ្នកអត់ការងារធ្វើ៖ ២,៣% (ឆ្នាំ២០១១)
- ប្រជាជនរស់នៅក្រោមបន្ទាត់ក្រីក្រ៖ ១៤,៥% (ឆ្នាំ២០១០)

គ. ក្រុមជនជាតិ

៥៤ក្រុម រួមមាន៖

- ជនជាតិវៀតណាម(Kinh)៖ ៨៥.៧៣%
- Tay៖ (១,៧៩%)
- Thai៖ (១,៧៩%)
- Moung៖ (១,៥២%)
- ខ្មែរ៖ (១,៣៧%)
- ចិន៖ (១,១៣%)
- Nung៖ (១,១៣%) និង
- Hmong៖ (១,១១%)។

ឃ.សាសនា

- ព្រះពុទ្ធ៖ (៥០%)
- កាតូលិក៖ (៨-១០%)
- សាសនាកាវដាយ៖ (១,៥-៣%)
- សាសនាប្រូតេស្តង់៖ (០,៥២%)
- Hoa Hoa៖ (១,៥-៤%)
- ឥស្លាម៖ (០,១%) និងអ្នកជឿលើសត្វ។

ង. ភាសា

វៀតណាម(ភាសាផ្លូវការ) ភាសាអង់គ្លេសរីកចម្រើនជាលំដាប់ ជាភាសាផ្លូវការទី២ បារាំង ចិន និងភាសាជនជាតិភាគតិចផ្សេងៗទៀត។

ច. ការអប់រំ

អក្ខរជន៖ ៩៤% ប្រុស៖ ៩៦,១% ស្ត្រី៖ ៩២% (ឆ្នាំ២០១២)[០៨៦]

ឆ. សុខាភិបាល

- អត្រាកំណើត៖ ១៦,៨១/១០០០នាក់ (ឆ្នាំ២០១២)
- អត្រាមរណៈភាពទារក៖ ២០,២៤នាក់/១០០០ ទារកកើតរស់
- អត្រាមរណៈភាពមាតា៖ ៥៩នាក់/១០០.០០០ ស្ត្រីសម្រាលកូន
- អាយុជាមធ្យម៖ ៧២,៤១ឆ្នាំ ប្រុស៖ ៦៩,៩៥ឆ្នាំ ស្ត្រី៖ ៧៥,១៦ឆ្នាំ (ឆ្នាំ២០១២)
- អត្រាមរណៈភាព៖ ៥,៩៥នាក់/១០០០នាក់ (ឆ្នាំ២០១២)

**១០.១.៦. ការទទួលឯករាជ្យ**

ថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៤៥ ពីប្រទេសបារាំង

**១០.១.៧.ធនធានធម្មជាតិ**

ធ្យូងថ្ម សង្កសី ស្ពាន់ ប្រាក់ មាស ម៉ង់កាណែស ដែក កសិផលព្រៃឈើ នេសាទ ដំឡូងផ្លា កប្បាស។ល។

**១០.១.៨. សេដ្ឋកិច្ច**

- ផលិតផលក្នុងស្រុកសរុប GDP៖ ១២២,៧កោដិដុល្លា (ឆ្នាំ២០១១)
- GDP Per Capita(PPP)៖ ៣៤០០ដុល្លា (ឆ្នាំ២០១១)
- អត្រាកំណើន GDP៖ ៥,៩% (ឆ្នាំ២០១១)
- សមាសភាព GDP តាមវិស័យ៖

[០៨៦] Vietnam-CIA- the world facebook, ១០កញ្ញា ឆ្នាំ២០១២។

- កសិកម្ម៖ ២២% (ឆ្នាំ២០១១)
- ឧស្សាហកម្ម៖ ៤០,៣% (ឆ្នាំ២០១១)
- សេវាកម្ម៖ ៣៧,៧% (ឆ្នាំ២០១១)

- អត្រាអតិផរណា៖ ១៨,៦% (ឆ្នាំ២០១១)
- រូបិយវត្ថុ៖ ដុង
- ទំនិញនាំចេញ៖ ប្រេង ផលិតផលកសិកម្មមិនទាន់កែច្នៃ និងគ្រឿងសមុទ្រ អង្ករ ត្បូងថ្ម សំលៀកបំពាក់ ចាន កែវ ត្បូងថ្ម សូត្រ។ ប្រទេសដៃគូមាន ជប៉ុន អូស្ត្រាលី អាឡឺម៉ង់ ចិន សហរដ្ឋអាមេរិក និងកម្ពុជា។
- ទំនិញនាំចូល៖ ផលិតផលប្រេង ផលិតផលដែកថែប សំភារៈផ្លូវដែក គ្រឿងគីមី ថ្នាំពេទ្យ កប្បាស ជីធុញ្ញជាតិ។ ប្រទេសដៃគូមាន សិង្ហបុរី ជប៉ុន កូរ៉េខាងត្បូង តៃវ៉ាន់ និងចិន។

### ១០.១.៥. ការចូលជាសមាជិកអង្គការផ្សេងៗ

ADB, APEC, ARF, ASEAN, CICA, CP, EAS, FAO, G-77, IAEA, IBRD, ICAO, ICRM, IDA, IFAD, IFC, IFRCS, ILO, IMF, IMO, IMSO, Interpol, IOC, IOM, IPU, ISO, ITSO, ITU, MIGA, NAM, OIF, OPCW, UN, UNCTAD, UNESCO, UNIDO, UNWTO, UPU, WCO, WFTU, WHO, WIPO, WMO, WTO។[១៨៧]

## ១០.២. ប្រព័ន្ធនយោបាយគ្រប់គ្រង

### ១០.២.១. ប្រវត្តិនៃការគ្រប់គ្រងប្រទេស

សាធារណៈរដ្ឋសង្គមនិយមវៀតណាម គឺជារបបផ្តាច់ការដែលមានគណបក្សតែមួយ និងនៅពេលថ្មីៗនេះមានមូលដ្ឋានលើសេរីភាវូនីយកម្មសេដ្ឋកិច្ច។ ដោយផ្តើមចេញពីកំណែទម្រង់ doi Moi នៅឆ្នាំ១៩៨៦។ នៅឆ្នាំ២០០៧ វៀតណាមបានចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក។ ប្រទេសវៀតណាមបច្ចុប្បន្នជាប្រទេសដែលមានកំណើនសេដ្ឋកិច្ចលឿនជាងគេបំផុតនៅអាស៊ីអាគ្នេយ៍ ដែលចេញជាដំបូងពីវិស័យទេសចរណ៍ និងនាំចេញ។ រដ្ឋាភិបាលបានធ្វើសេរីភាវូនីយកម្មបន្តិចម្តងៗ លើវិស័យសេដ្ឋកិច្ចសំខាន់ៗ រួមបញ្ចូលស្ថាប័នហិរញ្ញវត្ថុ ប៉ុន្តែមានការរឹតត្បិតខាងនយោបាយ និងការគោរពសិទ្ធិមនុស្សនៅមានកម្រិតនៅឡើយ។

### ១០.២.២. ការគ្រប់គ្រងប្រទេស

ក. របបនយោបាយ

- ទម្រង់រដ្ឋាភិបាល៖ សាធារណរដ្ឋអាស្រ័យរដ្ឋធម្មនុញ្ញ មានគណបក្សតែមួយ (គណបក្សកុម្មុយនីស្ត)
- ប្រមុខរដ្ឋ៖ ប្រធានាធិបតី (TRUONG TAN SANG)

---

[១៨៧] Vietnam-CIA- the world facebook, ១០កញ្ញា ឆ្នាំ២០១២។

# ឧបសម្ព័ន្ធ២

## ៣.១ អនុវិស័យ ការអប់រំកុមារតូច

### ៣.១.១ សាវតារ

ក្នុងឆ្នាំសិក្សា២០១២-២០១៣ កុមារអាយុ៥ឆ្នាំ ៥៦,៤៩ ភាគរយ បានចូលរៀនក្នុងកម្មវិធីអប់រំកុមារតូច ធៀបនឹងឆ្នាំសិក្សា ២០០៨-២០០៩ មានត្រឹមតែ ៣៥ ភាគរយ ។ កុមារអាយុ ៣-៥ ឆ្នាំបានចូលរៀន ២១,២៣ ភាគរយ ។ ប៉ុន្តែការទទួលបានសេវាអប់រំកុមារតូចអាយុ ០ ទៅក្រោម ៣ ឆ្នាំ សម្រេចបានតែ ៣,១៩ ភាគរយប៉ុណ្ណោះ។

វឌ្ឍនភាពដែលទទួលបានទាំងនេះ ដោយសារមានការពង្រីកចំនួនសាលាមត្តេយ្យសិក្សាសហគមន៍ ថ្នាក់មត្តេយ្យសិក្សាក្នុងសាលាបឋមសិក្សា សាលាមត្តេយ្យសិក្សាឯកជន និងកម្មវិធីអប់រំកុមារតូចតាមផ្ទះ ខ្នងផ្ទះ។ ទោះជាយ៉ាងណា វិសាលភាពនៃការពង្រីកនេះនៅមានកម្រិតនៅឡើយ ដោយសារកង្វះធនធានរូបវន្តនិងហិរញ្ញវត្ថុ ព្រមទាំងសមត្ថភាព។ តម្រូវការនិងគុណភាពនៃសេវាអប់រំនៅកម្រិតនេះនៅមានកម្រិត និងមានគម្លាតរវាងទីតាំងភូមិសាស្ត្រមួយទៅភូមិសាស្ត្រមួយទៀត ជាពិសេសនៅតំបន់ដែលមានការចូលរៀននៅបឋមសិក្សាមានកម្រិតទាប និងបោះបង់ការសិក្សាខ្ពស់។ អនុវិស័យនេះបានផ្តោតការយកចិត្តទុកដាក់តិចតួចលើបញ្ហាអាហារូបត្ថម្ភ ការគាំពារ និងសុខភាពរបស់កុមារតូច។

ក្នុងពេលបច្ចុប្បន្ន ក្របខណ្ឌធានាគុណភាពមិនទាន់បានរៀបចំ និងមានតែគ្រូមត្តេយ្យសិក្សានៅសាលាសាធារណៈប៉ុណ្ណោះ ដែលបានទទួលវិក្រឹតការស្តីពីបច្ចុប្បន្នភាពកម្មវិធីសិក្សា។ គ្រូមត្តេយ្យសិក្សាសហគមន៍និងក្រុមម្តាយបង្គោលនៃកម្មវិធីអប់រំកុមារតូចតាមផ្ទះនិងខ្នងផ្ទះ បានទទួលការបំប៉នតិចតួច ការផ្តល់សម្ភារៈរៀននិងបង្រៀននៅមានកម្រិត និងការអភិវឌ្ឍសម្ភារូបវន្តមត្តេយ្យសិក្សាសហគមន៍មិនទាន់ជាចំណុចអាទិភាពនៅឡើយ។

អន្តរាគមន៍គោលនយោបាយក្នុងអំឡុង ២០០៩-២០១៣ បានផ្តល់ជាមូលដ្ឋានគ្រឹះសម្រាប់ការឈានទៅបង្កើនគុណភាពនៃសេវាអប់រំកុមារតូចនៅឆ្នាំ២០១៤។ មូលដ្ឋានគ្រឹះទាំងនោះមានដូចជាការរៀបចំគោលនយោបាយជាតិនិងផែនការសកម្មភាពជាតិស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូច ការបង្កើតគណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍន៍កុមារតូច ប្រកាសស្តីពីការគ្រប់គ្រងសាលាមត្តេយ្យសិក្សាឯកជន និងប្រកាសស្តីពីការទទួលស្គាល់គ្រូបង្គោលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។ គោលការណ៍ប្រតិបត្តិសម្រាប់មត្តេយ្យសិក្សាសហគមន៍ កម្មវិធីអប់រំមាតាបិតារួមបញ្ចូលទាំងស្ត្រីមានផ្ទៃពោះនិងមាតាបិតាដែលមានកូនអាយុក្រោម ២ ឆ្នាំ និងគោលការណ៍ប្រតិបត្តិសម្រាប់សាលាមត្តេយ្យសិក្សាធនធាន។

### ៣.១.២ វត្ថុបំណងគោលនយោបាយ

- បង្កើនការចូលរៀននិងការគាំពារដល់កុមារអាយុ ០ ដល់ក្រោម ៦ ឆ្នាំ ជាពិសេស កុមារមកពីគ្រួសារក្រីក្រ ជនជាតិដើមភាគតិច និងកុមារមានពិការភាព ព្រមទាំងផ្តល់អាទិភាពដល់សាលាមត្តេយ្យសិក្សាសហគមន៍ និងអប់រំកុមារតូចតាមផ្ទះនិងខ្នងផ្ទះ

## ៣.២ អនុវិស័យ ការអប់រំបឋមសិក្សា

### ៣.២.១ សាវតារ

កុមារបានចូលរៀននៅបឋមសិក្សាកាន់តែច្រើន ជាក់ស្តែងអត្រាពិតនៃការសិក្សាបានកើនពី ៩៤.៨ ភាគរយ ឆ្នាំសិក្សា២០០៨-២០០៩ ដល់ ៩៧ ភាគរយ ឆ្នាំសិក្សា២០១២-២០១៣ និងគ្មានគម្លាតយេនឌ័រ។ អត្រាត្រួតថ្នាក់និងសិស្សបោះបង់ការសិក្សាបានថយចុះ។ សាលាបឋមសិក្សាមិនគ្រប់កម្រិតត្រូវបានបន្ថែមបន្ទប់រៀន ដើម្បីក្លាយជាសាលាគ្រប់កម្រិត។ ការសិក្សាអំពីកុមារពិការនិងកុមារក្រៅសាលាត្រូវបានធ្វើឡើងនៅតាមសាលារៀនមួយចំនួន។ សាលារៀនជាច្រើនក្នុងរាជធានី ខេត្ត ១២ បានអនុវត្តកម្មវិធីផ្តល់អាហារពេលព្រឹក។ សាលាបឋមសិក្សា ៥០ ភាគរយមានកន្លែងលាងសម្អាតដៃ ៨០.២ ភាគរយមានបង្គន់អនាម័យ ៥៨.៥ ភាគរយមានទឹកស្អាតប្រើប្រាស់។ ជាមួយគ្នានេះ សម្ភារបន្ថែមមួយចំនួនដូចជា ប្រអប់សង្គ្រោះបឋម ធុងចម្រោះទឹកស្អាត ធុងសំរាមត្រូវបានផ្តល់ជាបណ្តើរៗដល់សាលាបឋមសិក្សាមួយចំនួន។

សាលាបឋមសិក្សាភាគច្រើនបានអនុវត្តតាមគោលនយោបាយសាលាកុមារមេត្រី។ ឧបករណ៍សម្រាប់វាយតម្លៃការសិក្សារបស់សិស្សត្រូវបានរៀបចំ និងបានបង្ហាញថាការសិក្សារបស់សិស្សបានល្អប្រសើរ ជាពិសេសមុខវិជ្ជាភាសាខ្មែរនៅកម្រិតថ្នាក់ដំបូង។ ការអប់រំពីរភាសាកំពុងត្រូវបានពង្រីក ក៏ដូចគ្នានឹងថ្នាក់ពន្លឿនការអប់រំ និងថ្នាក់គួបផងដែរ។ អាហារូបករណ៍ប្រមាណ ១៥ ០០០ បានផ្តល់ដល់សិស្សក្រីក្រនៅបឋមសិក្សា។ ថវិកាកែលម្អសាលារៀនត្រូវបានផ្តល់ជូនសាលារៀនប្រមាណ ៦០០ សាលា ដែលនឹងពង្រីកទូទាំងប្រទេសក្នុងឆ្នាំសិក្សា ២០១៣-២០១៤។ គ្រូបង្រៀនជាច្រើននាក់ត្រូវបានបំប៉នអំពីប្រសិទ្ធភាពនៃការរៀននិងបង្រៀន។

តួនាទីរបស់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ មានសារៈសំខាន់ណាស់ក្នុងការគាំទ្រដល់ប្រសិទ្ធភាពនៃការផ្តល់សេវាអប់រំ។ ក្រុមបំប៉ននិងពិនិត្យតាមដានថ្នាក់ក្រុង ស្រុក ខណ្ឌត្រូវបានបង្កើតឡើង ដើម្បីផ្តល់ការគាំទ្រទាន់ពេលវេលាដល់សាលារៀន។ ក្រុមគ្រូឧទ្ទេសបង្គោលថ្នាក់ជាតិត្រូវបានបង្កើតឡើង ដើម្បីជួយដល់ក្រុមបំប៉ននិងពិនិត្យតាមដានថ្នាក់ក្រុង ស្រុក ខណ្ឌនិងសាលារៀន។

ទោះយ៉ាងណា គម្លាតភូមិសាស្ត្រនិងសាលាបឋមសិក្សាមិនគ្រប់កម្រិតនៅតែជាឧបសគ្គសម្រាប់ការចូលរៀនរបស់កុមារ ជាពិសេសការចូលរៀនត្រឹមត្រូវតាមអាយុកំណត់។ លទ្ធផលសិក្សារបស់សិស្សលើសអាយុទាបជាងសិស្សរៀនត្រឹមត្រូវតាមអាយុ។

កិច្ចការបន្ទាប់គឺត្រូវបង្កើនសមត្ថភាពរបស់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ និងក្រុមបំប៉ននិងពិនិត្យតាមដានថ្នាក់ក្រុង ស្រុក ខណ្ឌ។ សាលារៀនត្រូវការធាតុចូលដែលមានគុណភាព ជាពិសេសសាលារៀននៅតំបន់ជនបទ។ តួនាទីរបស់មាតាបិតានិងសហគមន៍ក្នុងការគ្រប់គ្រងសាលារៀនត្រូវតែពង្រឹង ដើម្បីដោះស្រាយបញ្ហាខ្វះខាតផ្នែក និងបញ្ហាសង្គមសេដ្ឋកិច្ចនៅកម្រិតសហគមន៍ និងគ្រួសារ។ ការបំពេញការងាររបស់គ្រូបង្រៀនត្រូវធ្វើការពិនិត្យតាមដាននិងវាយតម្លៃជាទៀងទាត់។ នៅ

តំបន់ជនបទនៅខ្វះគ្រូបង្រៀនដែលមានបទពិសោធ។ នាយកសាលារៀនត្រូវការបំប៉នបន្ថែមអំពីជំនាញគ្រប់គ្រងនិងដឹកនាំ។ សុក្រឹតភាពរបស់ទិន្នន័យទាមទារឱ្យមានការខិតខំបន្ថែមទៀត និងសុខដុមនីយកម្មរវាងប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំជាមួយនឹងប្រព័ន្ធធានាគុណភាពអប់រំ។

ការអប់រំបឋមសិក្សាត្រូវបានចាត់ទុកជាអាទិភាពមួយ និងទទួលបាននូវចំណែកថវិកាច្រើនជាងគេក្នុងថវិកាសរុបរបស់ក្រសួងអប់រំ យុវជន និងកីឡា។ ការផ្តល់ហិរញ្ញប្បទានសម្រាប់បឋមសិក្សាគួរត្រូវបន្តជាអាទិភាពតទៅទៀត និងត្រូវបង្ហាញច្បាស់អំពីទំនាក់ទំនងរវាងធនធាននិងលទ្ធផល។

ដៃគូអភិវឌ្ឍជាច្រើនបានបន្តផ្តល់ការគាំទ្រជាហិរញ្ញវត្ថុ និងបច្ចេកទេសសម្រាប់អនុវិស័យនេះ ដូចជា មូលនិធិភាពជាដៃគូសកលសម្រាប់ការអប់រំ ការគាំទ្ររបស់ប្រទេសស៊ុយអែតក្នុងការផ្តល់ថវិកាកែលម្អសាលារៀន និងសហភាពអឺរ៉ុបផ្តល់ជាថវិកាគាំទ្រដែលមានលទ្ធភាពក្នុងការបង្កើនថវិកាដំណើរការសាលារៀនតាមរយៈថវិកាកម្មវិធី។ ថវិកាភាពជាដៃគូសម្រាប់ការអភិវឌ្ឍសមត្ថភាពបានផ្តល់លទ្ធភាពក្នុងការអភិវឌ្ឍសមត្ថភាពនៅគ្រប់កម្រិត។ កម្មវិធីស្បៀងអាហារពិភពលោកនឹងបន្តផ្តល់អាហារតាមសាលារៀន។ ដៃគូអភិវឌ្ឍនិងអង្គការមិនមែនរដ្ឋាភិបាលបានអនុវត្តនូវកម្មវិធីផ្តួចផ្តើមមួយចំនួនដែលនឹងផ្តល់ជាធាតុចូលសម្រាប់ការពិភាក្សាកម្រិតគោលនយោបាយ និងការពង្រីកវិសាលភាពផងដែរ។

### ៣.២.២ វត្ថុបំណងគោលនយោបាយ

- ធានាប្រមូលកុមារដល់វ័យនិងក្នុងវ័យសិក្សាឱ្យចូលរៀននិងរៀនបានចប់ឆ្នាំសិក្សានិងភូមិសិក្សា
- ធានាកុមារទាំងអស់ទទួលបានចំណេះដឹង បំណិន សុខភាពពេញលេញ និងសីលធម៌ស្របតាមស្តង់ដារដែលបានកំណត់
- ធានាដំណើរការពេញលេញនូវប្រព័ន្ធគ្រប់គ្រងផ្អែកលើលទ្ធផល។

### ៣.២.៣ សកម្មភាពគោលនយោបាយ

- ធ្វើវិសោធនកម្មអនុក្រឹត្យ ស្តីពីការផ្តល់អាហារូបករណ៍សម្រាប់បឋមសិក្សា នៅឆ្នាំ ២០១៤
- កែសម្រួលលិខិតបទដ្ឋានគតិយុត្តិ ស្តីពីការប្រើប្រាស់ថវិកាដំណើរការសាលារៀន នៅឆ្នាំ ២០១៤
- រៀបចំលក្ខន្តិកៈ ស្តីពីការបង្កើតគ្រឹះស្ថានបឋមសិក្សាសាធារណៈនិងឯកជន នៅឆ្នាំ ២០១៥
- កែលម្អលិខិតបទដ្ឋានគតិយុត្តិ ស្តីពីការសាងសង់និងការបំពាក់សម្ភារបរិក្ខារគ្រឹះស្ថានសិក្សាឱ្យស្របតាមស្តង់ដារគុណភាពសាលាបឋមសិក្សា នៅឆ្នាំ ២០១៥
- រៀបចំលិខិតបទដ្ឋានណែនាំអនុវត្តកម្មវិធីអាហារូបត្ថម្ភនៅតាមសាលាបឋមសិក្សា នៅឆ្នាំ២០១៤
- កែសម្រួលផែនការគោលក្នុងការជួយកុមារពិការ ចាប់ពីឆ្នាំ ២០១៤
- កែលម្អកម្មវិធីសិក្សានៅបឋមសិក្សានៅឆ្នាំ ២០១៥

- អត្រាបោះបង់ការសិក្សាថយចុះពី ៣,៧ ភាគរយនៅឆ្នាំសិក្សា២០១១-២០១២ មកត្រឹម ១ ភាគរយ នៅឆ្នាំសិក្សា ២០១៦-២០១៧
- អត្រាត្រួតថ្នាក់ថយចុះពី ៥,៣ ភាគរយនៅឆ្នាំសិក្សា ២០១១-២០១២ មកត្រឹម ២ ភាគរយ នៅឆ្នាំសិក្សា ២០១៦-២០១៧
- អត្រាបញ្ចប់ការសិក្សាកើនពី ៨៧,៤ ភាគរយនៅឆ្នាំសិក្សា ២០១២-២០១៣ ដល់ ១០០ ភាគរយ នៅឆ្នាំសិក្សា ២០១៧-២០១៨
- ភាគរយកុមារចូលរៀនថ្នាក់ទី១ថ្មី បានឆ្លងកាត់មត្តេយ្យសិក្សាកើនពី ៨០ ភាគរយនៅឆ្នាំសិក្សា ២០១១-២០១២ ដល់ ១០០ ភាគរយ នៅឆ្នាំសិក្សា ២០១៧-២០១៨
- អត្រាឆ្លងភូមិសិក្សាទៅមធ្យមសិក្សាបឋមភូមិកើនពី ៧៨,៩ ភាគរយនៅឆ្នាំសិក្សា ២០១១-២០១២ ដល់ ១០០ ភាគរយ នៅឆ្នាំសិក្សា ២០១៧-២០១៨
- ភាគរយសាលាបឋមសិក្សាមានបង្គន់អនាម័យនិងទឹកស្អាត (៨៧ ភាគរយ) កន្លែងលាងសម្អាតដៃ (៦០ ភាគរយ) និងប្រអប់សង្គ្រោះបឋម (៧០ ភាគរយ) នៅឆ្នាំ ២០១៨។

### ៣.២.៦ កម្មវិធីនិងសកម្មភាព

- *ការប្រមូលកុមារចូលរៀន* ៖ តាមរយៈ ការផ្តល់ថវិកាដំណើរការសាលារៀន ការអនុវត្តផែនការកែលម្អសាលារៀន និងការផ្តល់អាហារូបករណ៍សម្រាប់កុមារក្រីក្រនិងអាហារពេលព្រឹក
    - **ផ្តល់ថវិកាដំណើរការសាលារៀន** ៖ ថវិកាដំណើរការសាលាបឋមសិក្សា គណៈកម្មការកម្រង សាលាប្រជុំកសាងផែនការ ការបំប៉នគ្រូនិងអ្នកពាក់ព័ន្ធពីបច្ចេកទេសរៀននិងបង្រៀន ការពិនិត្យតាមដាននិងការប្រឡងប្រណាំងគ្រូល្អ សាលារៀនល្អ។
    - **ផែនការកែលម្អសាលារៀន** ៖ កែលម្អប្រព័ន្ធព័ត៌មានគ្រប់គ្រងសាលារៀន។ កែលម្អផែនការសាលារៀនដើម្បីឆ្លើយតបតាមស្តង់ដារគុណភាព។
    - **អាហារូបករណ៍សម្រាប់កុមារក្រីក្រ និងអាហារពេលព្រឹក** ៖ ផ្តល់អាហារូបករណ៍ជាថវិកានិងស្បៀងអាហារដល់កុមារក្រីក្រពីថ្នាក់ទី ៤ ដល់ទី ៦ និងផ្តល់អាហារពេលព្រឹកសម្រាប់សាលាបឋមសិក្សា។
- *កម្មវិធីអភិវឌ្ឍសម្ភារៈបង្រៀននិងរៀន* ៖ តាមរយៈ ការអភិវឌ្ឍកម្មវិធីសិក្សា ការផ្តល់សម្ភារៈបង្រៀននិងរៀន
    - *ការអភិវឌ្ឍកម្មវិធីសិក្សា* ៖ ធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សា ស្តង់ដារកម្មវិធីសិក្សាតាមមុខវិជ្ជា។ កសាងឯកសារ ផ្សព្វផ្សាយ ណែនាំការអនុវត្តកម្មវិធីសិក្សា និងពិនិត្យតាមដាន

## ៣.៣ អនុវិស័យ ការអប់រំមធ្យមសិក្សានិងអប់រំបច្ចេកទេស

### ៣.៣.១ សាវតារ

អំឡុងឆ្នាំ ២០០៩-២០១៣ សកម្មភាពគោលនយោបាយមួយចំនួនត្រូវបានរៀបចំដូចជា ផែនការគោលស្តីពីការអភិវឌ្ឍមធ្យមសិក្សា និងសៀវភៅប្រតិបត្តិសម្រាប់សាលាមធ្យមសិក្សាធនធាន គោលនយោបាយស្តីពីសាលាកុមារមេត្រីនៅមធ្យមសិក្សា និងការកែលម្អកម្មវិធីសិក្សា។ ប្រព័ន្ធវិក្រឹតការគ្រូបង្រៀនលើមុខវិជ្ជាគណិតវិទ្យានិងវិទ្យាសាស្ត្រត្រូវបានរៀបចំ។ កម្មវិធីបំណិនជីវិត បច្ចេកវិទ្យា ព័ត៌មាន និងទេសចរណ៍ត្រូវបានអនុម័ត និងស្តង់ដារបណ្ណាល័យនៅមធ្យមសិក្សាកំពុងរៀបចំជាសេចក្តីព្រាង។

ការចូលរៀននិងគុណភាពនៅកម្រិតនេះមានការប្រែប្រួលតិចតួច។ អត្រាត្រួតថ្នាក់បានថយចុះតិចតួច ប៉ុន្តែអត្រាបោះបង់ការសិក្សាមិនមានប្រែប្រួលទេ។ សិស្សភាគច្រើនបានជ្រើសរើសយកបណ្តុំមុខវិជ្ជាវិទ្យាសាស្ត្រនៅថ្នាក់ទី ១១ និងថ្នាក់ទី ១២។ ទោះយ៉ាងណាក៏ដោយ គុណភាពនៅកម្រិតនេះមិនទាន់អាចវាស់វែងបាននៅឡើយ ដោយសារពុំទាន់បានធ្វើតេស្តវាយតម្លៃថ្នាក់ជាតិនៅថ្នាក់ទី ១២ ។ អាហារូបករណ៍បានផ្តល់ជារៀងរាល់ឆ្នាំ។ សិស្សបានទទួលមេដាយលើមុខវិជ្ជាគណិតវិទ្យានិងវិទ្យាសាស្ត្រពីកម្មវិធីប្រកួតស៊ីមេអូឡាំពិក និងកម្មវិធីប្រកួតអន្តរជាតិផ្សេងៗទៀត។

ប្រព័ន្ធវាយតម្លៃថ្នាក់ជាតិត្រូវបានដាក់ឱ្យអនុវត្តនិងមានឱកាសសម្រាប់ដំណើរការ។ ការប្រឡងថ្នាក់ជាតិនៅថ្នាក់ទី ៩ និងទី ១២ ត្រូវបានអនុវត្តជាទៀងទាត់។

ចំនួនអនុវិទ្យាល័យ និងវិទ្យាល័យបានកើនឡើង។ សាលាមធ្យមសិក្សាបឋមភូមិ ៥០ ភាគរយបានអភិវឌ្ឍទៅជាសាលាមធ្យមសិក្សាទុតិយភូមិ។ អគារធនធាននៅមធ្យមសិក្សាត្រូវបានកសាងនៅគ្រប់រាជធានី ខេត្ត។ សាលាមធ្យមសិក្សាបឋមភូមិចំនួន ១៩១ ក្នុងខេត្ត ៨ មានបន្ទប់កុំព្យូទ័រ។ ប្រព័ន្ធនៃការបណ្តុះបណ្តាលនិងវិក្រឹតការគ្រូបង្រៀន ជាពិសេសគ្រូបង្រៀនកម្រិតអប់រំមូលដ្ឋាននៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងវិទ្យាស្ថានជាតិអប់រំកំពុងត្រូវបានពង្រីក។ ការជាវិក្រឹតការលើមុខវិជ្ជាគណិតវិទ្យានិងវិទ្យាសាស្ត្រ ក៏កំពុងពង្រីកផងដែរ។ នាយកសាលាមធ្យមសិក្សាទុតិយភូមិទាំងអស់ និងនាយកសាលាមធ្យមសិក្សាបឋមភូមិមួយចំនួនបានទទួលការបំប៉នស្តីពីការគ្រប់គ្រងនិងដឹកនាំ។ ប្រធានក្រុមបច្ចេកទេសនៃសាលាមធ្យមសិក្សាធនធាន និងបណ្ណារក្សទាំងអស់បានទទួលការបំប៉ន ស្តីពីស្តង់ដារកម្មវិធីសិក្សា។ គោលនយោបាយសាលាកុមារមេត្រីត្រូវបានអនុវត្តនៅសាលាចំនួន ៨២៣ (៥០,៧ ភាគរយនៃសាលាមធ្យមសិក្សាបឋមភូមិ)។ សាលាមធ្យមសិក្សាបឋមភូមិ ៨៤,៨ ភាគរយមានបង្គន់អនាម័យ ៥២,៩ ភាគរយមានទឹកស្អាតប្រើប្រាស់ និងសាលាមធ្យមសិក្សាទុតិយភូមិ ៩៧,៧ ភាគរយ មានបង្គន់អនាម័យ ៦៨,៨ ភាគរយមានទឹកស្អាតប្រើប្រាស់។

បញ្ហាប្រឈមសម្រាប់ផែនការយុទ្ធសាស្ត្រវិស័យអប់រំ នៅពេលបន្ទាប់គឺ ការបង្កើនសមធម៌ក្នុងការចូលរៀននៅមធ្យមសិក្សា តាមរយៈបង្កើនចំនួនសាលាមធ្យមសិក្សាបឋមភូមិឱ្យបានគ្រប់ឃុំ សង្កាត់ និងវិទ្យាល័យនៅគ្រប់ស្រុក ខណ្ឌ។ គុណភាពរបស់សិស្សបញ្ចប់ថ្នាក់ទី ១២ ត្រូវលើកកម្ពស់ និងផ្តល់នូវ

ចំណេះដឹងពាក់ព័ន្ធដទៃទៀត សម្រាប់ការអប់រំបច្ចេកទេសវិជ្ជាជីវៈ និងឧត្តមសិក្សា។ សាលាមធ្យមសិក្សាភាគច្រើន ជាពិសេសនៅតំបន់ជនបទខ្វះខាតធាតុចូលដែលមានគុណភាពដូចជា គ្រូបង្រៀនតាមមុខវិជ្ជា សម្ភារៈបង្រៀននិងគ្រឿងបរិក្ខារ សៀវភៅសិក្សាគោល បន្ទប់ពិសោធវិទ្យាសាស្ត្រ បន្ទប់កុំព្យូទ័រ និងភាសា និងបរិក្ខារបណ្ណាល័យ។ វិធីសាស្ត្រក្នុងការបង្រៀនក្នុងពេលបច្ចុប្បន្នអនុវត្តតាមរបៀបជាមេរៀន ចម្លងតាមដកស្រង់ និងការចងចាំ។ វិធីសាស្ត្រទាំងនេះគួរត្រូវបញ្ចូលនូវការគិត និងជំនាញវិភាគ។ ស្តង់ដារគ្រូបង្រៀនគួរត្រូវពិនិត្យតាមដាន វាយតម្លៃ និងអភិវឌ្ឍជាប្រចាំ។

ការអប់រំបច្ចេកទេសជាមុខងារថ្មីមួយក្នុងក្រសួង និងទើបតែបានអនុម័តគោលនយោបាយស្តីពីការអប់រំបច្ចេកទេស។ ក្នុងគោលនយោបាយនេះបានលើកឡើងពី ការបង្កើតវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសនៅគ្រប់រាជធានី ខេត្ត។ នាពេលបច្ចុប្បន្ន សាលាមធ្យមសិក្សាចំណេះទូទៅនិងបច្ចេកទេសចំនួន ៣ កំពុងដំណើរការ និងផ្តល់នូវមុខវិជ្ជាសំខាន់បួន។ សិស្សដែលបញ្ចប់ការសិក្សានៅសាលាទាំងនេះ អាចរកការងារបាន។

កម្មវិធីអប់រំបច្ចេកទេស ដែលកំពុងអនុវត្តនាពេលបច្ចុប្បន្ន មានកង្វះខាតទាំងក្របខណ្ឌគុណភាពដ៏រឹងមាំ និងធាតុចូលដែលមានគុណភាព។ ប្រព័ន្ធទទួលស្គាល់និងប្រព័ន្ធធានាគុណភាពសាលារៀនមិនទាន់បានបង្កើត ព្រមទាំងទំនាក់ទំនងរវាងប្រព័ន្ធអប់រំ និងទីផ្សារការងារនៅមានកម្រិត។ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនិងហិរញ្ញវត្ថុសាលារៀនមិនទាន់បង្កើត។ ការងារអប់រំបច្ចេកទេសត្រូវដកបទពិសោធពីប្រទេសដទៃ។ ដៃគូអភិវឌ្ឍជាច្រើនបានចាប់អារម្មណ៍គាំទ្រដល់កម្មវិធីនេះ។

### ៣.៣.២ វត្ថុបំណងគោលនយោបាយ

- ធានាសមធម៌ និងពង្រីកការចូលរៀននៅសាលាមធ្យមសិក្សាចំណេះទូទៅ ស្របតាមស្តង់ដារគុណភាព ព្រមទាំងនៅនៅវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស និងបំផុសសកម្មភាពអប់រំកាយ និងកីឡា រួមទាំងការលើកកម្ពស់សុខភាពសិក្សា
- ធានាសិស្សបញ្ចប់ការសិក្សានៅមធ្យមសិក្សាចំណេះទូទៅ និងវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសទទួលបានជំនាញត្រឹមត្រូវ និងអាចចូលបម្រើការងារ ឬបន្តការសិក្សានៅផ្នែកអប់រំបច្ចេកទេស និងវិជ្ជាជីវៈ និងឧត្តមសិក្សា
- ធានាប្រព័ន្ធគ្រប់គ្រងផ្អែកលើលទ្ធផលនៅមធ្យមសិក្សាចំណេះទូទៅ និងមធ្យមសិក្សាបច្ចេកទេសបានដំណើរការពេញលេញ។

### ៣.៣.៣ សកម្មភាពគោលនយោបាយ

- កសាងគោលនយោបាយជាតិស្តីពី អាហារូបករណ៍ ឧបត្ថម្ភធន និងឥណទានអ្នកសិក្សា នៅឆ្នាំ ២០១៩

### ៣.៣.៥ សូចនាករផលសម្រេច (សាធារណៈ និងឯកជន)

- អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ ថយចុះពី ២០ ភាគរយនៅឆ្នាំសិក្សា ២០១១-២០១២ ដល់ ៣ ភាគរយនៅឆ្នាំសិក្សា ២០១៦- ២០១៧
- អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ កើនឡើងពី ៥៣,៦ ភាគរយនៅឆ្នាំសិក្សា ២០១២-២០១៣ ដល់ ៨៧,០ ភាគរយនៅឆ្នាំសិក្សា ២០១៧- ២០១៨
- អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិកើនឡើងពី ២៧,៤ ភាគរយនៅឆ្នាំសិក្សា ២០១២-២០១៣ ដល់ ៤៥,០ ភាគរយនៅឆ្នាំសិក្សា ២០១៧- ២០១៨
- អត្រាឆ្លងភូមិសិក្សាពីមធ្យមសិក្សាបឋមភូមិទៅមធ្យមសិក្សាទុតិយភូមិកើនឡើងពី ៧៤,០ ភាគរយនៅឆ្នាំសិក្សា ២០១២-២០១៣ ដល់ ៨៣,០ ភាគរយនៅឆ្នាំសិក្សា ២០១៧-២០១៨
- អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិកើនឡើងពី ៤០,៦ ភាគរយនៅឆ្នាំសិក្សា ២០១២ -២០១៣ ដល់ ៧៦,៤ ភាគរយនៅឆ្នាំសិក្សា ២០១៧- ២០១៨
- ភាគរយសិស្សមធ្យមសិក្សាបឋមភូមិយ៉ាងតិច ៥ ភាគរយទទួលអាហារូបករណ៍ជារៀងរាល់ឆ្នាំ
- ចំនួនគ្រឹះស្ថានមធ្យមសិក្សាអនុវត្តកម្មវិធីសាលាកុមារមេត្រីកើនឡើងពី ៥០,៧ ភាគរយនៅឆ្នាំសិក្សា ២០១២-២០១៣ ដល់ ៧៥ ភាគរយនៅឆ្នាំសិក្សា ២០១៧-២០១៨
- សាលាមធ្យមសិក្សាបឋមភូមិ ៩០ ភាគរយ និង សាលាមធ្យមសិក្សាទុតិយភូមិ ១០០ ភាគរយ មានបង្គន់អនាម័យនិងមានទឹកស្អាត នៅឆ្នាំ ២០១៨
- ចំនួនវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសមាន ៧ នៅឆ្នាំ ២០១៨
- ចំនួនសិស្សចូលរៀនក្នុងការអប់រំបច្ចេកទេសកើនឡើងពី ៦១០ នាក់នៅឆ្នាំសិក្សា២០១២-២០១៣ ដល់ ២០០០ នាក់ នៅឆ្នាំសិក្សា ២០១៧-២០១៨
- សាលាមធ្យមសិក្សា ៣០ ភាគរយបានអនុវត្តកម្មវិធីអប់រំបំណិនជីវិតតាមគោលការណ៍ណែនាំនៅឆ្នាំ២០១៨។

### ៣.៣.៦ កម្មវិធីនិងសកម្មភាព

កម្មវិធីនិងសកម្មភាពសំខាន់ៗ ដើម្បីបង្កើនការចូលរៀនប្រកបដោយសមធម៌នៅសាលាមធ្យមសិក្សាបឋមភូមិនិងទុតិយភូមិ ៖

- *ការបង្កើនសិស្សចូលរៀននៅមធ្យមសិក្សា* ៖ តាមរយៈ ការផ្តល់ថវិកាដំណើរការសាលារៀន ការបង្កើតសាលារៀន និងការផ្តល់អាហារូបករណ៍
  - *ការបង្កើតសាលារៀននិងអភិវឌ្ឍកម្មវិធី* ៖ សាងសង់ និងផ្តល់គ្រូបង្រៀនដល់សាលារៀន

## ៣.៤ អនុវិស័យ ការអប់រំឧត្តមសិក្សា

### ៣.៤.១ សាវតារ

ក្នុងអំឡុងឆ្នាំ២០០៨-២០១៣ ឧត្តមសិក្សាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ជាមួយនឹងកំណើននិស្សិត ៥៧ ភាគរយ ពី ១៣៧២៥៣ នាក់ដល់ ២១៦០៥៣ នាក់។ ចំនួននិស្សិតទទួលអាហារូបករណ៍រដ្ឋនៅតាមគ្រឹះស្ថានឧត្តមសិក្សាមានការកើនឡើងទ្វេដងពី ៩០៩៧ នាក់ ដល់ ១៨៩០៦ នាក់។ ក៏ប៉ុន្តែចំនួននិស្សិតអាហារូបករណ៍នៅតាមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈមានប្រមាណ ១៦,៥ ភាគរយនៅឆ្នាំ ២០០៨ និង ១៨,៧ ភាគរយនៅឆ្នាំ ២០១៣ (កើន ២,៣ ភាគរយ)។ អគ្គនាយកដ្ឋានឧត្តមសិក្សានិងគ្រឹះស្ថានឧត្តមសិក្សាបានអភិវឌ្ឍសមត្ថភាពរបស់ខ្លួន ក្នុងការកសាងផែនការនិងការពិនិត្យតាមដានការគ្រប់គ្រងមូលនិធិស្រាវជ្រាវ មូលនិធិអាហារូបករណ៍ និងមានលទ្ធភាពទាញយកមូលនិធិឱ្យកាន់តែច្រើន ដើម្បីពង្រីកកម្មវិធី។ វប្បធម៌នៃការស្រាវជ្រាវបានចាប់ផ្ដើមផុសឡើង តាមរយៈការអនុវត្តកម្មវិធីផ្ដល់មូលនិធិស្រាវជ្រាវ និងមានកិច្ចសហប្រតិបត្តិការក្នុងតំបន់រឹងមាំ កិច្ចសហការ និងសកម្មភាពបានអនុវត្តរួមគ្នា។ សកម្មភាពគោលនយោបាយសំខាន់ៗមួយចំនួនដែលត្រូវបានអនុវត្ត ដូចជាការអនុម័តផែនការគោល ស្ដីពីការស្រាវជ្រាវ ព្រះរាជក្រឹត្យស្ដីពីចំណាត់ថ្នាក់សាស្ត្រាចារ្យ និងការរៀបចំចក្ខុវិស័យឧត្តមសិក្សាឆ្នាំ ២០៣០។ ការបង្កើតក្រុមការងារបច្ចេកទេសឧត្តមសិក្សាជាជំណាក់កាលសំខាន់មួយ ក្នុងការបង្កើតវេទិកាមួយសម្រាប់ការជជែកនិងពិភាក្សា អំពីបញ្ហានៅឧត្តមសិក្សា។

បញ្ហាប្រឈមចម្បងសម្រាប់ឆ្នាំខាងមុខនេះគឺ ការដោះស្រាយអំពីភាពខុសគ្នារវាងតម្រូវការទីផ្សារការងារ ជាពិសេស ជំនាញសមត្ថភាពក្នុងការគិតពិចារណានិងចំណេះដឹង ជាមួយនឹងជំនាញរបស់បរិញ្ញាបត្របញ្ចប់ការសិក្សានាពេលបច្ចុប្បន្ន។ កត្តានេះទាមទារឱ្យមានការយល់ដឹងកាន់តែប្រសើរឡើងអំពីទីផ្សារការងារ ការសម្របសម្រួលល្អប្រសើរជាងមុន និងមានតំណភ្ជាប់ជាមួយនឹងវិស័យឧស្សាហកម្ម និងព័ត៌មានកាន់តែប្រសើរឡើងសម្រាប់និស្សិត ដូច្នេះពួកគេអាចជ្រើសរើសវគ្គសិក្សាមុខជំនាញដែលសមស្រប។ ដើម្បីធានាបាននូវកម្មវិធីមានគុណភាពខ្ពស់ដែលអាចទទួលស្គាល់ជាអន្តរជាតិបាននោះ ការកំណត់រចនាសម្ព័ន្ធតម្លៃសិក្សាមួយដែលមានកម្រិតសមរម្យក៏ជាបញ្ហាប្រឈមមួយផងដែរ។ ការបង្កើនកិច្ចខិតខំប្រឹងប្រែងនិងការផ្ដល់ធនធានបន្ថែម ជាកត្តាចាំបាច់ដើម្បីធានាថាសិស្សដែលមានទេពកោសល្យ និងមកពីក្រុមជួបការលំបាក នឹងអាចចូលសិក្សានៅឧត្តមសិក្សា តាមរយៈកម្មវិធីអាហារូបករណ៍ ឬគម្រោងប្រាក់កម្ចីសិក្សា។

រាជរដ្ឋាភិបាលបានទទួលស្គាល់អំពីសារៈសំខាន់ នៃការផ្ដល់កាលានុវត្តភាពក្នុងការសិក្សានៅឧត្តមសិក្សា និងអំពីសារៈសំខាន់ក្នុងការធានាគុណភាពនិងភាពឆ្លើយតប។ ការធ្វើសមាហរណកម្មអាស៊ាននឹងផ្ដល់ជាកាលានុវត្តភាព សម្រាប់ការសហការរវាងស្ថាប័ន ការស្រាវជ្រាវរួមគ្នា និងការកំណត់ស្តង់ដារគុណភាព។

### ៣.៥.២ វត្ថុបំណងគោលនយោបាយ

- បង្កើនភាគរយនិស្សិតអាហារូបករណ៍ និងកាណានុវត្តភាព ដល់និស្សិតចូលរៀននៅឧត្តមសិក្សា
- លើកកម្ពស់គុណភាព និងភាពឆ្លើយតប នៃការអប់រំឧត្តមសិក្សា
- អភិវឌ្ឍប្រព័ន្ធអប់រំឧត្តមសិក្សាឱ្យមានការប្រតិបត្តិពេញលេញ សម្រាប់គាំទ្រគ្រឹះស្ថានឧត្តមសិក្សា ដើម្បីទទួលបាន ស្តង់ដារថ្នាក់ជាតិ និងថ្នាក់តំបន់ នៅឆ្នាំ២០១៨។

### ៣.៥.៣ សកម្មភាពគោលនយោបាយ

- រៀបចំគោលនយោបាយជាតិស្តីពីអាហារូបករណ៍ ការឧបត្ថម្ភធន និងឥណទានសម្រាប់អ្នកសិក្សានៅឧត្តមសិក្សា នៅឆ្នាំ ២០១៤
- រៀបចំផែនការបង្កើនចំនួននិស្សិតផ្នែកវិទ្យាសាស្ត្រ បច្ចេកទេស វិស្វកម្ម សិល្បៈថ្លៃប្រនិត និង គណិតសាស្ត្រ នៅឆ្នាំ ២០១៤
- រៀបចំផែនការពង្រីកសេវាកម្មនិងធនធានរបស់គ្រឹះស្ថានឧត្តមសិក្សាតាមតំបន់ នៅឆ្នាំ ២០១៦
- បង្កើតគោលនយោបាយអភិវឌ្ឍធនធានមនុស្សសម្រាប់ឧត្តមសិក្សា នៅឆ្នាំ ២០១៥
- រៀបចំសេចក្តីណែនាំស្តីពីការជ្រើសរើសនិស្សិតចូលរៀននិងការបញ្ចប់ការសិក្សា នៅឆ្នាំ ២០១៤
- រៀបចំគោលការណ៍ណែនាំអំពីតម្លៃសិក្សាអប្បបរមាតាមមុខជំនាញសិក្សានៅឧត្តមសិក្សា នៅឆ្នាំ ២០១៧
- រៀបចំគោលការណ៍ណែនាំស្តីពីការអភិវឌ្ឍកម្មវិធីសិក្សា នៅឆ្នាំ ២០១៦
- រៀបចំគោលការណ៍ណែនាំស្តីពីការវាយតម្លៃតាមថ្នាក់រៀនជាប្រចាំ នៅឆ្នាំ ២០១៥
- រៀបចំបង្កើតមហាវិទ្យាល័យអប់រំនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ នៅឆ្នាំ ២០១៤
- រៀបចំសៀវភៅណែនាំប្រតិបត្តិស្តីពីគម្រោងស្រាវជ្រាវ នៅឆ្នាំ២០១៥
- រៀបចំសៀវភៅណែនាំប្រតិបត្តិស្តីពីការគ្រប់គ្រងបណ្ណាល័យ នៅឆ្នាំ ២០១៤
- រៀបចំសៀវភៅណែនាំប្រតិបត្តិស្តីពីការគ្រប់គ្រងបន្ទប់ពិសោធន៍ នៅឆ្នាំ ២០១៤
- រៀបចំសេចក្តីណែនាំស្តីពីការអភិវឌ្ឍកម្មវិធីចុះកម្មសិក្សា នៅឆ្នាំ ២០១៥
- រៀបចំសេចក្តីណែនាំស្តីពីការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា នៅឆ្នាំ ២០១៤
- រៀបចំយន្តការអនុវត្តព្រះរាជក្រឹត្យស្តីពីការផ្តល់ឋានៈសាស្ត្រាចារ្យ នៅឆ្នាំ ២០១៥
- រៀបចំរចនាសម្ព័ន្ធនិងយន្តការអនុវត្តគោលនយោបាយស្តីពីការស្រាវជ្រាវនិងអភិវឌ្ឍនៅឆ្នាំ២០១៤

### ៣.៤.៥ សូចនាករផលសម្រេច

- ចំនួនសាស្ត្រាចារ្យដែលមានគុណវុឌ្ឍិកម្រិតបរិញ្ញាបត្រជាន់ខ្ពស់កើន ១០០០ នាក់ និងកម្រិតបណ្ឌិត កើន ២៥០ នាក់ នៅឆ្នាំ ២០១៨
- ភាគរយនិស្សិតអាហារូបករណ៍ផ្ទុចូលរៀនឆ្នាំទី១ នៅតាមគ្រឹះស្ថានឧត្តមសិក្សារដ្ឋ កើនឡើងពី ៥ ភាគរយ នៅឆ្នាំ ២០១២ ដល់ ១៥ ភាគរយ នៅឆ្នាំ ២០១៨
- អត្រារួមនៃការសិក្សានៅឧត្តមសិក្សាកើនពី ១៣ ភាគរយ នៅឆ្នាំ ២០១២ ដល់ ២៣ ភាគរយ នៅឆ្នាំ ២០១៨
- អត្រានិស្សិតបញ្ចប់ការសិក្សាចន្លោះពី ៧៥ ទៅ ៨៥ ភាគរយ
- ភាគរយនិស្សិតបញ្ចប់ការសិក្សាមានការងារធ្វើបានកើនឡើងនៅឆ្នាំ ២០១៨ ចំនួន៥ ទៅ ១០ ភាគរយ ធៀបនឹងទិន្នន័យគោលដែលនឹងរកឃើញ ក្នុងឆ្នាំ ២០១៤
- ៨០ ភាគរយនៃគ្រឹះស្ថានឧត្តមសិក្សា បានរៀបចំផែនការថវិកាប្រចាំឆ្នាំ នៅឆ្នាំ ២០១៨
- ៥០ ភាគរយនៃគ្រឹះស្ថានឧត្តមសិក្សា សម្រេចបានតាមស្តង់ដារធានាគុណភាពផ្ទៃក្នុង នៅឆ្នាំ ២០១៨
- ថវិកាសម្រាប់អនុវិស័យឧត្តមសិក្សាពី ៨ ភាគរយ ដល់ ២០ ភាគរយ នៅឆ្នាំ ២០១៨
- ប្រព័ន្ធគ្រប់គ្រងផ្អែកលើលទ្ធផលនៅឧត្តមសិក្សា និងដំណើរការ នៅឆ្នាំ ២០១៨។

### ៣.៤.៦ កម្មវិធីនិងសកម្មភាព

- ***កម្មវិធីបង្កើនសមធម៌នៃការចូលរៀននៅឧត្តមសិក្សា***
  - ***កម្មវិធីផ្តល់និងពង្រីកអាហារូបករណ៍*** ៖ ពង្រីកនិងផ្តល់អាហារូបករណ៍ពេញលេញតាមរយៈ ការបង្កើនថវិការបស់រាជរដ្ឋាភិបាល និងថវិកាដៃគូអភិវឌ្ឍ។ មន្ត្រីអគ្គនាយកដ្ឋានឧត្តមសិក្សានិងគ្រឹះស្ថានឧត្តមសិក្សា និងដៃគូអភិវឌ្ឍចូលរួមសិក្ខាសាលា និងទស្សនកិច្ចសិក្សាស្តីពីអាហារូបករណ៍។
  - ***កម្មវិធីផ្តល់ប្រាក់កម្ចីសម្រាប់អ្នកសិក្សា*** ៖ នាយកដ្ឋានឧត្តមសិក្សាសហការជាមួយគ្រឹះស្ថានឧត្តមសិក្សានិងផ្នែកពាក់ព័ន្ធដទៃទៀត រៀបចំនិងអនុវត្តកម្មវិធីផ្តល់ប្រាក់កម្ចីសម្រាប់អ្នកសិក្សា។ មន្ត្រីអគ្គនាយកដ្ឋានឧត្តមសិក្សា គ្រឹះស្ថានឧត្តមសិក្សា និងអ្នកពាក់ព័ន្ធចូលរួមសិក្ខាសាលា និងទស្សនកិច្ចសិក្សាស្តីពីការផ្តល់ប្រាក់កម្ចីសម្រាប់អ្នកសិក្សា។
  - ***ការផ្តល់សេវាសិក្សា*** ៖ ផ្តល់ការគាំទ្រលើការសិក្សាដល់និស្សិតជួបការលំបាក ជាពិសេសដល់និស្សិត នៅឆ្នាំសិក្សាមូលដ្ឋាន ដូចជាសេវាប្រឹក្សាយោបល់។

# ឧបសម្ព័ន្ធ៣

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ ថ្ងៃសម្ភាសន៍៖.................................
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច អ្នកធ្វើសម្ភាសន៍៖.............................

**កម្រងសំណួរ**

កម្រងសំណួរនេះ មានគោលបំណងស្វែងរកព័ត៌មានបុគ្គលដែលមានការងារធ្វើក្រោយ បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រពីសាលា ឬសាកលវិទ្យាល័យនានា។ លទ្ធផលនៃការស្រាវជ្រាវ នេះយកទៅប្រើសម្រាប់ជាមធ្យោបាយបង្កើនប្រាក់ចំណូលបុគ្គលតាមរយៈការអប់រំ។ ខ្ញុំបាទជាអ្នក ស្រាវជ្រាវសំណូមពរ លោក លោកស្រីមេត្តាជួយផ្តល់ព័ត៌មានទៅតាមការជាក់ស្តែងដែលទទួល បានពីលទ្ធផលការងារបច្ចុប្បន្ន។

ព័ត៌មានរបស់ លោក លោកស្រី បានផ្តល់ក្នុងកម្រងសំណួរនេះនឹងរក្សាទុកយ៉ាងសម្ងាត់។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ក្នុងការសហការដល់កិច្ចស្រាវជ្រាវនេះ។

សូមគូស (√) ត្រង់លេខដែលជាចម្លើយរបស់លោក លោកស្រី។

ឈ្មោះបុគ្គល៖............................................ ភេទ៖ 1.□ ប្រុស 2. □ ស្រី ឆ្នាំកំណើត៖....................

បរិញ្ញាបត្រ (ជំនាញ)
1.□ នីតិសាស្ត្រ 7. □ សេដ្ឋកិច្ចព័ត៌មានវិទ្យា
2.□ រដ្ឋបាលសាធារណៈ 8. □ គ្រប់គ្រងទេសចរណ៍
3.□ គ្រប់គ្រងអាជីវកម្ម 9. □ ទំនាក់ទំនងអន្តរជាតិ
4.□ សេដ្ឋកិច្ចអភិវឌ្ឍន៍ 10.□ ទីផ្សារ
5.□ គណនេយ្យ 11.□ សំណង់ស៊ីវិល
6.□ ធនាគារ និងហិរញ្ញវត្ថុ 12.□ ភាសាអង់គ្លេស
13.□ ផ្សេងពីនេះ

១. តើលោក លោកស្រីរៀននៅសាកលវិទ្យាល័យណា?

1.□ RULE 2.□ NUM 3.□ RUPP 4.□ ICT 5.□ VAI 6.□ BBU 7.□ ផ្សេងពីនេះ......

២. តើលោក លោកស្រីរៀនបានដល់កម្រិតណា?

1.□បឋម 2.□អនុវិទ្យាល័យ 3.□វិទ្យាល័យ 4.□បរិញ្ញាបត្ររង
5.□បរិញ្ញាបត្រ 6.□បរិញ្ញាបត្រជាន់ខ្ពស់ 7.□បណ្ឌិត

៣. បើគិតជាចំនួនឆ្នាំតើលោក លោកស្រីរៀនបានប៉ុន្មានឆ្នាំ? ចំនួន៖.........................ឆ្នាំ

៤. តើលោក លោកស្រីមានការងារធ្វើហើយឬនៅ?

1.□ មាន 2.□ អត់មាន

៥. តើលោក លោកស្រីបានទទួលការងារធ្វើនៅខែទីប៉ុន្មានបន្ទាប់ពីបញ្ចប់ការសិក្សា? ខែទី....................

៦. តើលោក លោកស្រីបំរើការនៅក្នុងវិស័យណា?

1.□ រដ្ឋ 2.□ ឯកជន 3.□ អង្គការសង្គមស៊ីវិល

៧. តើលោក លោកស្រីធ្វើការត្រូវជំនាញដែលអ្នកបានសិក្សាដែរឬទេ?

1.□ ត្រូវជំនាញ 2.□ ខុសជំនាញ

៨. តើលោក លោកស្រីធ្វើការនៅផ្នែកអ្វី?

1.□ គណនេយ្យ 2.□ ទីផ្សារ 3.□ គ្រប់គ្រង 4.□ ច្បាប់ 5.□ រដ្ឋបាល 6.□ ធនាគារ
7.□ សំណង់ 8.□ បេឡា 9.□ គ្រូបង្រៀន 10.ផ្សេងពីនេះ....................................

៩. តើលោក លោកស្រីមានបទពិសោធក្នុងការងារចំនួនប៉ុន្មានឆ្នាំ? ចំនួន៖................ឆ្នាំ

១០. តើលោក លោកស្រីទទួលបានប្រាក់ចំណូលប្រចាំខែប៉ុន្មាន? ចំនួន៖................$

១១. តើប្រាក់ចំណូលប្រចាំខែរបស់លោក លោកស្រីអាចប្រែប្រួលដោយសារកត្តាអ្វី?

1.□ លទ្ធផលការងារ 2.□ ភាពស្មោះត្រង់ 3.□ ការងារបន្ថែមម៉ោង
4.□ របរបន្ថែម 5.□ ផ្សេងពីនេះ..............................